ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ការបណ្តុះបណ្តាលឆ្លងមណ្ឌលសុខភាព

អំពីការថែទាំក្នុងអំឡុងពេលឈឺពោះសម្រាលនិងពេលសម្រាល

# សៀវភៅណែនាំស្តីអំពីការវាយតម្លៃដំបូង

ខែមករា ឆ្នាំ២០២០

# អារម្ភកថា

ការមានផ្ទៃពោះ និងការសម្រាលកូន គឺជាដំណើរការសរីរសាស្ត្រមួយដែលមានជាយូរលង់ណាស់មកហើយ តាំងពីមនុស្សបានកកើតមក។ ដំណើរការដែលផ្តើមពីការមានផ្ទៃពោះ រហូតដល់ពេលសម្រាលដោយសុវត្ថិភាព ពិតជាមានតម្លៃ និងមានអត្ថន័យណាស់ សម្រាប់ស្ត្រីដែលនឹងក្លាយជាមាតា ក៏ដូចជាសម្រាប់ទារកទើបកើត និងសម្រាប់គ្រួសារទាំងមូល។ ជាទូទៅ ជំហាន និងដំណាក់កាលនៃការសម្រាលកូននិមួយៗប្រព្រឹត្តទៅដូចគ្នា តែដំណើរការវិវត្តន៍នៃការសម្រាលកូនមានភាពប្លែកគ្នាពីស្ត្រីម្នាក់ទៅស្ត្រីម្នាក់ទៀត។

ការលើកកម្ពស់សុខភាពមាតា ទារក និងកុមារ ជាអន្តរាគមន៍អទិភាព និងចម្បងនៅក្នុងវិស័យសុខាភិបាល។ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាទទួលបានជោគជ័យ និងសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ និងទី៥ ក្នុងការកាត់បន្ថយអត្រាមរណភាពមាតាពី១០២០នាក់នៅឆ្នាំ១៩៩០ មកនៅ១៧០នាក់ក្នុងកំណើតរស់១សែននាក់នៅឆ្នាំ២០១៤ និងកាត់បន្ថយអត្រាមរណភាពទារកទើបកើតពី៣៧នាក់នៅឆ្នាំ២០០០ មកនៅ១៨នាក់ក្នុងកំណើតរស់១ពាន់នាក់នៅឆ្នាំ២០១៤។ ប៉ុន្តែបច្ចុប្បន្ននេះកម្ពុជាត្រូវប្រឹងឱ្យកាន់តែខ្លាំងថែមទៀត ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០។ ដើម្បីឱ្យការសម្រាលកូនមានសុវត្ថិភាពនិងជួយសង្គ្រោះជីវិតមាតានិងទារកបាន យើងបានខិតខំអស់លទ្ធភាពក្នុងការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត (EmONC)ពិសេសសម្រាប់អន្តរាគមន៍នៅពេលមានការសម្រាលកូនមានផលវិបាក។ ជាមួយគ្នានេះយើងត្រូវធ្វើឱ្យប្រសើរ និងយកចិត្តទុកដាក់លើគុណភាពនៃការថែទាំសម្រាប់ការសម្រាលកូនធម្មតា/គ្មានផលវិបាកដែលជាទូទៅមានប្រមាណជា៨០%នៃការសម្រាលទាំងអស់។ ការតាមដានវាយតម្លៃដោយយកចិត្តទុកដាក់ដោយឆ្មបជំនាញលើស្ថានភាពសុខភាពទាំងមាតាទាំងទារក និងការតាមដានការវិវត្តជាបន្តបន្ទាប់រហូតដល់ការសម្រាលកូន ជាការចាំបាច់ណាស់។ សកម្មភាព និងការសង្កេតប្រកបដោយវិជ្ជាជីវៈ នឹងជួយឱ្យរកឃើញទាន់ពេលវេលានូវករណីមិនធម្មតា/មានផលវិបាក គាំទ្រការវិវត្តនៃការសម្រាលឱ្យប្រព្រឹត្តទៅធម្មតា ជួយបញ្ចៀសផលវិបាកឬការធ្វើអន្តរាគមន៍មិនចាំបាច់នានា។

សៀវភៅណែនាំនេះ បង្ហាញឱ្យឆ្មបជំនាញចេះអំពីការវាយតម្លៃដំបូងលើស្ថានភាពស្ត្រី/ទារកដោយប្រើប្រាស់ឧបករណ៍វាយតម្លៃដំបូង(តារាងវាយតម្លៃIAS) នៅពេលស្ត្រីមានផ្ទៃពោះមកដល់មូលដ្ឋានសុខាភិបាលដើម្បីសម្រាលកូន។ ខ្ញុំសង្ឃឹមថាសៀវភៅណែនាំនេះ នឹងជួយដល់ការពង្រឹងគុណភាពសេវា និងជួយលើកកម្ពស់សុខភាពមាតា ទារក និងកុមារនៅកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃ ខែ ឆ្នាំ ព.ស ២៥៦៣

ត្រូវនឹងថ្ងៃ ទី ខែ ឆ្នាំ ២០២០

សាស្ត្រាចារ្យ អេង_ហួត

រដ្ឋលេខាធិការ

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះត្រូវបានរៀបរៀងជាដំបូងដោយសមាជិកគ្រូបង្គោលនៃមជ្ឈមណ្ឌលជាតិ គាំពារមាតា និងទារក (NMCHC) ក្នុងប្រទេសកម្ពុជា ដោយមានការគាំទ្រ បច្ចេកទេសពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) គម្រោងលើកកម្ពស់ការថែទាំបន្តនៅកម្ពុជាផ្តោតលើការថែទាំស្ត្រីនិងទារកក្នុងពេលសម្រាល និងក្រោយពេលសម្រាល ( គម្រោងIINeoC ) ។ ក្រសួងសុខាភិបាល អរគុណ យ៉ាងជ្រាលជ្រៅចំពោះការណែនាំ បច្ចេកទេស ពីសមាគមន៍ផ្នែកសម្ភពនិងរោគស្ត្រីនៅកម្ពុជា (SCGO) ។

# មាតិកា

អារម្ភកថា
សេចក្តីថ្លែងអំណរគុណ
សទ្ទានុក្រម
ទិដ្ឋភាពទូទៅនៃតារាងវាយតម្លៃដំបូង
**ជំពូកទី ១ ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ** ....... 3
**១-១. កម្រិតស្មារតី** ....... 4
**១-២. ផ្លូវខ្យល់ និងការដកដង្ហើម** ....... 7
**១-៣. សញ្ញាស្តុក** ....... 9
**១-៤. សញ្ញាជីវិតមិនធម្មតា-ការលើសសម្ពាធឈាមអប្បបរមា** ....... 13
**១-៥. សញ្ញាជីវិតមិនធម្មតា - គ្រុនក្តៅ** ....... 15
**១-៦. សញ្ញាជីវិតមិនធម្មតា - ការធ្លាក់ឈាម** ....... 17
**១-៧. ការបង្ហាញមិនធម្មតា** ....... 18
**ជំពូកទី២ ស្តាប់ការត្អូញត្អែររបស់ស្ត្រី** ....... 19
**២-១. ការធ្លាក់ឈាម** ....... 20
**២-២. ជ្រាបទឹកភ្លោះតាមទ្វារមាស** ....... 22
**២-៣. ស្បូនកន្ត្រាក់ និងការឈឺពោះសម្រាល** ....... 25
**២-៤. ចលនាទារកក្នុងផ្ទៃ** ....... 28
**ជំពូកទី៣ ព័ត៌មានទូទៅ និងប្រវត្តិសម្ភពរបស់ស្ត្រី** ....... 29
**៣-១. អាយុនៃគភ៌ពេលចូលសម្រាកពេទ្យ** ....... 30
**៣-២. កម្ពស់ស្បូននៅពេលចូលសម្រាកពេទ្យ** ....... 34
**៣-៣. អាយុស្ត្រី** ....... 38
**៣-៤. ចំនួនផ្ទៃពោះ ចំនួនសម្រាល ចំនួនរលូតឬរំលូត** ....... 40
**៣-៥. ចំនួនទារកក្នុងផ្ទៃ** ....... 42
**៣-៦. កម្ពស់ស្ត្រី** ....... 43
**៣-៧. ភាពស្លេកស្លាំង** ....... 45
៣-៨-១. ការបង្ករោគ- មេរោគអេដស៍ (HIV) ....... 47
៣-៨-២. ការបង្ករោគ - មេរោគស្វាយ ....... 49
៣-៩-១. ប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន - ការធ្លាក់ឈាមមុនសម្រាល ....... 51
៣-៩-២. ប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន - ការលើសសម្ពាធឈាម ....... 51

៣-១០. ប្រវត្តិនៃការសម្រាលនៃផ្ទៃពោះមុន ........ 53
៣-១១. ប្រវត្តិជំងឺទូទៅ ........ 55
ជំពូកទី៤ ការសង្កេតមើលស្ថានភាពទារកក្នុងផ្ទៃ ........ 56
៤-១. សណ្ឋាន ទម្រង់បង្ហាញ និងការបង្ហាញរបស់ទារក ........ 57
៤-១-១. សណ្ឋាន និង ទម្រង់បង្ហាញរបស់ទារក ........ 57
៤-១-២. ការបង្ហាញរបស់ទារកក្នុងទម្រង់បង្ហាញកំពូលក្បាល ........ 65
៤-២. ស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃៈ ........ 71
៤-២-១. ចង្វាក់បេះដូងទារក (FHR)/BCF ........ 71
៤-២-២. ទឹកភ្លោះ ........ 75
ជំពកទី ៥ ការប៉ាន់ប្រមាណការវិវត្ត ការឈឺពោះសម្រាល ........ 77
៥-១. ៤Ps - កម្លាំង ផ្លូវឆ្លងកាត់ អ្នកធ្វើដំណើរនិង ផ្លូវចិត្ត ........ 78
៥-២. កំណត់ពីដំណាក់កាលនៃការឈឺពោះសម្រាល ........ 80
៥-៣. អនុវត្តការប៉ាន់ប្រមាណការវិវត្តនៃការឈឺពោះសម្រាល ........ 83
៥-៤. ការប៉ាន់ប្រមាណរយៈពេលនៃការឈឺពោះសម្រាល ........ 92
៥-៥. ស្ថានភាពដែលត្រូវពិចារណា ........ 93
ជំពូកទី ៦ ការសង្កេតមើលស្ថានភាពម្តាយ ........ 94
៦-១. សម្ពាធឈាម ........ 95
៦-២. សញ្ញានៃការលើសសម្ពាធឈាម ........ 98
៦-៣. ជីពចរ ........ 99
៦-៤. សីតុណ្ហភាពរាងកាយ ........ 101
៦-៥. ការពិនិត្យទឹកនោម ........ 104
៦-៦. ការធ្លាក់ឈាម ........ 107
៦-៧. ស្ថានភាពផ្លូវចិត្ត ........ 110
ឧបសម្ព័ន្ធ ១ ........ 112
ឧបសម្ព័ន្ធ ២ ........ 118
ឧបសម្ព័ន្ធ ៣ ........ 121
ឯកសារយោង ........ 123
សមាជិករៀបរៀងនិងប្រែសម្រួលសៀវភៅណែនាំនេះ: ........ 125

# សន្ទានុក្រម

## ពាក្យកាត់

| | |
|---|---|
| ANC | ការពិនិត្យផ្ទៃពោះ |
| BP | សម្ពាធឈាម |
| CPD | វិសមាមាត្ររវាងឆ្អឹងក្បាលទារកនិងឆ្អឹងអាងត្រគាកម្ដាយ |
| EDD | កាលបរិច្ឆេទសម្រាលរពឹងទុក |
| FHR | ចង្វាក់បេះដូងកូន |
| Hb | អេម៉ូក្លូប៊ីន |
| HIV | មេរោគដែលបង្កឱ្យកើតជាជំងឺអេដស៍ |
| IA | ការវាយតម្លៃដំបូង |
| IAS | តារាងវាយតម្លៃដំបូង |
| IM | ចាក់តាមសាច់ដុំ |
| IV | ចាក់តាមសរសៃវ៉ែន |
| LOA | អុកស៊ីពុតមុខឆ្វេង |
| LOP | អុកស៊ីពុតក្រោយឆ្វេង |
| LOT | អុកស៊ីពុតទទឹងឆ្វេង |
| LMP | រដូវចុងក្រោយ |
| MAS | បញ្ហាផ្លូវដង្ហើមពេលទារកដកដង្ហើមចូលលាមក៍ព្រៃ |
| MgSO4 | ថ្នាំម៉ាញ៉េស្យូមស៊ុលហ្វាត |
| NS | សេរ៉ូមប្រៃ |
| OA | អុកស៊ីពុតមុខ |
| OP | អុកស៊ីពុតក្រោយ |
| OT | អុកស៊ីពុតទទឹង |
| PPH | ការធ្លាក់ឈាមក្រោយសម្រាល |
| PROM | បែកស្រោមទឹកភ្លោះមុនឈឺពោះសម្រាល |

| | |
|---|---|
| RPR test | តេស្តពិនិត្យរកមេរោគស្វាយ |
| ROA | អុកស៊ីពុតមុខស្តាំ |
| ROP | អុកស៊ីពុតក្រោយស្តាំ |
| ROT | អុកស៊ីពុតទទឹងស្តាំ |
| SI | របៀបគណនាស្មុក |
| STI | ជំងឺបង្ករោគឆ្លងតាមផ្លូវភេទ |
| WHO | អង្គការសុខភាពពិភពលោក |

# និដ្ឋភាពទូទៅនៃតារាងវាយតម្លៃដំបូង

## តើអ្វីទៅជា <ការវាយតម្លៃដំបូង> ?

តួនាទីរបស់ឆ្មបនៅមណ្ឌលសុខភាពគឺផ្តល់ការថែទាំដល់ស្ត្រីមានផ្ទៃពោះ ទារកក្នុងផ្ទៃ និងទារកទើបនឹងកើតជាបន្តបន្ទាប់រហូតដល់គេទាំងអស់គ្នា ស្ថិតនៅក្នុងស្ថានភាពធម្មតា ។ **ស្ថានភាពបី៖**((១) **ការវិវត្តរបស់ម្តាយ** (២) **ការវិវត្តរបស់ទារក និង**(៣) **ការវិវត្តការសម្រាល**) គួរត្រូវ បានតាមដានឱ្យបានដិតដល់ និងគ្រប់ជ្រុងជ្រោយ ។ វាមានសារៈសំខាន់ផងដែរក្នុងការអង្កេតបញ្ហា ហើយប្រសិនបើចាំបាច់ត្រូវបញ្ជូនអ្នកជំងឺឱ្យបានសមស្រប ។ នៅពេលដែលស្ត្រីមានផ្ទៃពោះមកកាន់ មណ្ឌលសុខភាពដើម្បីសម្រាលកូន ឆ្មបត្រូវពិនិត្យស្ថានភាព របស់គាត់ជាលក្ខណៈប្រព័ន្ធ ។ ឆ្មបត្រូវឆ្លើយតបភ្លាមៗទៅនឹងករណីសង្គ្រោះបន្ទាន់ស្តាប់ការត្អូញត្អែររបស់ស្ត្រី ប្រមូលព័ត៌មានទូទៅរបស់គាត់ និងប៉ាន់ប្រមាណការវិវត្តការសម្រាល ។ ជាចុងបញ្ចប់ឆ្មបធ្វើការ សម្រេចពីស្ថានភាពស្ត្រីតាមរយៈព័ត៌មានទាំងអស់ដែលប្រមូលបាន។ យើងហៅជំហានទាំងនេះ ថាជា **'ការវាយតម្លៃដំបូង'** ។

## <តើអ្វីទៅជា 'តារាងវាយតម្លៃដំបូង (IAS)' ?>

សម្រាប់ការវាយតម្លៃដំបូង ឆ្មបអាចប្រើប្រាស់ឧបករណ៍ IAS ។ IAS គឺជាឧបករណ៍ដែលគួរឱ្យទុកចិត្តបានដើម្បីប្រមូលព័ត៌មានបានគ្រប់ជ្រុងជ្រោយនៅពេលជួបស្ត្រីលើកដំបូងដែលជាស្ត្រីត្រូវ សម្រាលកូនក្នុងពេលឆាប់ៗនេះ ។ ក្នុងការប្រើប្រាស់IAS ឆ្មបអាចចាត់ថ្នាក់ ស្ថានភាព ទៅជាបីដំណាក់ កាល/ពណ៌៖ 'សញ្ញាធម្មតា (ពណ៌បៃតង)', 'សញ្ញាប្រឈមនឹងគ្រោះថ្នាក់ (ពណ៌លឿង)' **និង** **'សញ្ញា មិនធម្មតា/ផលវិបាក/ សង្គ្រោះបន្ទាន់ (ពណ៌ក្រហម)'** ។ ឆ្មបអាចបញ្ជូនករណីដែលមាន **'ពណ៌ក្រហម'** ភ្លាម ។ ឆ្មបក៏អាចសង្កេតករណីដែលមាន **'ពណ៌លឿង'** ដោយប្រុងប្រយ័ត្នដើម្បីជៀសវាង ការវិវត្តទៅជាករណីដែលមានផលវិបាកខ្លាំងថែមទៀត ។

## <មាតិការនៃ IAS >

IAS គឺជាស៊េរីនៃតារាងដែលរួមបញ្ចូលព័ត៌មានដែលគួរប្រមូល។ IAS គ្របដណ្តប់លើប្រាំមួយប្រធានបទមាន៖

១. ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ

២. ស្តាប់ការត្អូញត្អែររបស់ស្ត្រី

៣. ព័ត៌មានទូទៅ និងប្រវត្តិសម្ភពរបស់ស្ត្រី

៤. ការសង្កេតមើលស្ថានភាពទារកក្នុងផ្ទៃ

៥. ការប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល

៦. តាមដានស្ថានភាពរបស់ស្ត្រី

លំដាប់លំដោយនៃ IA គឺពី ១. ទៅ ៦. អាចសម្រេចដោយបត់បែនបានយោងទៅតាមស្ថានភាពរបស់ស្ត្រី។ សម្រាប់តារាងនៃសមាសភាគនិមួយៗ ប្រធានបទ**មួយចំនួន** ដែលត្រូវពិនិត្យ គឺស្ថិតនៅ ជួរដេក ។ សម្រាប់ជួរដេកនិមួយៗ ទិន្នន័យស្តង់ដា (ការកាត់បន្ថយ, ចំណាត់ថ្នាក់, -ល-) ដើម្បីធ្វើការប៉ាន់ប្រមាណ គឺបង្ហាញក្នុងជួរឈរបី ‘សញ្ញាធម្មតា (ពណ៌បៃតង)’, ‘សញ្ញាប្រឈមមុខគ្រោះថ្នាក់ (ពណ៌ លឿង)’ **និង ‘សញ្ញាមិនធម្មតា/ ផលវិបាក/សង្គ្រោះបន្ទាន់ (ពណ៌ក្រហម)’ ។** ឆ្មបអាច ( ✔ ) នៅត្រង់កន្លែងដែលត្រឹមត្រូវបន្ទាប់ពីធ្វើការប៉ាន់ប្រមាណ ។

# ជំពូកទី ១ ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ


**សង្ខេប**

- វត្ថុបំណងនៃជំពូកនេះគឺ (១) រៀបរាប់ពីភាពខុសគ្នានៃករណីសង្គ្រោះបន្ទាន់និង (២) ផ្ដល់ការថែទាំព្យាបាលដំបូងភ្លាមៗតាមករណីមុនពេល ធ្វើការបញ្ជូន ។
- ការបង្ហាញទូទៅនៃស្ថានភាពរបស់ស្ត្រីមានសារៈសំខាន់ណាស់ក្នុងការបែងចែកករណីសង្គ្រោះបន្ទាន់ ។
- ករណីដែលអ្នកយល់ថាស្ត្រីមានផ្ទៃពោះស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរដោយពិនិត្យភ្លាមៗ លើ **'ស្មារតី' 'ការដកដង្ហើម' 'សញ្ញាស្លុក' 'សញ្ញាជីវិត'** (**សម្ពាធឈាម ជីពចរ និងសីតុណ្ហភាពរាងកាយ**) និង **'ការធ្លាក់ឈាមតាមទ្វារមាស'** ។
- វាមានសារៈសំខាន់ក្នុងការបញ្ជូនស្ត្រីឱ្យបានលឿនតាមដែលអាចធ្វើបានដើម្បីសង្គ្រោះជីវិតស្ត្រីដោយមិនចាំបាច់វាយតម្លៃគ្រប់ក្នុងតារាងកត់ត្រាការវាយតម្លៃដំបូងក្នុងករណីបន្ទាន់នោះទេ ។

## ១-១. កម្រិតស្មារតី

《**សង្ខេប**》

- ការសន្លប់គឺជាសញ្ញាសំខាន់ដែលធ្វើឱ្យខូចខួរក្បាល ។ ដូច្នេះវាគឺជាស្ថានភាពបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ។
- មធ្យោបាយដែលងាយបំផុតក្នុងការពិនិត្យមើលកម្រិតស្មារតីគឺការនិយាយជាមួយស្ត្រី ។
- ប្រសិនបើស្ត្រីមិនឆ្លើយតប ឬ ស្គាល់អ្នកទេ សូមចូលទៅជំហានបន្ទាប់ភ្លាម ដោយពិនិត្យមើល 'ការដកដង្ហើម' 'សញ្ញាជីវិត' (សម្ពាធឈាម ជីពចរ និងសីតុណ្ហភាពរាងកាយ) និង 'ការធ្លាក់ឈាម' ។
- ប្រសិនបើស្ត្រីសន្លប់ និងមានការប្រកាច់ ឬ ទើបតែមានការប្រកាច់ថ្មីៗ នោះមូលហេតុច្រើនបណ្ដាលមកពីជំងឺក្រឡាភ្លើង ។
- ត្រូវផ្ដល់ម៉ាញ៉េស្យូមសុលហ្វាត (MgSO4) ដល់ស្ត្រីដើម្បីព្យាបាលជំងឺក្រឡាភ្លើងមុនពេលបញ្ជូន។

### ១-១-១. ពិនិត្យកម្រិតស្មារតី

- មធ្យោបាយងាយបំផុតក្នុងការពិនិត្យ 'ស្មារតី' គឺការនិយាយជាមួយស្ត្រី ។
- ប្រសិនបើស្ត្រីមិនឆ្លើយតបឬស្គាល់អ្នកសូមចូលទៅជំហានបន្ទាប់ភ្លាមដោយពិនិត្យមើលផ្លូវដង្ហើម និងស្ថានភាពនៃការដកដង្ហើម ។
- បន្ទាប់មកពិនិត្យ**សញ្ញាជីវិត** (**សម្ពាធឈាម ជីពចរ និងសីតុណ្ហភាពរាងកាយ**) និង**ការធ្លាក់ឈាមតាមទ្វារមាស** ។
- ប្រសិនបើស្ត្រីសន្លប់ ឬ កំពុងប្រកាច់ត្រូវដាក់ស្ថានភាពស្ត្រីក្នុង**ដំណេកផ្អៀងឆ្វេង** ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការស្រូបចូលស្លេសកំអួត និងឈាម ។
- សួរគ្រួសារស្ត្រីថាតើស្ត្រីទើបមានការប្រកាច់ ឬ ទេ ?

## ១-១-២. ផលវិបាករួមនៃស្ថានភាពសង្គ្រោះបន្ទាន់

### ១-១-២-១. ការសន្លប់

ការសន្លប់ជាសញ្ញាសំខាន់ដែលធ្វើឱ្យខូចខួរក្បាល ។ ដូច្នេះវាជាស្ថានភាពបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ ។ ប្រសិនបើសន្លប់ ឬ **កំពុងប្រកាច់** (**រួមបញ្ចូលប្រវត្តិថ្មីៗនៃការប្រកាច់**) នោះប្រហែលជាជំងឺក្រឡាភ្លើង ។ សំខាន់ណាស់ក្នុងការបញ្ជាក់ពីប្រវត្តិនេះជាមួយនឹងអ្នកកំដរ(សមាជិកគ្រួសារ) ។ ត្រូវបញ្ជូនស្ត្រី ដោយការផ្តល់ MgSO4 ដូសដំបូង ។

### ១-១-២-២. ការប្រកាច់

- ការប្រកាច់ក៏ជាសញ្ញាខូចខួរក្បាលដូចគ្នា ។ នៅពេលដែលមានការប្រកាច់ ជាញឹកញាប់ច្រើនរួមជាមួយការពិបាកដកដង្ហើម ។ វាជាហេតុធ្វើឱ្យ**ការផ្គត់ផ្គង់អុកស៊ីសែន**ពីម្តាយទៅកូនត្រូវបានកាត់ផ្តាច់ ។ ការប្រកាច់អាចបង្កឱ្យមានក្អួតដែលអាចធ្វើឱ្យស្ទះផ្លូវដង្ហើម(បំពង់ក ឬ បំពង់ខ្យល់)ចំពោះស្ត្រីមានផ្ទៃពោះផងដែរ ។
- ប្រសិនមានប្រកាច់រួមជាមួយការ**លើសសម្ពាធឈាម**ធ្ងន់ធ្ងរ (**សម្ពាធឈាមអប្បបរមាស្មើឬធំជាង ១១០ មមបារត**) វាអាចជា**ជំងឺក្រឡាភ្លើង ។** ហើយវាក៏អាចបណ្តាលមកពីគ្រុនចាញ់ធ្ងន់ធ្ងរ ជំងឺឆ្កួតជ្រូក ឬ រលាកស្រោមខួរក្បាលផងដែរ ។ ទោះបីជាយ៉ាងនេះក្តីការព្យាបាលដំបូងចំពោះជំងឺក្រឡាភ្លើងគឺជាការប្រសើរ ទោះបីជាការប្រកាច់មកពីមូលហេតុផ្សេងទៀតក៏ដោយពីព្រោះវាពិបាកក្នុងការកំណត់រោគវិនិច្ឆ័យនៅក្នុងថ្នាក់មណ្ឌលសុខភាព ។

## ១-១-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

(យោងតាម *ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព* ទំព័រទី២៥)

- ដំបូងគេបង្អស់ ព្យាយាមចាក់សរសៃដោយប្រើម្ជុលកាតេទ័រ (ម្ជុរជ័រ) និងភ្ជាប់ជាមួយសេរ៉ូមប្រៃ ឬ សេរ៉ូមឡាក់តាតរីងជ័រ (Lactate Ringer) ។
- ទោះបីជាការ**ចាក់តាមសរសៃ**មានសារៈសខាន់ក៏ដោយ តែពេលខ្លះអាចនឹងពិបាកអនុវត្តពេលដែលស្ត្រីកំពុងតែប្រកាច់ ។ ក្នុងករណីនេះឆ្មបអាចចាក់ម៉ាញ៉េស្យូមសុលហ្វាត **តាមសាច់ដុំ**មុនក៏បាន ។
- រក្សាស្ថានភាពស្ត្រីគេងផ្អៀងឆ្វេង ។

- ការផ្តល់ MgSO4៖
    - របៀបផ្តល់ម៉ាញ៉េស្យូមស៊ុលហ្វាតតាមសរសៃ៖បូមម៉ាញ៉េស្យូមស៊ុលហ្វាត ៥០% មួយអំពូល (១០ម.ល) ដោយស៊ីរ៉ាំងលេខ ៣០ ឬ ៥០ម.ល ជាមួយនឹងម្ជុលលេខ ១៨G ។ អ្នកក៏អាចប្រើប្រាស់ទំហំម្ជុលផ្សេងទៀតដែរ ប៉ុន្តែលេខម្ជុលកាន់តែធំគឺកាន់តែងាយបឺតថ្នាំ។រួចបូមសេរ៉ូមប្រៃ (Normal saline) ២០ម.ល ចូលក្នុងស៊ីរ៉ាំងតែមួយសម្រាប់ពង្រាវកំហាប់ម៉ាញ៉េស្យូមស៊ុលហ្វាត ។ បន្ទាប់មក ប្តូរម្ជុលពីលេខ ១៨G ទៅលេខ ២៥G ដើម្បីចាក់ចូលសរសៃវ៉ែន ។ ថ្នាំអាចនឹងចាក់ចូលតាមជ័រកៅស៊ូ នៃទ្រូសសេរ៉ូម (រៀបរាប់ពីខាងលើ)។ អ្នកត្រូវចាក់យឺតៗចន្លោះពី ១៥ ទៅ ២០ នាទី។ **កុំ**ចាក់ម៉ាញ៉េស្យូមស៊ុលហ្វាតតាមសរសៃ**លឿនពេក** វា អាចបណ្តាលឱ្យស្ត្រី**ឈប់ដកដង្ហើម** (Apnea) និង**ស្លាប់**បាន ។
    - របៀបផ្តល់ម៉ាញ៉េស្យូមស៊ុលហ្វាតតាមសាច់ដុំ៖ សម្រាប់ការចាក់សាច់ដុំ (IM) បូមម៉ាញ៉េស្យូមស៊ុលហ្វាត ៥០% អំពូល ១០ម.ល ដាក់ក្នុង២ ស៊ីរ៉ាំងរួច ចាក់សាច់ដុំត្រគាកទាំងសងខាង (ឆ្វេងម្ខាងស្តាំម្ខាង) ។
    - ប្រសិនបើ**សម្ពាធឈាមអប្បបរមា > ១០០មមបារត** ផ្តល់**អ៊ីដ្រាឡាស៊ីន (Hydralazine)** ដែលជាថ្នាំបញ្ចុះសម្ពាធឈាម ។ លាយអ៊ីដ្រាឡាស៊ីនមួយអំពូល ១០មីលីក្រាម(១ម.ល)ជាមួយ នឹងទឹកសេរ៉ូម ៩ម.ល ។ ចាក់តាមសរសៃវ៉ែនអ៊ីដ្រាឡាស៊ីន ១០មីលីក្រាមយឺតៗ ៣ ទៅ ៤នាទី ។ ប្រសិនមិនអាចចាក់តាមសរសៃវ៉ែនបានទេ ត្រូវចាក់សាច់ដុំ ។

**<u>សម្គាល់៖</u>**

- ខណៈពេលដែលរង់ចាំរថយន្តសង្គ្រោះ ឬ យានជំនិះ ប្រសិនបើកន្លងផុត ៣០នាទី ហើយ សម្ពាធឈាមអប្បបរមានៅតែច្រើនជាង ៩០មមបារតចាក់ Hydralazine ល្បាយតាមសរសៃវ៉ែន ១០មីលីក្រាមបន្ថែមទៀត ។ សរុបទាំងអស់មិនត្រូវផ្តល់ថ្នាំលើសពី ២០មីលីក្រាមទេ ។
- កត់ត្រា**កម្រិតថ្នាំ និងពេលវេលា**នៃការចាក់លើលិខិតបញ្ជូន ។

## ១-២. ផ្លូវខ្យល់ និងការដកដង្ហើម

《**សង្ខេប**》

- នៅពេលដែលស្ត្រីសន្លប់ ឬ មិនមានការឆ្លើយតបបានល្អប្រសើរទេត្រូវពិនិត្យផ្លូវខ្យល់ និងធានា ថាផ្លូវខ្យល់នៅចំហរ ។
- ស្តាប់សូរដកដង្ហើមរបស់ស្ត្រី ឬ មើលចលនាទ្រូង ។ នៅពេលដែលស្ត្រីដកដង្ហើមរាប់ចង្វាក់ដង្ហើម ។
- ប្រសិនបើស្ត្រីមិនដកដង្ហើម ជំនួយការដកដង្ហើមតាមរយៈការសប់បញ្ចូលខ្យល់ដោយប្រើម៉ាស់ និងបាល់ឡុង ។
- នៅពេលដែលមានការដង្ហើមខ្លីហើយញាប់ (ច្រើនជាង ៣០ដងក្នុងមួយនាទី) ពិបាកដកដង្ហើមមានពណ៌ ស្វាយនៅលើស្បែក ឬ បបូរមាត់នោះបញ្ជាក់ថាខ្វះអុកស៊ីសែន នៅក្នុងឈាម ។
- ប្រសិនបើសង្កេតឃើញរោគសញ្ញាទាំងនេះ ត្រូវផ្តល់អុកស៊ីសែន មុនពេលបញ្ជូន (ប្រសិនបើមាន) ។

### ១-២-១. ពិនិត្យមើលផ្លូវខ្យល់និងការដកដង្ហើម

- នៅពេលដែលស្ត្រីមានផ្ទៃពោះសន្លប់ ពិនិត្យមើលថាគាត់មានដកដង្ហើម ឬទេ?
- ប្រសិនបើស្ត្រីមិនដកដង្ហើម ដាក់ស្ត្រីក្នុងស្ថានភាពដងខ្លួនត្រង់ ហើយចាប់ផ្តើម ផ្តល់ជំនួយការដកដង្ហើមដោយប្រើម៉ាស់និងបាល់ឡុង ។ ពិនិត្យមើលថាមានអ្វីនៅក្នុងមាត់របស់ស្ត្រី ឬ ទេ ព្រោះអាចរាំងស្ទះដល់ផ្លូវខ្យល់របស់គាត់ ។
- នៅពេលដែលស្ត្រីដកដង្ហើមបាន ត្រូវស្តាប់សូរដង្ហើម មើលចលនាទ្រូង និងរាប់ចង្វាក់ដង្ហើម ។
- ពិនិត្យមើលពណ៌នៃបបូរមាត់និងចុងម្រាមដៃថាមានស្វាយ ឬ ទេ ។ ការឡើង**ពណ៌ស្វាយ** នៅបបូរមាត់បញ្ជាក់ ថាមាន**កង្វះអុកស៊ីសែន**ធ្ងន់ធ្ងរ ។

### ១-២-២. ផលវិបាកនៃស្ថានភាពសង្គ្រោះបន្ទាន់

- ពិបាកដកដង្ហើម ដកដង្ហើមខ្លីហើយ**ញាប់** (**ច្រើនជាង ៣០ដងក្នុងមួយនាទី**) សម្បុរឡើងពណ៌ស្វាយ (ស្បែក ឬ បបូរមាត់) គឺរោគសញ្ញាទាំងនេះគឺជាសញ្ញានៃ**កង្វះអុកស៊ីសែននៅក្នុងឈាម ។**
- ស្ទុកគឺជាមូលហេតុមួយដែលធ្វើឱ្យខ្វះអុកស៊ីសែនក្នុងឈាម ។

- វាអាចបណ្តាលមកពីការដកដង្ហើមមិនគ្រប់គ្រាន់ដោយសារជំងឺផ្លូវដង្ហើម ឬ បេះដូងដូចជាជំងឺរលាកសួត ហើតការហើមសួតស្រួចស្រាវ ការស្ទះផ្លូវដង្ហើម ឬ ខ្សោយបេះដូង ។

## ១-២-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

- ប្រសិនបើមានរោគសញ្ញាដូចខាងលើ ត្រូវធ្វើការការព្យាបាលភ្លាមតាមតម្រូវការនៃជំងឺ ។ អ្វីដែលអាចធ្វើបាននៅថ្នាក់មណ្ឌលសុខភាពគឺការផ្តល់**អុកស៊ីសែន ៤-៦លីត្រក្នុងមួយនាទី ដោយម៉ាស ឬ Cannulae** [៥] ( ប្រសិនបើមាន ) ។ ប្រសិនបើមានអ្វីស្ទះផ្លូវខ្យល់ ( ឧទាហរណ៍ការក្អួត ) សូមយកវាចេញ ។
- ប្រសិនបើស្ត្រីមិនដកដង្ហើមដាក់ស្ត្រីក្នុងស្ថានភាពអង្គុយ និងចាប់ផ្តើមជំនួយការដកដង្ហើម ដោយប្រើម៉ាស និងបាឡុង ។

## ១-៣. សញ្ញាស្ទុក

《**សង្ខេប**》

- ស្ទុកគឺជាការចុះខ្សោយនៃប្រព័ន្ធឈាមរត់ក្នុងការរក្សាលំហូរឈាមគ្រប់គ្រាន់នៅក្នុងរាងកាយ។ វាអាចបណ្តាលឱ្យម្តាយនិងទារកស្លាប់បានប្រសិនបើទុកដោយគ្មានការព្យាបាល ។
- ប្រសិនបើស្ត្រីសន្លប់ ឬ មិនឆ្លើយតបបានល្អប្រសើរត្រូវពិនិត្យសញ្ញាស្ទុក៖ សម្ពាធឈាមទាប (សម្ពាធឈាមអតិបរមាតិចជាង ៩០មមបារត) ជីពចរខ្សោយ បែកញើសស្អិត ស្វាយនៅបាតដៃ ឬ បបូរមាត់ និងដង្ហើមញាប់ ។
- ប្រសិនបើស្ទុករួមជាមួយការធ្លាក់ឈាមធ្ងន់ធ្ងរ ឬ ការឈឺពោះខ្លាំងមិនធម្មតាវាជាស្ទុក ដោយសារបរិមាណឈាមចុះទាប (Hypovolemic shock) ។
- ប្រសិនបើស្ទុកមានគ្រុនក្តៅវាជាស្ទុកដោយសារការក្លាយរោគ (Septic shock) ។
- ចាក់បញ្ចូលសេរ៉ូមសរសៃវ៉ែនភ្លាមមុនពេលបញ្ជូន ។

### ១-៣-១. និយមន័យស្ទុក

#### ១-៣-១-១. និយមន័យ

- ស្ទុកគឺជា**ការចុះខ្សោយនៃប្រព័ន្ធឈាមរត់**ក្នុងការរក្សាលំហូរឈាមគ្រប់គ្រាន់នៅក្នុងរាងកាយ ។ វាអាចបណ្តាលឱ្យម្តាយនិងទារកស្លាប់បានប្រសិនបើទុកដោយគ្មានការព្យាបាល ។

#### ១-៣-១-២. សញ្ញាស្ទុក

- លក្ខណៈសំខាន់នៃស្ទុកគឺសម្ពាធឈាមចុះទាប ។ រោគវិនិច្ឆ័យគេអាចកំណត់បាននៅពេល **សម្ពាធឈាម អតិបរមាតិចជាង ៩០មមបារត ។**
- រោគសញ្ញាជាច្រើនផ្សេងទៀតមាន៖
    - ជីពចរខ្សោយ និង/ឬញាប់ (លើសពី ១០០ដង/១នាទី)
    - បែកញើសត្រជាក់ និងស្បែកស្អិត
    - ពណ៌ឡើងស្វាយ (បាតដៃ ឬបបូរមាត់)
    - ដកដង្ហើមញាប់
    - ចំណុះទឹកនោមតិច

## ១-៣-២. ពិនិត្យចរន្តឈាមរត់ និងសញ្ញាស្តុក

### ១-៣-២-១.សម្ពាធឈាម

- វាអាចពិបាកវាស់ម្ពាធឈាមតាមវិធីស្តង់ដារ (ដោយប្រដាប់វាស់សម្ពាធឈាម និង ស្តេតូស្កុប) ក្នុងករណីស្តុក ។
- **ការរាប់ជីពចរដោយការស្ទាបជីពចរកដៃ** (**អាទែរ៉ាដ្យាល់**) ត្រូវបានគេផ្តល់អនុសាសន៍ឱ្យធ្វើ ។
- ដូចដែលបានបញ្ជាក់នៅក្នុងនិយមន័យខាងលើ**សម្ពាធឈាមអតិបរមាតិចជាង ៩0mmHg** បង្ហាញថាមាន**ស្តុក ។** ការរាប់ជីពចរគួរត្រូវបានធ្វើឡើងក្នុងពេលតែមួយ ។

### ១-៣-២-២. ជីពចរ

**ចង្វាក់បេះដូងលោតញាប់** (**Tachycardia**) (**ជីពចរលើសពី ១០០ ដងក្នុងមួយនាទី**) អាចជាសញ្ញា មួយនៃស្តុក ។ ការគណនាស្តុក '**Shock Index (SI)**' មានសារៈប្រយោជន៍ណាស់ព្រោះជាសូចនាករ ក្នុងការវាយតម្លៃកម្រិតនៃស្តុក ។

Shock Index (SI) មានរូបមន្តដូចខាងក្រោម៖

$$\textbf{SI} = \frac{\textbf{ជីពចរ}}{\textbf{សម្ពាធឈាមអតិបរមា (ស៊ីស្តូលិក)}}$$

ការវាយតម្លៃ SI គឺត្រូវបានបង្ហាញតាមតារាងដូចខាងក្រោម៖

| **SI** | **ការវាយតម្លៃ** |
|---|---|
| **ច្រើនជាង១,0** | **ស្តុកកម្រិតស្រាល** |
| **ច្រើនជាង១,៥** | **ស្តុកកម្រិតមធ្យម** |
| **ច្រើនជាង២,0** | **ស្តុកកម្រិតធ្ងន់ធ្ងរ** |

ឧទាហរណ៍៖ SI គឺ ១,១ ប្រសិនបើជីពចរ ១០០ដង/ ១នាទីហើយសម្ពាធឈាមអតិបរមា ៩0មមបារត ដែលបញ្ជាក់ថាជាស្តុកកម្រិតស្រាល ។

SI គឺ ១,៥ ប្រសិនបើជីពចរ ១២០ដង/១នាទីហើយសម្ពាធឈាមអតិបរមា ៨0មមបារត ដែលបញ្ជាក់ ថាជាស្តុកកម្រិតមធ្យម ។

SI គឺ ២,០ ប្រសិនបើជីពចរ ១៤០ដង/ ១នាទីហើយសម្ពាធឈាមអតិបរមា ៧០មមបារត ដែលបញ្ជាក់ ថាជាស្ហុកកម្រិតធ្ងន់ធ្ងរ ។

SI ១ = ជីពចរ ១០០ដង/១នាទី / ៩០មមបារត = ១,១ = **ស្ហុកកម្រិតស្រាល**

SI ២ = ជីពចរ ១២០ដង/១នាទី / ៨០មមបារត = ១,៥ = **ស្ហុកកម្រិតមធ្យម**

SI ៣ = ជីពចរ ១៤០ដង/១នាទី / ៧០មមបារត = ២,០ = **ស្ហុកកម្រិតធ្ងន់ធ្ងរ**

**សម្គាល់៖**

យោងទៅតាម *ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព* ក្នុងប្រទេសកម្ពុជាលក្ខណៈវិនិច្ឆ័យស្ហុក គឺបញ្ជាក់ដោយសម្ពាធឈាមអតិបរមាតិចជាង ៩០មមបារត និងជីពចរលើសពី ១១០ដងក្នុងមួយនាទី ។ ទោះជាយ៉ាងនេះក្តីដូចដែលបានបង្ហាញខាងលើលក្ខណៈវិនិច្ឆ័យនេះគឺបញ្ជាក់ អំពីស្ហុកកម្រិតស្រាល។ ការវាយតម្លៃ ជីពចរជាមួយនឹងសម្ពាធឈាមអតិបរមាគឺត្រូវបានគេផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ជានិច្ចកាល ។

## ១-៣-៣. មូលហេតុនៃស្ហុក

ស្ហុកអាចបណ្តាលមកពី៖ (១) បរិមាណឈាមធ្លាក់ចុះទាប (Hypovolemic shock)(២) ការរីកមាឧសរសៃឈាមហួសប្រមាណ (Distributive shock)(៣) សកម្មភាពច្របាច់របស់បេះដូងមិនគ្រប់ គ្រាន់ (Cardiogenic shock) ។

### ១-៣-៣-១. ស្ហុកដោយសារបរិមាណឈាមចុះទាប (Hypovolemic shock)

- នៅពេលដែលបរិមាណឈាមបាត់បង់ភ្លាមៗធ្វើឱ្យបេះដូងមិនអាចច្របាច់ឈាមបញ្ជូនទៅរាងកាយបានគ្រប់គ្រាន់ ។ ការថយចុះបរិមាណឈាមបណ្តាលឱ្យមានស្ហុកដែលគេហៅ ថាស្ហុក **ដោយសារបរិមាណឈាមចុះទាប ។**

- ចំពោះស្ត្រីមានផ្ទៃពោះមូលហេតុចំបងនៃស្តុកដោយសារបរិមាណឈាមចុះទាបគឺការ**ធ្លាក់ឈាមខ្លាំង ។**
- ពិនិត្យរកមើលការធ្លាក់ឈាមចេញមកខាងក្រៅ ព្រមទាំងមានការឈឺពោះសម្រាលមិនប្រក្រតី ដោយសារ**សុករបើកមុនសម្រាល** ឬ **រហែកស្បូន** ដែលនាំឱ្យមានការហូរឈាមនៅខាងក្នុងស្បូន ឬក្នុងពោះ ។
- ក្នុងករណីស្តុកដោយសារបរិមាណឈាមចុះទាប សញ្ញាជីពចរញាប់គឺដើម្បីរក្សាចរន្តឈាម ទៅចិញ្ចឹមកោសិការឱ្យបានគ្រប់គ្រាន់ ។ ពេលដែលចំនួនជីពចរក្នុងមួយនាទីស្មើ ឬ ច្រើនជាងចំនួនសម្ពាធឈាមអតិបរមា (ស៊ីស្តូលិក) បង្ហាញថាមានការបាត់បង់ឈាមដែលគួរឱ្យកត់សម្គាល់ ។

**១-៣-៣-២. ស្តុកដោយសារការរីកសរសៃឈាមហួសប្រមាណ (Distributive sock)**

- ការរីកសរសៃឈាមហួសប្រមាណធ្វើឱ្យសម្ពាធឈាមធ្លាក់ចុះដែលនាំ ឱ្យកាត់បន្ថយលំហូរឈាម និងការដឹកជញ្ជូនអុកស៊ីសែនដល់សរីរាង្គ ។
- ការរីកសរសៃឈាមហួសប្រមាណបង្កឡើងដោយ**ប្រតិកម្មធ្ងន់ធ្ងរ** (**អាឡែកហ្ស៊ី**) (ដែលត្រូវបានគេហៅថា **Anaphylactic shock**), **ការបង្ករោគដោយបាក់តេរីធ្ងន់ធ្ងរ** (ដែលត្រូវបានគេហៅថា **Septic shock**) ឬ ហេតុផលផ្សេងទៀត ដូចជាការប្រើប្រាស់ថ្នាំ ឬ បញ្ហាប្រព័ន្ធប្រសាទ (Neurogenic) ។
- ក្នុងករណីដែលមាន**ស្តុកសិបទិក**ភាគច្រើនមាន**គ្រុនក្តៅខ្លាំង** (**លើសពី ៣៨ °C**) ហើយចុងដៃក្តៅឧណ្ហៗ នៅក្នុងដំណាក់កាលដំបូងនៃស្តុកសិបទិក ។

**១-៣-៣-៣.ស្តុកដោយសកម្មភាពច្របាច់របស់បេះដូងមិនគ្រប់គ្រាន់ (Cardiogenic shock)**

- សកម្មភាពច្របាច់របស់បេះដូងមិនបានគ្រប់គ្រាន់អាចធ្វើឱ្យបរិមាណឈាម ដែលច្របាច់បញ្ជូនចេញទៅចិញ្ចឹមកោសិកាមិនគ្រប់គ្រាន់រៀងរាល់ពេលបេះដូងលោតហៅ ថាស្តុក ដោយសារ**សកម្មភាពច្របាច់របស់ បេះដូងមិនគ្រប់គ្រាន់ ។**
- វាអាចបណ្តាលមកពីជំងឺបេះដូង ឬ មានដុំកំណកឈាមនៅក្នុងសួត ។

## ១-៣-៤. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

(យោងតាម *ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព*[១] ទំព័រទី១៤)

- នៅពេលដែលឃើញមានសញ្ញាណាមួយនៃស្តុក ត្រូវបញ្ចូលសេរ៉ូមឱ្យបានលឿនតាមសរសៃឈាមដោយម្ជុលជំរលេខ ១៦G ឬ ១៨G (**សេរ៉ូម Ringer's Lactate ឬ Normal Saline**) ។
- នៅពេលដែលស្ត្រីមានការធ្លាក់ឈាម ត្រូវដាក់ស្ថានភាពស្ត្រីគេងផ្អៀងឆ្វេង ដោយឱ្យជើងខ្ពស់ជាងទ្រូងនិងរក្សាកម្តៅរាងកាយ ។

## ១-៤. សញ្ញាជីវិតមិនធម្មតា-ការលើសសម្ពាធឈាមអប្បបរមា

《**សង្ខេប**》
- សម្ពាធឈាមអប្បបរមាខ្ពស់ (លើសឬស្មើ ៩០មមបារត) គឺជាសញ្ញាសំខាន់នៃជំងឺបម្រុងក្រឡាភ្លើង ។
- សម្ពាធឈាមអប្បបរមាខ្ពស់ (លើសឬស្មើ ១១០មមបារត) គឺបង្ហាញថាមានជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ដែលត្រូវការការព្យាបាលនិងបញ្ជូនភ្លាម ។

### ១-៤-១. និយមន័យជំងឺបម្រុងក្រឡាភ្លើង

(យោងតាម *ពិធីសារជាតិគ្រប់គ្រងគ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព* ទំព័រទី២៤, ៦. *សង្កេតស្ថានភាពមាតា* ៦-១ សម្ពាធឈាម ទំព័រ៩៥)

- **សម្ពាធឈាមអប្បបរមាខ្ពស់** គឺមាននិយមន័យថា **៩០មមបារត ឬ លើស ។**
- ប្រសិនបើមានការលើសសម្ពាធឈាមដូចខាងលើ រួមជាមួយវត្តមាន**ប្រូតេអ៊ីនក្នុងទឹកនោម** នោះគឺជា **ជំងឺបម្រុងក្រឡាភ្លើង ។**
- ប្រសិនបើ**សម្ពាធឈាមអប្បបរមា ១១០មមបារត ឬ លើសរួមជាមួយវត្តមានប្រូតេអ៊ីនក្នុងទឹកនោម** នោះគឺជា**ជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ។**

**សម្គាល់៖** ដោយប្រើ**ប្រដាប់តេស្តទឹកនោម** ប្រសិនបើមានសម្ពាធឈាមខ្ពស់រួមជាមួយប្រូតេអ៊ីន ក្នុងទឹកនោម (++) គឺជា**ជំងឺបម្រុងក្រឡាភ្លើងកម្រិតស្រាល** ។ ប្រសិនបើសម្ពាធឈាមអប្បបរមា ១១០មមបារត ឬ លើសរួមមាន**ប្រូតេអ៊ីនក្នុងទឹកនោម** (**លើសពី**++) នោះវាជា**ជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ។**

### ១-៤-២. ផលវិបាកនៃស្ថានភាពមិនធម្មតា

- ជំងឺបម្រុងក្រឡាភ្លើងមានការប្រឈមទៅនឹងការវិវត្តទៅជាជំងឺក្រឡាភ្លើង ។
- ជាញឹកញាប់ជំងឺបម្រុងក្រឡាភ្លើងធ្វើឱ្យទារកក្នុងផ្ទៃមានការលូតលាស់យឺតជាងធម្មតាដែលអាចបណ្តាល ឱ្យ**ទារកខ្សោយ**ក្នុងអំឡុងពេលសម្រាល ។
- ដូច្នេះជាអនុសាសន៍ត្រូវធ្វើការបញ្ជូនភ្លាម ។

### ១-៤-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

- ក្នុងករណីបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ការផ្តល់**ម៉ាញ៉េស្យូមស៊ុលហ្វាត ($MgSO_4$)** គឺត្រូវបានគេផ្តល់អនុសាសន៍ខ្ពស់ឱ្យប្រើប្រាស់មុនពេលបញ្ជូន ។ វិធីនេះគឺត្រូវបានធ្វើដូចគ្នាទៅនឹងករណីជំងឺក្រឡាភ្លើង ។ ( មើល *១-១-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន* ទំព័រ៥ )

## ១-៥. សញ្ញាជីវិតមិនធម្មតា - គ្រុនក្ដៅ

《**សង្ខេប**》

- សីតុណ្ហភាពរាងកាយខ្ពស់ (លើសឬស្មើ៣៨.០ºC) បង្ហាញថាមានការបង្ករោគធ្ងន់ធ្ងរ ។ វាអាចបញ្ជាក់ពី មេរោគនៅក្នុងឈាម (Sepsis) ។
- ប្រសិនបើសីតុណ្ហភាពរាងកាយខ្ពស់មានជាមួយការបែកស្រោមទឹកភ្លោះ នោះគឺសង្ស័យថាមានការបង្ករោគនៅក្នុងស្បូន ។
- តាមអនុសាសន៍ត្រូវផ្ដល់ការព្យាបាលភ្លាមៗ ដោយការចាក់សេរ៉ូមមុនបញ្ជូន ប្រសិនបើសង្ស័យថាមានការបង្ករោគដោយបាក់តេរី ។

### ១-៥-១. និយមន័យគ្រុនក្ដៅ

- គ្រុនក្ដៅបញ្ជាក់ពីសញ្ញាមិនធម្មតានៃរាងកាយ ។
- ប្រសិនបើ**សីតុណ្ហភាពរាងកាយលើសពី ៣៨.០ºC** ដែលអាចជាការ**បង្ករោគដោយបាក់តេរី** ។

### ១-៥-២. ផលវិបាកនៃស្ថានភាពមិនធម្មតា

(មើល *៦. សង្កេតស្ថានភាពម្ដាយ* ទំព័រ៩៤, *៦-៤. សីតុណ្ហភាពរាងកាយ* ទំព័រ១០១)

- ការបង្ករោគដោយបាក់តេរីធ្ងន់ធ្ងរក្នុងពេលមានផ្ទៃពោះ ឬ ពេលឈឺពោះសម្រាលច្រើនជា**ការបង្ករោគក្នុងស្បូន** ។ វាអាចធ្វើឱ្យប៉ះពាល់ទៅដល់សុខភាពរបស់ទារកក្នុងផ្ទៃផងដែរ ។
- **មេរោគក្នុងឈាម(Sepsis)**គឺជាមូលហេតុចំបងដែលបណ្ដាលឱ្យម្ដាយនិងទារកស្លាប់ ។

### ១-៥-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

- ការបញ្ជាក់ពីមូលហេតុសមស្របនៃការបញ្ជូនគឺការចាំបាច់ ។
- បញ្ចូលសេរ៉ូមតាមសរសៃ និងលើកទឹកចិត្តឱ្យពិសារទឹកឱ្យបានច្រើន[១] ។
- ពិនិត្យសញ្ញានៃការបង្ករោគផ្សេងទៀត ហើយផ្ដល់ថ្នាំអង់ទីប៊ីយ៉ូទិក (Antibiotics) មុនធ្វើការបញ្ជូន[១] ។

| រោគសញ្ញា | អង់ទីប៊ីយ៉ូទិក | ផ្លូវចាក់ថ្នាំ | កម្រិត |
|---|---|---|---|
| បែកទឹកភ្លោះនិងកម្តៅលើសពី ៣៨°C ឬធ្លាក់ទឹករំអិលមានក្លិនស្អុយ | អំពីស៊ីលីន | សរសៃ/សាច់ដុំ | ២ក្រាម |
| | (**បូក**) ហ្សង់តាមីស៊ីន | សាច់ដុំ | ៨០មីលីក្រាម |
| | (**បូក**) មេត្រូនីដាហ្សូល | សរសៃ | ៥០០មីលីក្រាម |
| បែកទឹកភ្លោះលើសពី ១៨ ម៉ោង | អំពីស៊ីលីន | សរសៃ/សាច់ដុំ | ១ក្រាម |
| | (**បូក**) ហ្សង់តាមីស៊ីន | សាច់ដុំ | ៨០មីលីក្រាម |
| សញ្ញានៃការបង្ករោគតាមផ្លូវនោម: ក្រហាយពេលនោម ឈឺឬពិបាកនោម នោមញឹកនិងចង់នោមជាបន្ទាន់ ឈឺពោះផ្នែកខាងក្រោម | អំពីស៊ីលីន២ | គ្រាប់ | ៥០០មីលីក្រាម |
| | (**ឬ**) ទ្រីមេតូព្រីម/ស៊ុលហ្វាមេតូហ្សាហ្សូល២ | គ្រាប់ | ៨០/៤០០ មីលីក្រាម |

## ១-៦. សញ្ញាជីវិតមិនធម្មតា - ការធ្លាក់ឈាម

《**សង្ខេប**》
- ការធ្លាក់ឈាមច្រើនមុនពេល ឬ អំឡុងពេលឈឺពោះសម្រាលបង្ហាញថាមានភាពមិនធម្មតាធ្ងន់ធ្ងរ ។
- ពិនិត្យមើលសម្ពាធឈាម និងជីពចរឱ្យបានញឹកញាប់ប្រសិនបើមានការធ្លាក់ឈាមតាមទ្វារមាសមិនធម្មតា ។
- ផ្តល់ការព្យាបាលដូចដែលបានសរសេរនៅក្នុង 'ស្ពុក' មុនពេលបញ្ជូន។

### ១-៦-១. និយមន័យការធ្លាក់ឈាមតាមទ្វារមាសមិនធម្មតា

- ការពិពណ៌នាសមស្របនៃការធ្លាក់ឈាមជាការចាំបាច់ ។
- ការធ្លាក់ឈាមមិនធម្មតាគឺ**ជាការធ្លាក់ឈាមជោកសំឡីអនាម័យ ឬ ក្រណាត់ទ្រាប់ ឬ សើមជាប់ក្នុងរយៈពេលពីរឬបីនាទី ឬ មានការធ្លាក់ឈាមថ្មីៗ**នៅបន្តកើតមានជាបន្តបន្ទាប់តាមទ្វារមាស ។

### ១-៦-២. ផលវិបាកនៃការធ្លាក់ឈាមមិនធម្មតា

- ការធ្លាក់ឈាមអាចហូរចេញពីសុក ទងសុក ឬ ស្បូន ។ វាមានផលប៉ះពាល់ទៅលើលំហូរឈាមចិញ្ចឹមទារកក្នុងផ្ទៃ និងកោសិការរបស់ម្តាយ ។
- ប្រសិនបើលំហូរឈាមទៅសុក និងទងសុកមានការប៉ះពាល់ធ្ងន់ធ្ងរនោះគឺអាចបណ្តាលឱ្យកូនស្លាប់ក្នុងពោះ និងស្លាប់កើត ។
- មូលហេតុដែលសង្ស័យគឺការរបើកសុកមុនសម្រាល របែកស្បូន និងសុកពាំងមាត់ស្បូន (មើល *២. ស្លាប់ការត្អូញត្អែររបស់ស្ត្រី ២-១. ការធ្លាក់ឈាម* ទំព័រ២០ និង *៦. សង្កេតស្ថានភាពម្តាយ ៦-៦. ការធ្លាក់ឈាម* ទំព័រ១០៧)។

### ១-៦-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន

- មិនមានការព្យាបាលជាក់លាក់សម្រាប់ការធ្លាក់ឈាមតាមទ្វារមាសមុនពេល ឬ អំឡុងពេលឈឺពោះសម្រាល ដែលអាចធ្វើបាននៅថ្នាក់មណ្ឌលសុខភាពនោះទេ ។
- ដូច្នេះគឺចាំបាច់ផ្តល់ការព្យាបាលដូចដែលបានសរសេរនៅក្នុង'ស្ពុក' ។ (មើល *១-៣-៤. ការព្យាបាលចាំបាច់មុនពេលបញ្ជូន* ទំព័រ១២)
- បន្តតាមដានសញ្ញាជីវិត គឺជាតម្រូវការចាំបាច់បំផុត ។

## ១-៧. ការបង្ហាញមិនធម្មតា

នៅពេលរកឃើញការបង្ហាញមិនធម្មតារបស់ទារក ( ទម្រង់ហុចថ្ងាស, ហុចបង្ហើយធំ, ហុចមុខ, កូនទទឹងពោះ កូនបញ្ឆិតពោះ, កូនធ្លាក់ដៃ, កូនបញ្ច្រាស់, បង្ហាញដៃទូលក្បាល, ធ្លាក់ទងសុកមកមុន ) ត្រូវរៀបចំបញ្ជូនស្ត្រីភ្លាម ។

**<សណ្ឋាននិងទម្រង់បង្ហាញរបស់ទារក>**



# ជំពូកទី២ ស្តាប់ការត្អូញត្អែររបស់ស្ត្រី

**សង្ខេប**

- វត្ថុបំណងនៅក្នុងជំពូកនេះគឺ (១)កំណត់សញ្ញា/បណ្តុំរោគសញ្ញាអាទិភាពរបស់ម្តាយ និង (២)ស្តាប់ការត្អូញត្អែររបស់គាត់ដើម្បីឱ្យគាត់មានអារម្មណ៍ផាសុកភាពនិងភាពកក់ក្តៅ ។
- វាចាំបាច់ក្នុងការស្តាប់ការត្អូញត្អែររបស់ស្ត្រី( ព័ត៌មានដែលមិនអាចសង្កេតឃើញនឹងភ្នែកទទេរ) ដំបូងគេ ។ បន្ទាប់មកស្តាប់ការពន្យល់របស់ស្ត្រី មើលស្ថានភាពស្ត្រី និងទារកនូវអ្វីដែលរកអាចឃើញតាមរយៈ ការសង្កេតនិងពិនិត្យបាន ។
- បញ្ជាក់មើលភាពមិនធម្មតានៃការវិវត្តនៃការឈឺពោះសម្រាលរបស់ស្ត្រី។
- ‘ការធ្លាក់ឈាម’, ‘ការបែកស្រោមទឹកភ្លោះ’, និង ‘ការឈឺពោះសម្រាលនិងស្បូនកន្ត្រាក់’ ‘ចលនារបស់ទារក’ គួរត្រូវបានពិនិត្យនៅពេលសម្ភាសន៍ (សួរ) ស្ត្រី។

## ២-១. ការធ្លាក់ឈាម

《**សង្ខេប**》

- ‘ការធ្លាក់ឈាម’ជាធម្មតាត្រូវបានគេសង្កេតក្នុងអំឡុងពេលវិវត្តន៍នៃការឈឺពោះសម្រាលធម្មតា ។
- ទោះជាយ៉ាងនេះក្តី ប្រសិនបើបរិមាណ**ឈាមធ្លាក់លើសកម្រិត ‘ធម្មតា’** នោះវាអាចជាសញ្ញានៃផលវិបាក មួយចំនួន ។
- ពិនិត្យមើលសញ្ញាផ្សេងទៀតនៃការធ្លាក់ឈាម (ការឈឺចាប់មិនធម្មតា ឈឺពេលប៉ះ -ល-) ។
- សួរស្រ្តីថាតើមានធ្លាក់ឈាមតាមទ្វារមាសឬទេ មុននឹងធ្វើការលូកពិនិត្យទ្វារមាសស្រ្តី ។
- នៅពេលដែលស្រ្តីធ្លាក់ឈាមច្រើនជាងធម្មតាជាមួយនឹងការឈឺពេលសម្រាលមិនធម្មតានោះគឺសង្ស័យថាមាន**សុករបើកមុនសម្រាល** ឬ **រហែកស្បូន** ។

### ២-១-១. ផលវិបាកដោយសារការធ្លាក់ឈាមមិនធម្មតា

(មើល *៦. សង្កេតមើលស្ថានភាពម្តាយ ៦-៦. ការធ្លាក់ឈាម*, ទំព័រ១០៧)

**២-១-១-១. សំឡីអនាម័យ ឬ ក្រណាត់សើមជោកក្នុងរយៈពេលតិចជាង ៥ នាទី**

- **មូលហេតុចំបងបីនៃការធ្លាក់ឈាមមានដូចខាងក្រោម៖**

(១) **សុកពាំងមាត់ស្បូន** គឺជាស្ថានភាពមួយដែលសុកមានទីតាំងនៅផ្នែកខាងក្រោមនៃស្បូន ហើយសុកអាចពាំងផ្នែកខ្លះនៃមាត់ស្បូន ឬ នៅចំមាត់ស្បូន ។ ដោយសារតែសុករបេះ ចេញពីកន្លែងតាំងនៅការធ្លាក់ឈាមធ្ងន់ធ្ងរអាចកើតឡើងនៅពេលមាត់ស្បូនចាប់ផ្តើមបើក ។ ជាធម្មតាស្រ្តីមិនបានត្អូញត្អែរ ពីការឈឺចាប់ ធ្ងន់ធ្ងរទេ ។

(២) **ការរបើកសុកមុនសម្រាល** គឺជាការបើកពីទីតាំងធម្មតារបស់សុកចេញពីស្បូនមុនសម្រាល ។ ឈាមធ្លាក់ចេញពីស្បូនមកក្រៅតាមទ្វារមាស ឬ លាយជាមួយទឹកភ្លោះ ហើយពេលខ្លះមានឈាមដក់នៅក្នុងស្បូន ។ ស្រ្តីជាញឹកញាប់មានការឈឺពោះខ្លាំង ឬឈឺពោះពេលប៉ះហើយស្បូនមានសភាពរឹង ។ (មើល *២.ស្តាប់ស្រ្តីត្អូញត្អែរ, ២-3 ស្បូនកន្ត្រាក់ និងការឈឺពោះពេលសម្រាល,* ទំព័រ២៥) ។

(៣) **ការរហែកស្បូន** គឺជាការរហែកជញ្ជាំងស្បូននៅទីតាំងមានស្នាមវះកាត់ពីមុន ។ ស្ត្រីត្អូញត្អែរថាមានការឈឺពោះខ្លាំង។(មើល *២. ស្តាប់ស្ត្រីត្អូញត្អែរ, ២-៣ ស្បូនកន្ត្រាក់និង ការឈឺពោះពេលសម្រាល*, ទំព័រ២៥) ។

| |
|---|
| **សម្គាល់៖** កុំលូកពិនិត្យទ្វារមាសប្រសិនបើមានការធ្លាក់ឈាមធ្ងន់ធ្ងរ (សំឡីអនាម័យ ឬក្រណាត់សើមជោក ក្នុងរយៈពេលខ្លីប្រហែលជាង៥នាទី) ព្រោះវាប្រហែលមកពីសុកពាំងមាត់ស្បូន ហើយការពិនិត្យទ្វារមាស អាចនឹងធ្វើឱ្យមានការធ្លាក់ឈាមកាន់តែធ្ងន់ធ្ងរ ។ |

## ២-២. ជ្រាបទឹកភ្លោះតាមទ្វារមាស

《សង្ខេប》
- ការបែកស្រោមទឹកភ្លោះជានិច្ចជាកាល គឺអាចកើតមាននៅពេលណាមួយនៅក្នុងការវិវត្តនៃការឈឺពោះសម្រាល ។
- ប្រសិនបើស្ត្រីមានអារម្មណ៍ថា 'សើម' ឬ 'ជ្រាបទឹកក្តៅឧណ្ហៗ' នោះជាសញ្ញានៃ 'ការបែកស្រោមទឹកភ្លោះ' ។
- បញ្ជាក់ការបែកស្រោមទឹកភ្លោះដោយការពិនិត្យមើលការជ្រាបទឹកចេញជាបន្តបន្ទាប់តាមទ្វារមាស ឬការប៉ះស្រោមទឹកភ្លោះ ឬ ក្បាលកូន (សក់) ពេលលូកពិនិត្យទ្វារមាស ។
- សួរម្តាយនៅពេលដែលគាត់មានអារម្មណ៍ថាមានបែកស្រោមទឹកភ្លោះ ។ កត់ត្រាពីពេលវេលា និងគណនារយៈពេលបន្ទាប់ពីបែកស្រោមទឹកភ្លោះ ។
- ផលវិបាកមួយចំនួន (ការបង្ករោគក្នុងស្បូន ទារកខ្សោយដោយសារបរិមាណទឹកភ្លោះតិច ការលូនចេញទងសុកមុនសម្រាល) អាចកើតមានឡើងពិសេសនៅក្នុងករណីបែកស្រោមទឹកភ្លោះមុនសម្រាល (PROM) ឬ រយៈពេលនៃការបែកស្រោមទឹកភ្លោះយូរ ។

### ២-២-១. និយមន័យនៃការបែកស្រោមទឹកភ្លោះ

- ទារកក្នុងស្បូនព័ទ្ធជុំវិញដោយទឹកភ្លោះដែលត្រូវបានរក្សាដោយ '**ស្រោមទឹកភ្លោះ**' ។
- ការបែកស្រោមទឹកភ្លោះ កើតមានក្នុងពេលណាមួយនៃការវិវត្តន៍នៃការឈឺពោះសម្រាលហើយ អាចដឹងបាន ដោយជ្រាបចេញនូវទឹកភ្លោះតាមទ្វារមាស ។ ការបែកស្រោមទឹកភ្លោះអាចបែក ត្រង់ផ្នែកខាងមុខ ឬ ខាងក្នុងនៃស្រោមទឹកភ្លោះ ។
- នៅពេលដែលផ្នែកខាងក្នុងនៃស្រោមទឹកភ្លោះបែកទឹកភ្លោះអាចមិនជ្រាបចេញច្រើនទេ ខណៈពេលដែលផ្នែកខាងមុខនៃស្រោមទឹកភ្លោះនៅតែមិនទាន់បែក ។

### ២-២-២. មធ្យោបាយដើម្បីដឹងថាស្រោមទឹកភ្លោះបែក

(១) **មើល** ថាមានទឹកជ្រាបតាមទ្វារមាសជាបន្តបន្ទាប់ ឬ ពិនិត្យមើល ដោយប្រើ Speculum (ប្រសិនបើមាន) ។

(២) **ស្ទាប**តើមានប៉ះស្រោមទឹកភ្លោះដែលមិនទាន់បែក ឬ ក៏ក្បាលកូន (សក់) តាមរយៈការលូកពិនិត្យទ្វារមាស ឬ ទេ ។

(៣) ប្រសិនបើមិនប្រាកដថាមានការជ្រាបទឹកភ្លោះ ឬ ស្រោមទឹកភ្លោះមិនទាន់បែក **សូមសង្កេត**ថាតើស្ត្រីនៅបន្តមានអារម្មណ៍ថាមានជ្រាបទឹកភ្លោះនៅពេលធ្វើចលនាឬទេ ។ ដាក់សំឡីអនាម័យ ឬ ក្រណាត់ហើយរង់ចាំនៅរយៈពេលខ្លីមួយ ។ ប្រសិនបើសំឡី ឬ ក្រណាត់នោះសើមវាអាចនឹងមានការបែកស្រោមទឹកភ្លោះ ។

**<ប្រសិនបើស្រោមទឹកភ្លោះបែក>**

(១) **ស្ទាប** រកការលូនចេញនៃទងសុកមុនទារកសម្រាល ដោយការលូកពិនិត្យទ្វារមាស និងស្តាប់ចង្វាក់បេះដូងទារក (FHR) ។

(២) **ពិនិត្យ** មើលស្ថានភាពទឹកភ្លោះ (មើល *៤. សង្កេតមើលស្ថានភាពទារក ៤-២-២.ទឹកភ្លោះ* ទំព័រ ៧៥) សីតុណ្ហភាពរាងកាយ និងសញ្ញានៃការបង្ករោគ ។

(៣) **សួរ** ស្ត្រីពីពេលដែលគាត់មានអារម្មណ៍ថាស្រោមទឹកភ្លោះបែក ។ កត់ត្រាពេលវេលា និងគណនារយៈពេលបន្ទាប់ពីបែកស្រោមទឹកភ្លោះ ។

## ២-២-៣. ផលវិបាកដោយសារការបែកស្រោមទឹកភ្លោះ

- ផលវិបាកមួយចំនួនអាចកើតមានបន្ទាប់ពីស្រោមទឹកភ្លោះបែក ។
- ស្រោមទឹកភ្លោះដើរតួនាទីជួយការពារទារក និងបែងចែកទារកជាមួយនឹងមជ្ឈដ្ឋានក្រៅ ។ នៅពេលដែលស្រោមទឹកភ្លោះបែក មានន័យថាមានការភ្ជាប់គ្នារវាងមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅស្បូន ។ ការភ្ជាប់ នេះអាចបណ្តាលឱ្យមាន **ការបង្ករោគនៅខាងក្នុងស្បូន ។**
- បន្ទាប់ពីស្រោមទឹកភ្លោះបែក ទឹកភ្លោះនៅបន្តជ្រាបចេញ ។ ការថយចុះនៃទឹកភ្លោះអាចបណ្តាលឱ្យមាន **ការសង្កត់លើទងសុក**ក្នុងអំឡុងពេលស្បូនកន្ត្រាក់ ដែលអាចបណ្តាលឱ្យទារកខ្សោយ ។
- ប្រសិនបើក្បាលកូនមិនសមស្របនឹងអាងត្រគាកទេ នោះការលូនចេញនៃទងសុកមុនទារកសម្រាលអាចនឹងកើតមាន ។

### ២-២-៣-១. ការបែកស្រោមទឹកភ្លោះមុនឈឺពោះសម្រាល (PROM)

- ពេលវេលាល្អបំផុតនៃការបែកស្រោមទឹកភ្លោះគឺ នៅរយៈសកម្មក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ នៃការឈឺពោះសម្រាល ។

- តែពេលខ្លះ**ស្រោមទឹកភ្លោះអាចបែកមុនពេលឈឺពោះសម្រាល** ដែលត្រូវបានហៅថា**ការបែក ស្រោមទឹកភ្លោះមុនឈឺពោះសម្រាល (PROM)** ។
- ជាញឹកញាប់ក្បាលរបស់ទារកមិនទាន់ចុះចូលច្រកលើនៃអាងត្រគាកម្តាយទេ មុនពេលចាប់ផ្តើមឈឺពោះសម្រាល ។ ដូច្នេះវាអាចមានការប្រឈមដូចជាការ**ថយចុះបរិមាណទឹកភ្លោះ** និង**ការលូនចេញនៃ ទងសុកទារកមុនសម្រាល** ជាហេតុបណ្តាលឱ្យ**ទារកខ្សោយ ។**
- ការប្រឈមមុខនឹង**ការបង្ករោគក្នុងស្បូន**មានការកើនឡើង នៅពេលដែលស្រោមទឹកភ្លោះបែកក្នុងរយៈពេលកាន់តែយូរ ។

**២-២-៣-២. ការបែកស្រោមទឹកភ្លោះលើសពី ១៨ ម៉ោង**

- នៅពេលដែលស្រោមទឹកភ្លោះបែកលើសពី ១៨ ម៉ោង ការប្រឈមមុខនឹង**ការបង្ករោគ ដោយបាក់តេរី**ទៅលើទារកមានការកើនឡើង ។ សូមបញ្ជូនស្ត្រីទៅមន្ទីរពេទ្យដែលមានការគ្រប់គ្រងព្យាបាលសមស្រប ដើម្បីការពារការបង្ករោគទារកក្នុងផ្ទៃ ។
- ផ្តល់**អង់ទីប៊ីយូទិក** (អំពីស៊ីលីន ១ ក្រាមចាក់តាមសរសៃឬសាច់ដុំ និងហ្សង់តាមីស៊ីន. ៨០មីលីក្រាមចាក់សាច់ដុំ)មុនពេលបញ្ជូន ។
  (ពិនិត្យឯកសារយោង *ពិធីសារជាតិគ្រប់គ្រងគ្លីនិក មាតុភាពគ្មាន គ្រោះថ្នាក់ សម្រាប់មណ្ឌលសុខភាពទំព័រទី ៤១* និង *ការឆ្លើយតបភ្លាមៗទៅនឹងការសង្គ្រោះបន្ទាន់ សម្រាប់ស្ត្រី មានផ្ទៃពោះ ១-៥-៣. ការព្យាបាលចាំបាច់មុនពេលបញ្ជូន* ទំព័រ១៥) ។

## ២-៣. ស្បូនកន្ត្រាក់ និងការឈឺពោះសម្រាល

《សង្ខេប》

- ការកន្ត្រាក់ស្បូនក្នុងអំឡុងពេលឈឺពោះសម្រាលមានសារៈសំខាន់ណាស់សម្រាប់ការសម្រាលទារក ពីព្រោះវាជម្រុញឱ្យមាត់ស្បូនបើក និងរុញទារកចេញពីក្នុងស្បូន ។
- នៅពេលដែលស្ត្រីត្អូញត្អែរពីការកន្ត្រាក់ស្បូន ដំបូងត្រូវពិនិត្យមើលថាតើជាការកន្ត្រាក់ស្បូន ឈឺពោះសម្រាល ‘ពិតប្រាកដ’ ឬ ‘មិនពិតប្រាកដ’ ។
- លក្ខណៈស្បូនកន្ត្រាក់នៃការឈឺពោះសម្រាលគឺជាការកន្ត្រាក់ទៀងទាត់ និងមានចន្លោះពេល សម្រាករបស់វា ។
- នៅពេលដែលការកន្ត្រាក់ស្បូនជាការឈឺពោះសម្រាលពិតប្រាកដ សូមបញ្ជាក់ពីពេលវេលាចាប់ផ្តើមនៃការកន្ត្រាក់ស្បូនទៀងទាត់នោះ ហើយកត់ត្រា ។
- ការធ្វើរោគវិនិច្ឆ័យការឈឺពោះសម្រាលមានសារៈសំខាន់ណាស់ក្នុងការប៉ាន់ប្រមាណពេលវេលានៅក្នុងរយៈយឺត ។
- កត់សម្គាល់សញ្ញាឈឺពោះមានសភាពខ្លាំងពេក ឬ បន្តឈឺជាប់រហូតដោយគ្មានចន្លោះពេលសម្រាក ។ សញ្ញាទាំងនេះអាចជាសញ្ញានៃការឈឺពោះសម្រាលមិនធម្មតា ឬ មានផលវិបាក ។

### ២-៣-១. និយមន័យស្បូនកន្ត្រាក់ពេលឈឺពោះសម្រាល

- ស្បូនកន្ត្រាក់ គឺជា**ការកន្ត្រាក់**ដោយអរធន្ទៈនៃសាច់ដុំស្បូន ។ វាមានសារៈសំខាន់ណាស់ក្នុងការសម្រាលទារកពីព្រោះវាជម្រុញឱ្យមាត់ស្បូនបើកនិងរុញទារកឱ្យចេញពីស្បូន ។
- ការកន្ត្រាក់ស្បូនក្នុងអំឡុងពេលឈឺពោះសម្រាល ដែលត្រូវបានគេហៅថា ‘**ការឈឺពោះសម្រាល ពិត**’ នោះគឺជា**ការកន្ត្រាក់ស្បូនម្តងហើយម្តងទៀត ដោយមានចន្លោះពេលឈប់សម្រាកស្បូន ទៀងទាត់** (**សាច់ដុំស្បូនសម្រាក**)។ ភាគច្រើននៃការកន្ត្រាក់ស្បូនឈឺពោះសម្រាលគឺមានការឈឺចាប់។ ពេលចាប់ផ្តើមដំបូងស្បូនកន្ត្រាក់រយៈពេលខ្លីនិងមានចន្លោះពេលសម្រាកវែង។ បន្ទាប់មករយៈពេលនៃការកន្ត្រាក់វែងជាងមុន ហើយចន្លោះពេលនៃការសម្រាកខ្លីជាងមុនដែលបង្ហាញនៃការវិវត្តការឈឺពោះសម្រាល ។

### ២-៣-២. និយមន័យការឈឺពោះសម្រាល

- ការធ្វើរោគវិនិច្ឆ័យនៃ**ការចាប់ផ្ដើមឈឺពោះសម្រាល**មានសារៈសំខាន់ណាស់ក្នុងការប៉ាន់ប្រមាណរយៈពេលនៅក្នុងរយៈយឺត ។ ការចាប់ផ្ដើមឈឺពោះសម្រាលទារកគឺជា**ការចាប់ផ្ដើមនៃការកន្ត្រាក់ស្បូនទៀងទាត់**[៩] ។
- អ្នកត្រូវដឹងថាការ**ធ្លាក់ទឹករំអិលលាយឈាមតិចៗនិងការបើកមាត់ស្បូនមិនអាចកំណត់ការឈឺពោះសម្រាលបានទេ ។** ការធ្លាក់ទឹករំអិលលាយឈាមតិចៗគ្រាន់តែជាសញ្ញាកំណត់ថាការឈឺពោះសម្រាលកូនជិតកើតមានឡើង ហើយវាអាចធ្លាក់ចេញមុនពេលចាប់ផ្ដើមនៃការឈឺពោះ សម្រាល ឬ នៅក្នុងរយៈ យឺត[៦,៩] ។ ការបើកមាត់ស្បូនតែមួយក៏មិនអាចឱ្យនិយមន័យថាជាការឈឺពោះសម្រាលដែរ ។ វាគឺជាសូចនាករមួយដែលអាចបញ្ជាក់ពីដំណាក់កាល និងរយៈនៃការឈឺ ពោះសម្រាល ។

### ២-៣-៣. របៀបបញ្ជាក់ការឈឺពោះសម្រាល

- សួរម្ដាយថាតើគាត់មានការកន្ត្រាក់ស្បូនទៀងទាត់ ឬ មានចង្វាក់ឬទេ ។ ម្ដាយភាគច្រើនមានការឈឺចាប់ តែក៏មានខ្លះមិនមានការឈឺចាប់ដែរ ។

  *'តើអ្នកមានអារម្មណ៍ថាស្បូនកន្ត្រាក់ម្ដងហើយម្ដងទៀតដែរឬទេ ?'*

  *'តើចន្លោះពេលសម្រាកមានរយៈពេលប៉ុន្មាន ?', 'តើចន្លោះពេលសម្រាកដូចឬក៏ខុសគ្នា ?'*

  *'តើការកន្ត្រាក់នៃស្បូនមានការឈឺចាប់ខ្លាំងឬមានអារម្មណ៍មិនស្រួលជាងធម្មតាដែរឬទេ ?'*
- រកនិងកត់ត្រាពី**ពេលវេលាចាប់ផ្ដើមមានការកន្ត្រាក់ស្បូនទៀងទាត់** នោះគឺជាពេលនៃការចាប់ផ្ដើមឈឺពោះសម្រាល ។ ពេលវេលានោះគឺជាពេលចាប់ផ្ដើមឈឺពោះសម្រាល ។
- បញ្ជាក់ការកន្ត្រាក់ស្បូនដោយការស្ទាបពោះ។ (មើល *៥.ការប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល ៥-៣-១ កម្លាំង* ទំព័រ៨៣) ។

### ២-៣-៤. ផលវិបាកនៃការឈឺពោះមិនធម្មតា

#### ២-៣-៤-១. ឈឺជាប់នៅចន្លោះពេលកន្ត្រាក់, ឈឺពោះភ្លាមៗនិងខ្លាំង

រោគសញ្ញាទាំងនេះអាចបញ្ជាក់ពី**ការរបើកសុកមុនសម្រាល ឬ រហែកស្បូន ។**

- **សុករបើកមុនសម្រាល** គឺជារបើកសុកចេញពីស្បូន ។ ស្ត្រីមានការឈឺពោះខ្លាំងឈឺជាប់ នៅចន្លោះពេលកន្ត្រាក់ឈឺពោះពេលប៉ះ (មានអារម្មណ៍ឈឺចាប់នៅពេលដែលអ្នកផ្ដល់សេវាស្ទាបពោះ) ដោយសារស្បូនព្យាយាមកន្ត្រាក់ខ្លាំងជាងមុនដើម្បីទប់ការហូរឈាមពីកន្លែងសុករបើក ។

- **រហែកស្បូន** គឺជាការរហែកជញ្ជាំងឬសាច់ដុំស្បូន ។ យើងអាចឃើញមានផ្ចិតកាត់ទទឹងពោះនៅខាងក្រោមផ្ចិតមុនពេលរហែក ។ សុករហែកកើតមានច្រើន ដោយសារតែស្បូនមាន ស្នាមវះកាត់ ឬ របួសពីមុនដូចជាការវះកាត់យកកូន និងការរំលូត ដោយការកាយយកកូន ចេញ ។




ប្រភពរូបភាព: *Wellness kara mita boseikango katei*, 3rd edition

**២-៣-៤-២. ការឈឺចាប់ដែលខុសពីការឈឺចាប់ស្បូនកន្ត្រាក់**

- ការឈឺចាប់តែមួយចំហៀងពោះ និងស្ទាបទៅឈឺ ឬ មិនសមស្របទៅនឹងការកន្ត្រាក់នៃស្បូនអាចបញ្ជាក់ពីការរលាកខ្នែងពោះវៀន ឬ មូលហេតុដែលត្រូវការវះកាត់ផ្សេងទៀតដូចជា រលាកស្រោមពោះអាប់សែអាងត្រគាក ឬ គីស នៅក្នុងក្រពេញអូវែ[៥] ។

**២-៣-៤-៣. ការកន្ត្រាក់ស្បូនមិនទៀងទាត់ ឬ គ្មានការកន្ត្រាក់ស្បូន**

- នៅពេលជិតគ្រប់ខែ ស្ត្រីមួយចំនួនមានការឈឺពោះស្បូនកន្ត្រាក់ខ្លាំង ។ ការកន្ត្រាក់ជាធម្មតាមិនទៀងទាត់ ឬ ភាពទៀងទាត់មិនបន្តរយៈពេលយូរ[៦] ហើយមាត់ស្បូនមិនបើក ។ ការកន្ត្រាក់ស្បូនបែបនេះគឺហៅថា '**ការឈឺពោះសម្រាលមិនពិតប្រាកដ**' ហើយមានន័យថាការឈឺពោះសម្រាលពិតប្រាកដមិនទាន់ចាប់ ផ្តើម ។ សង្កេតមើលស្ត្រី**យ៉ាងហោចណាស់៨ម៉ោង**[៧] ព្រមទាំងតាមដាន រយៈឃើតដោយយកចិត្តទុកដាក់លើការកន្ត្រាក់របស់ស្បូន និងការប្រែប្រួល មាត់ស្បូន ។

## ២-៤. ចលនាទារកក្នុងផ្ទៃ

《សង្ខេប》

- ប្រសិនបើស្ត្រីថាកូនមិនសូវមានចលនា ឬ គ្មានចលនា នោះប្រហែលជាបញ្ជាក់ថាទារកខ្សោយ ។ បញ្ជាក់ស្ថានភាពទារកដោយការស្តាប់ចង្វាក់បេះដូងទារក ។
- ក្នុងអំឡុងពេលឈឺពោះសម្រាល ការបញ្ជាក់ស្ថានភាពទារកដោយការស្តាប់ចង្វាក់បេះដូងទារកមានលក្ខណៈជាក់លាក់ជាងការតាមដានចលនារបស់ទារកក្នុងផ្ទៃ ។

### ២-៤-១. លក្ខណៈធម្មតានៃចលនារបស់ទារកក្នុងផ្ទៃ

- គេអាចដឹងពីចលនារបស់ទារកចាប់ផ្តើមពី **១៦ ទៅ ២០សប្តាហ៍ ។** ទារកមានចលនាកាន់តែញឹកញាប់ និងខ្លាំងឡើងនៅត្រីមាសទី២[៩] ។

### ២-៤-២. ផលវិបាក ដោយសារទារកមិនសូវធ្វើចលនា ឬ គ្មានចលនា

- ប្រសិនបើស្ត្រីត្អូញត្អែរថាចលនាទារកមានការថយចុះ ឬ គ្មានចលនាវាអាចនឹងបញ្ជាក់ថា**ទារកខ្សោយ** ដែលបណ្តាលមកពីហេតុផលសម្ពាធដូចជាសុករបើកមុនសម្រាល[១,៩ (S-១៥៥)] ។
- ជាដំបូងស្តា**ប់ចង្វាក់បេះដូងទារក ។** ប្រសិនបើធម្មតាសុំឱ្យស្ត្រីគេងសណ្តូកជើង និងសម្រាកដើម្បី ស្ទាបចលនារបស់ទារក ។ ក្នុងអំឡុងពេលឈឺពោះសម្រាល វាមានភាពពិបាក ដើម្បីដឹងពីចលនារបស់ទារក ។ បញ្ជាក់ស្ថានភាពទារកជាប្រចាំដោយការស្តាប់ចង្វាក់បេះដូងទារក ។
- ប្រសិនបើអវត្តមានចលនារបស់ទារកទាំងស្រុង ហើយមិនឮស្នូរបេះដូងទារកលោតនោះគឺ សង្ស័យ ថាទារកក្នុងផ្ទៃស្លាប់[៩(S-១៥៥)] ។

# ជំពូកទី៣ ព័ត៌មានទូទៅ និងប្រវត្តិសម្ភពរបស់ស្ត្រី

**សង្ខេប**

- វត្ថុបំណងនៃជំពូកនេះគឺ (១) យល់ពីព័ត៌មានទូទៅនិងប្រវត្តិសម្ភពរបស់ម្តាយ និង (២) កំណត់ថាតើម្តាយមានសញ្ញាធម្មតាឬមិនធម្មតាលើព័ត៌មានទូទៅនិងប្រវត្តិសម្ភពដែរឬទេ?
- ការប្រឈមមុខនឹងផលវិបាកធ្ងន់ធ្ងរ ឬ ភាពមិនធម្មតាមួយចំនួនអាចដឹងតាមរយៈការប៉ាន់ប្រមាណព័ត៌មានមូលដ្ឋានរបស់ស្ត្រីនិងទារកក្នុងផ្ទៃ ។
- ព័ត៌មានមូលដ្ឋានអាចប្រមូលបានពីស្ត្រីសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) និងការវាស់វែង ឬ គណនាសាមញ្ញៗ ។

《**សង្ខេប**》

- ជាការចាំបាច់ក្នុងការដឹងពីអាយុគភ៌ដើម្បីកំណត់ពីការសម្រាលគ្រប់ខែ មិនគ្រប់ខែ ឬលើសខែ ។
- គណនាអាយុរបស់គភ៌ដោយស្គាល់ថ្ងៃដំបូងនៃដូវចុងក្រោយ (LMP) ។
- ប្រសិនបើស្ត្រីមិនចាំ LMP គាត់គួរចាត់ទុកថាមិនដឹងពីអាយុរបស់គភ៌ ។
- ទារកទើបកើតដែលមិនគ្រប់ខែត្រូវការការគាំទ្រផ្លូវដង្ហើម កម្ដៅ និងចំណីអាហារក្នុងបរិស្ថានមួយដែលស្អាត ដោយសារតែភាពមិនគ្រប់ខែនោះ ។
- ទារក ដែលលើសខែអាចនឹងខ្សោយក្នុងអំឡុងពេលឈឺពោះសម្រាល ដោយសារអសមត្ថភាពមុខងារសុក ។ ការឈឺពោះសម្រាលអូសបន្លាយក៏អាចកើតមានផងដែរ ដោយសារ ទារកមានទំហំធំ ។

## ៣-១-១. និយមន័យនៃអាយុនៃគភ៌

- អាយុនៃគភ៌គឺជាពេលវេលាចាប់ផ្ដើមពី**ថ្ងៃដំបូងនៃរដូវចុងក្រោយ** (LMP)[៦] ។ អាយុនៃគភ៌ត្រូវ បង្ហាញពេញលេញជា**សប្ដាហ៍និងថ្ងៃ**[៩] ដូចជា ៣៧សប្ដាហ៍ ៤ថ្ងៃ ។

## ៣-១-២. មធ្យោបាយដើម្បីដឹងពីអាយុនៃគភ៌

### ៣-១-២-១. ការគណនារដូវចុងក្រោយ (LMP)

- ការកំណត់**កាលបរិច្ឆេទការសម្រាលរំពឹងទុក** និងអាយុនៃគភ៌អាចវាស់វែង ដោយរាប់ពីថ្ងៃដំបូងនៃរដូវចុងក្រោយ (LMP) ដោយមើលតាមកងប្រតិទិនរបស់ស្ត្រីមានផ្ទៃពោះ (Pregnancy wheel calendar) ឬវិធីសាស្ត្រគណនាកាលបរិច្ឆេទការសម្រាលរំពឹងទុក ។
- ប្រសិនមិនដឹងពីអាយុគភ៌ និងស្ត្រីមិនចាំកាលបរិច្ឆេទរដូវចុងក្រោយ សូមវាស់កម្ពស់ស្បូន (មើល *៣-២-២. របៀបវាស់កំពស់ស្បូន* ទំព័រ៣៥) ។

**<កងប្រតិទិនរបស់ស្ត្រីមានផ្ទៃពោះ (Pregnancy wheel calendar)>**

- កងប្រតិទិនរបស់ស្ត្រីមានផ្ទៃពោះគឺជាប្រតិទិនតូចដែលអាចប្រើប្រាស់ បានសម្រាប់មើលអាយុនៃគភ៌ពេលចូលសម្រាកពេទ្យ និងកាលបរិច្ឆេទសម្រាលកូន (EDD) ដោយកំណត់តាម LMP ។
- EDD គឺត្រូវបានកំណត់ត្រឹម ៤0 សប្តាហ៍ 0 ថ្ងៃនៃអាយុរបស់គភ៌ ។
- ដាក់ចុងព្រួញឱ្យចំ LMP បន្ទាប់មកអ្នកអាចរកឃើញអាយុនៃគភ៌បច្ចុប្បន្ននៅពេលដែលអ្នកឃើញកាលបរិច្ឆេទថ្ងៃនេះ ។
- ចុងព្រួញម្ខាងទៀតដោយកំណត់ត្រឹម ៤0 សប្តាហ៍ 0 ថ្ងៃបង្ហាញ EDD ។




ប្រភពរូបភាព: https://www.acog.org/About-ACOG/News-Room/News-Releases/2016/ACOG-Reinvents-the-Pregnancy-Wheel?IsMobileSet=false

**<វិធីសាមញ្ញក្នុងការគណនាកាលបរិច្ឆេទសម្រាលរំពឹងទុក ( EDD )>**

វិធីសាស្ត្រទី១ ៖ ថែម៧ នៃថ្ងៃរបស់ LMP និងដក៣ នៃខែរបស់ LMP ( នឹងថែម១ឆ្នាំ )

វិធីសាស្ត្រទី២ ៖ ថែម៧ នៃថ្ងៃរបស់ LMP និងថែម ៩ នៃខែរបស់ LMP

ឧទាហរណ៍១ LMP ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨

↓ +៧ ↓ -៣ ↓ +១

EDD ២៩ កញ្ញា ២០១៩

ឧទាហរណ៍ ២ LMP ថ្ងៃទី២ ខែមករា ឆ្នាំ២០១៩

↓ +៧ ↓ +៩ ↓

EDD ៩ តុលា ២០១៩

### ៣-១-២-២. អេកូសាស្ត្រ (Ultrasound)

- អេកូសាស្ត្រ (Ultrasound) គឺជាមធ្យោបាយមួយទៀតដើម្បីឱ្យដឹងពីអាយុរបស់គភ៌ តែការពិនិត្យគឺត្រូវតែធ្វើឡើងនៅ**ត្រីមាសទីមួយ** (**អាយុគភ៌ ត្រឹមសប្តាហ៍ទី១៣និង ៦ថ្ងៃ**)[៧] ។ អាយុរបស់គភ៌ និង EDD ដែលប៉ាន់ប្រមាណដោយអេកូសាស្ត្របន្ទាប់ពីរយៈពេលនេះគឺមិនប្រាកដឡើយ ។
- ដូច្នេះអ្នកមិនត្រូវប្រើប្រាស់ EDD និងអាយុរបស់គភ៌បច្ចុប្បន្នដែលសរសេរ ដោយអេកូសាស្ត្រនៅត្រីមាស ទីពីរ និងទីបីឡើយ ។

## ៣-១-៣. ចំណាត់ថ្នាក់អាយុនៃគភ៌

អាយុនៃគភ៌ត្រូវបានចាត់ថ្នាក់ជា៣កំឡុងពេល:

(១) **គភ៌គ្រប់ខែ** ពី ៣៧សប្តាហ៍និង ០ថ្ងៃទៅ ៤១សប្តាហ៍និង ៦ថ្ងៃ

(២) **គភ៌មិនគ្រប់ខែ** (តិចជាងឬស្មើ) ≤ ៣៦សប្តាហ៍ និង ៦ថ្ងៃ

(៣) **គភ៌លើសខែ** (ច្រើនជាងឬស្មើ) ≧ ៤២សប្តាហ៍ និង ០ថ្ងៃ

## ៣-១-៤. ផលវិបាកដោយសារតែការសម្រាលកូនមិនគ្រប់ខែនិងលើសខែ

### ៣-១-៤-១. ការសម្រាលកូនមិនគ្រប់ខែ

- សម្រាប់ទារកក្នុងផ្ទៃ និងទារកទើបនឹងកើតដែលមិនគ្រប់ខែភាពមិនគ្រប់ខែអាចធ្វើឱ្យមានផលវិបាកមួយចំនួន ។
  (១) ទារកក្នុងផ្ទៃដែលមិនគ្រប់ខែភាគច្រើនរងផលប៉ះពាល់ដោយសម្ពាធសង្កត់របស់ស្បូនដែលកន្ត្រាក់ ដែលបណ្តាលឱ្យចង្វាក់បេះដូងរបស់កូន (FHR) ងាយនឹងធ្លាក់ចុះនៅអំឡុងពេលឈឺពោះសម្រាល និងអាចជាលទ្ធផល**ទារកខ្សោយ ។**
  (២) ទារកទើបនឹងកើតមិនគ្រប់ខែ សួតរបស់គេមិនទាន់ពេញលេញដែលធ្វើឱ្យមានបញ្ហា **ផ្លូវដង្ហើម ។**

(៣) ទារកទើបកើតដែលមិនគ្រប់ខែមិនអាចផលិតកម្ដៅគ្រប់គ្រាន់ដើម្បីរក្សាសីតុណ្ហភាពរាងកាយបាន ដូច្នេះហើយគេងាយនឹងមាន **សីតុណ្ហភាពរាងកាយធ្លាក់ចុះ ។**

(៤) ទារកទើបនឹងកើតដែលមិនគ្រប់ខែគឺប្រព័ន្ធភាពស៊ាំនៅខ្សោយដែលជាទូទៅការបង្ករោគអាចរីករាលដាលចូលទៅក្នុងចរន្តឈាមបានឆាប់រហ័ស **(Sepsis)** ។

(៥) ទារកទើបនឹងកើតមិនគ្រប់ខែ**មិនទាន់ជញ្ជក់ដោះបានល្អ**ដោយខ្លួនឯងបានទេ ។

### ៣-១-៤-២. ការសម្រាលកូនលើសខែ

- នៅពេលអាយុគភ៌ឡើងដល់ ៤២ សប្ដាហ៍ឬច្រើនជាងនេះ មុខងាររបស់សុក ដែលផ្គត់ផ្គង់អុកស៊ីសែន និងសារធាតុចិញ្ចឹមចាប់ផ្ដើមធ្លាក់ចុះ (អសមត្ថភាពមុខងារសុក) ។ វាបង្កឱ្យមាន ផលវិបាកមួយចំនួនៈ

(១) អសមត្ថភាពមុខងារសុកបណ្ដាលឱ្យការផ្ដល់អុកស៊ីសែនពីម្ដាយទៅកូនក្នុងផ្ទៃមិនបានគ្រប់គ្រាន់។ ជាលទ្ធផលចង្វាក់បេះដូងរបស់កូនធ្លាក់ចុះជាញឹកញាប់ ហើយអាចបណ្ដាលឱ្យ**ទារកខ្សោយ ។**

(២) បរិមាណនៃទឹកភ្លោះបន្តធ្លាក់ចុះតាំងពីពេលកូនក្នុងផ្ទៃមានអាយុគ្រប់ខែ៦ ។ ក្នុងអំឡុងពេលឈឺពោះសម្រាល ទងសុកងាយរងការសង្កត់ ពេលស្បូនកន្ត្រាក់ ដោយសារតែទឹក ភ្លោះមានការធ្លាក់ចុះដូច្នេះហើយវាបណ្ដាលឱ្យទារកខ្សោយនៅពេលឈឺពោះសម្រាល ។

(៣) ទារកក្នុងផ្ទៃបន្តលូតលាស់ហើយក្លាយជាមានទំហំធំដែលវាអាចបង្កឱ្យមានការ**ឈឺពោះសម្រាលមានរយៈពេលយូរ ឬ ការសម្រាលស្ទា ទារកអាចជាប់ក្នុងអាងត្រគាករបស់ម្ដាយ** (Shoulder dystocia) ។

## ៣-២. កម្ពស់ស្បូននៅពេលចូលសម្រាកពេទ្យ

《**សង្ខេប**》

- កម្ពស់ស្បូន គឺជាសូចនាករមួយក្នុងចំណោមសូចនាករដទៃទៀត ក្នុងការប៉ាន់ប្រមាណសមាសភាគស្បូន ។ ពីព្រោះវាមានទំនាក់ទំនងជាមួយទំហំរបស់ស្បូន ទារកក្នុងផ្ទៃទឹកភ្លោះ និងសុក ។
- ប្រសិនបើកម្ពស់ស្បូនធំ ឬ តូចមិនធម្មតាទំហំរបស់ទារកក្នុងផ្ទៃ ឬ បរិមាណទឹកភ្លោះអាចនឹងមិនធម្មតា ។
- ករណីមិនដឹងអាយុរបស់គភ៌ កម្ពស់ស្បូនតូចអាចបញ្ជាក់ថាកូនតូចដោយសារតែទារកមិនគ្រប់ខែ ឬ ការលូតលាស់មានកម្រិត។

### ៣-២-១. និយមន័យនៃកម្ពស់ស្បូន

- **កម្ពស់ស្បូនគឺជាចម្ងាយតាមបណ្តោយពោះពីលើឆ្អឹងថ្ងាសរបស់ម្តាយ (Symphysis pubis) ដល់កំពូលស្បូន ។**
- កម្ពស់ស្បូនមានទំនាក់ទំនងជាមួយទំហំស្បូន ។ នៅក្នុងស្បូនមាន**ទារក ទឹកភ្លោះ និងសុក ។**
- ទំហំនៃទារកក្នុងផ្ទៃ និងបរិមាណទឹកភ្លោះផ្លាស់ប្តូរតាមអាយុនៃគភ៌ ។
- ដូច្នេះហើយ កម្ពស់ស្បូន អាចត្រូវបានគេប្រើជាជំនួយក្នុងការប៉ាន់ប្រមាណ ទំហំនៃទារកក្នុងផ្ទៃ និងបរិមាណទឹកភ្លោះ សម្រាប់អាយុនៃគភ៌នីមួយៗ ។



ប្រភពរូបភាព:
https://www.grepmed.com/images/4172/approximation-obstetrics-diagnosis-fundal-height-obgyn

## ៣-២-២. របៀបវាស់កម្ពស់ស្បូន

(១) ប្លោកនោមត្រូវគ្មានទឹកនោមមុនពេលវាស់កម្ពស់ស្បូន ។

(២) សុំឱ្យម្ដាយគេងផ្ងារ ។

(៣) ស្ទាបរកកំពូលស្បូនៈដាក់ដៃរបស់អ្នកនៅពីក្រោមចុងសន្ទះទ្រូង ហើយសង្កត់ថ្នមៗរំកិលដៃចុះមក ពោះរហូតអ្នកមានអារម្មណ៍ថាកោងចូលនៅផ្នែកខាងលើនៃស្បូន ។

**សម្គាល់៖** អ្នកអាចសុំម្ដាយឱ្យបញ្ឈរជង្គង់នៅខណៈពេលដែលអ្នកស្វែងរកកំពូលស្បូន ។ ប៉ុន្តែគាត់ត្រូវសណ្ដូកជើងឱ្យត្រង់វិញនៅពេលវាស់កម្ពស់ស្បូន ។

(៤) ស្ទាបរកឆ្អឹងថ្ងាស (Symphysis pubis): កាន់ខ្សែម៉ែត្រនៅលើកំពូលស្បូន ហើយទាញចុះទៅឆ្អឹងថ្ងាស (Symphysis pubis) ។




ប្រភពរូបភាព: https://www.grepmed.com/images/4172/approximation-obstetrics-diagnosis-fundal-height-obgyn

## ៣-២-៣. ផលវិបាកនៃកម្ពស់ស្បូនដែលខុសពីប្រវែងធម្មតា

### ៣-២-៣-១. កម្ពស់ស្បូន ច្រើនជាងឬស្មើ ៣៥ស.ម

កម្ពស់ស្បូន**ច្រើនជាង ឬ ស្មើ ៣៥ស.ម** គឺធំហួសសម្រាប់ទារកតែមួយហើយគ្រប់ខែ ។ វាអាចបញ្ជាក់បានពីផលវិបាកដូចខាងក្រោម៖

- អាចនឹងមាន**ទារកច្រើនក្នុងផ្ទៃលើសពីមួយ**→( មើល *៣-៥. ចំនួនទារកក្នុងផ្ទៃ* ទំព័រ៤២ )
- ទារកអាចនឹងធំជ្រុល ។ ក្បាលទារកប្រហែលមិនអាចចុះចូលក្នុងអាងត្រគាក ដោយសារតែមាន**វិសមមាត្ររវាងឆ្អឹងក្បាលទារក និងឆ្អឹងអាងត្រគាកម្តាយ** (CPD) ។ ទារកធំជ្រុលក៏អាច បង្កឱ្យមាន**ការឈឺពោះសម្រាលយូរ** ឬ **ការឈឺពោះសម្រាលដែលមានឧបសគ្គ**ដូចជា ការសម្រាលជាប់ស្មាទារកផងដែរ ។
- អាចនឹងមាន**សណ្ឋាន ទម្រង់បង្ហាញ និងការបង្ហាញខុសធម្មតា ។**
- អាចនឹងមានការ**កើនឡើងនៃបរិមាណទឹកភ្លោះ**ច្រើនខុសពីធម្មតា ។ ការកើនឡើងនៃបរិមាណទឹកភ្លោះច្រើនខុសពីធម្មតាអាចបណ្តាលឱ្យមានការឈឺ**ពោះសម្រាលយូរ** ដោយសារទំហំស្បូនធំហួសប្រមាណ **សណ្ឋានទម្រង់បង្ហាញ និងការបង្ហាញខុសពីធម្មតា ។** នៅពេលស្រោមទឹកភ្លោះត្រូវបាន

គេបំបែក **ការរបើកសុកមុនសម្រាល** និង**ការធ្លាក់ទងសុកចេញមកក្រៅមុនចេញទារក** អាចនឹងកើតមានឡើង[៥,៦] ។

- **ស្បូនអាចនឹងសន្ទឹងហួសប្រមាណ**ដែលបណ្ដាលឱ្យមាន**ការធ្លាក់ឈាមក្រោយសម្រាល** (PPH) ដោយសារតែ**សាច់ដុំស្បូនខ្សោយ** ស្បូនកន្ត្រាក់មិនបានគ្រប់គ្រាន់ដើម្បីបញ្ឈប់ការហូរឈាម ពីសរសៃជញ្ជាំងស្បូនដែលជាកន្លែងសុកតាំងនៅ[៦] ។

**៣-២-៣-២. កម្ពស់ស្បូន ៣៣ ទៅ ៣៤ស.ម**

- កម្ពស់ស្បូន ៣៣ ទៅ ៣៤ស.ម គឺស្ថិតនៅក្នុងប្រវែងធម្មតាតែធំគួរសមដែរ ។ ចូរចាំពីផលវិបាក ដែលអាចកើតមាននៅខាងលើ ហើយតាមដានម្ដាយទារកក្នុងផ្ទៃ និងការវិវត្តនៃការសម្រាលជាប្រចាំ ។

**៣-២-៣-៣. កម្ពស់ស្បូន តិចជាងឬស្មើរ ២៨ស.ម**

កម្ពស់ស្បូន**តិចជាងឬស្មើរ ២៨ស.ម** គឺ**តូចជ្រុល**សម្រាប់ទារកគ្រប់ខែ ។

វាអាចបញ្ជាក់បានពីផលវិបាកដូចខាងក្រោម៖

- អាចនឹងមានផ្ទៃពោះ**មិនគ្រប់ខែ**នៅពេលដែលមិនដឹងអាយុរបស់គភ៌ ។
- ទារកក្នុងផ្ទៃអាចនឹង**តូចជ្រុលសម្រាប់ពេលគ្រប់ខែ ។** ការលូតលាស់របស់ទារកអាចនឹង មានកម្រិតដោយសារតែមានបញ្ហាខ្លះៗទាក់ទងនឹងទារកក្នុងផ្ទៃម្ដាយ ឬ សុក ។
- អាចនឹងមាន**ការចុះថយនៃបរិមាណទឹកភ្លោះមិនធម្មតា ។** ក្នុងកំឡុងពេលឈឺពោះសម្រាលទងសុកងាយនឹងរងការសង្កត់ពេលស្បូនកន្ត្រាក់ដោយសារតែមានការចុះថយនៃទឹកភ្លោះ ដែលបណ្ដាលឱ្យ**ចង្វាក់បេះដូងរបស់ទារកចុះទាប**នៅក្នុងពេលឈឺពោះសម្រាល ។ ទារកក្នុងផ្ទៃអាចនឹងមានបញ្ហាក្នុងការលូត លាស់សួត ហើយអាចនាំឱ្យមាន**បញ្ហាផ្លូវដង្ហើម**ដល់ទារកទើបនឹងកើត ។

| |
|---|
| **សម្គាល់៖** ហេតុផលនៅពីក្រោយការបញ្ជូន និងការប្រឈមមុខនឹងផលវិបាកតាមរយៈការវាស់កម្ពស់ស្បូន គឺត្រូវបានគេពិចារណាបន្ទាប់ពីមានការពិភាក្សាជាមួយនឹងសមាជិកបង្គោលនៃការបណ្ដុះបណ្ដាលការថែទាំពេលឈឺពោះសម្រាលកូន (Core member of intrapartum care training) ។ |

## ៣-៣. អាយុស្ត្រី

《**សង្ខេប**》
- អាយុម្ដាយក្មេងពេកឬចាស់ពេកអាចបណ្ដាលឱ្យមានផលវិបាកផ្នែកសម្ភព ។
- ពិនិត្យកាលបរិច្ឆេទថ្ងៃកំណើតរបស់ស្ត្រីតាមរយៈអត្តសញ្ញាណប័ណ្ណ ឬ ឯកសារពាក់ព័ន្ធ ។
- លក្ខណៈសរីរៈសាស្ត្រតាមរយៈអាយុអាចមានឥទ្ធិពលលើស្ថានភាពម្ដាយការសម្រាល និងទារកក្នុងផ្ទៃ ។
- សម្រាប់ស្ត្រីវ័យក្មេងពេក រាងកាយដែលលូតលាស់មិនពេញលេញអាចមានឥទ្ធិពលលើការវិវត្តន៍ការសម្រាល ។
- សម្រាប់ស្ត្រីវ័យចាស់ នោះការប្រឈមមុខនឹងផលវិបាកផ្នែកសម្ភពមានការកើនឡើង ។

### ៣-៣-១. មធ្យោបាយដើម្បីដឹងពីអាយុស្ត្រី

បញ្ជាក់កាលបរិច្ឆេទកំណើត (ឆ្នាំ ខែ និងថ្ងៃ) ដោយពិនិត្យ**អត្តសញ្ញាណប័ណ្ណរបស់ម្ដាយ ឬ ឯកសារ** ដទៃ**ទៀត** (**កំណត់ត្រាវេជ្ជសាស្ត្រ សៀវភៅសុខភាពមាតា** (**សៀវភៅពណ៌ផ្កាឈូក**) -ល-) ។ ប្រសិនបើគ្មានអ្វីអាចបញ្ជាក់ពីកាលបរិច្ឆេទថ្ងៃកំណើតទេ សូមសួរគាត់ ឬ ក្រុមគ្រួសាររបស់គាត់ ។

### ៣-៣-២. ផលវិបាកបណ្ដាលពីអាយុស្ត្រីក្មេងពេក ឬ ចាស់ពេក

#### ៣-៣-២-១. មានផ្ទៃពោះនៅអាយុតិចជាងឬស្មើ១៧ឆ្នាំ

- រាងកាយរបស់ស្ត្រីមិនទាន់ពេញវ័យដែលអាចបណ្ដាលឱ្យមានផលវិបាកខ្លះទាក់ទងនឹងសម្ភពដូច ជា ស្លេក ស្លាំង បម្រុងក្រឡាភ្លើង ឈឺពោះសម្រាលយូរ និង ទារកកើតមាន ទម្ងន់ទាប [៦(p១៦១)] ។

#### ៣-៣-២-២. មានផ្ទៃពោះនៅអាយុតិចជាងឬស្មើ១៥ ឆ្នាំ

- បន្ថែមទៅលើការប្រឈមមុខនឹងគ្រោះថ្នាក់ខាងលើឆ្អឹងត្រគាកនិងផ្លូវសម្រាលរបស់ក្មេងស្រី ដែល មានអាយុ**តិចជាងឬស្មើ**១៥ឆ្នាំ គឺនៅលូតលាស់មិនទាន់ពេញលេញ។ នេះគឺអាចបណ្ដាលឱ្យមាន**ការឈឺពោះសម្រាលដែលមានឧបសគ្គ** និងមានផលវិបាកទាក់ទងនឹងសម្ភពផ្សេងទៀត ដូចជា មានភាពខុសប្រក្រតីពីការដាច់រហែកទ្វាមាសនិង**រន្ធគូទ (Fistulas)** [១០]។

**៣-៣-២-៣. ការមានផ្ទៃពោះនៅអាយុច្រើនជាងឬស្មើ៣៥ ឆ្នាំ**

- ម្តាយអាយុច្រើនអាចប្រឈមមុខនឹងផលវិបាកមួយចំនួនដូចជា**ជំងឺលើសសម្ពាធឈាម ទឹកនោមផ្អែម សុកពាំងមាត់ស្បូន សុករបើកមុនសម្រាល និងការធ្លាក់ឈាមក្រោយសម្រាល (PPH)**[៤,៦] ។
- ទាំងម្តាយដែលមានអាយុតិចពេកនិងច្រើនពេក ការតាមដានម្តាយ (ពិសេសសម្ពាធឈាមនិងស្ថានភាពធ្លាក់ឈាម) ទារកក្នុងផ្ទៃ និងការវិវត្តនៃការសម្រាលគឺមានសារៈសំខាន់ ។
- ការប្រឈមគ្រោះថ្នាក់របស់ស្ត្រីមានផ្ទៃពោះអាយុលើសឬស្មើ៣៥ឆ្នាំមានលក្ខណៈខុសគ្នារវាងស្ត្រីកូនដំបូង និងស្ត្រីមានកូនច្រើនដង ។ ដូច្នេះការស្តាប់ប្រវត្តិនៃការមានផ្ទៃរបស់ស្ត្រីមានសារៈសំខាន់ ។

## ៣-៤. ចំនួនផ្ទៃពោះ ចំនួនសម្រាល ចំនួនរលូតឬរំលូត

《សង្ខេប》
- បញ្ជាក់ចំនួនមានផ្ទៃពោះ ការសម្រាល និងការរលូតឬរំលូតជាមួយម្ដាយ ។
- ចំនួននៃការសម្រាលកូនមានឥទ្ធិពលសំខាន់លើការវិវត្តការឈឺពោះសម្រាល ។ ចូលកត់សម្គាល់ថាដំណើរការនៃការសម្រាលច្រើនដង ជាធម្មតាលឿនជាងការសម្រាលលើកទីមួយ ។
- បន្ថែមពីលើនេះទៀតចំនួនសម្រាលនិងការរំលូតអាចនាំឱ្យមានផលវិបាកផ្នែកសម្ភពមួយចំនួន ។

### ៣-៤-១. និយមន័យចំនួនផ្ទៃពោះ ចំនួនសម្រាល ចំនួនរលូត ឬ រំលូត

(១) **ចំនួនផ្ទៃពោះ** គឺជាចំនួនសរុបនៃការមានផ្ទៃពោះ **រួមមានការមានផ្ទៃពោះបច្ចុប្បន្ន** ដោយមិនគិតពីលទ្ធផលនៃការមានផ្ទៃពោះ ។

(២) **ចំនួនសម្រាល**គឺជាចំនួនដងដែលស្ត្រីសម្រាលកូនមាន **អាយុ២៧សប្ដាហ៍0ថ្ងៃ ឬ ច្រើន សប្ដាហ៍ជាងនេះ**[១] ដោយមិនគិតថាទារកក្នុងផ្ទៃមានតែមួយ ឬមានច្រើនហើយទារកកើតមករស់ ឬ ស្លាប់ ។ **'Grand multiparity'** មានន័យថាស្ត្រីដែលមានការសម្រាលកូនច្រើនជាងឬ ស្មើ៥ដង[៤] ។

(៣) **ការរលូត** គឺជាការបាត់បង់កូននៅ**អាយុមុន២៦សប្ដាហ៍ ៦ថ្ងៃ ឬតិចជាង ។**

(៤) **ការរំលូត** គឺជាដំណើរការនៃការបញ្ចប់គភ៌ **ដោយមានគោលបំណង**តាមបែបបទវេជ្ជសាស្ត្រ នៅ**អាយុមុន២៦សប្ដាហ៍ ៦ថ្ងៃ**[១] ។

### ៣-៤-២. មធ្យោបាយក្នុងការដឹងពីចំនួនសម្រាលនិងការរលូតឬរំលូត

ពិនិត្យសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ឬសួរម្ដាយពីចំនួនដងដែលមានផ្ទៃ ពោះ(១) ចំនួនសម្រាល (២) និងបទពិសោធន៍ ធ្លាប់មានករណី រលូតឬរំលូត (៣,៤) ។

(១) ចំនួនមានផ្ទៃពោះ

(២) ចំនួនសម្រាល

a. ចំនួនកូនដែលកំពុងរស់នៅបច្ចុប្បន្ន

b. ចំនួនកូនកើតស្លាប់

( ៣ ) ចំនួនរំលូត

c. តើការរំលូតបែបណាដែលគាត់មានបទពិសោធន៍ ?

( ៤ ) ចំនួនរលូត

## ៣-៤-៣. ផលវិបាកនៃការសម្រាលចំនួន ៥ដង ឬ ច្រើនលើសពី ៥ដង និងធ្លាប់មានរលូតនិងរំលូត

### ៣-៤-៣-១. ការសម្រាលចំនួន ៥ដង ឬ លើសពី ៥ដង (Grand multipara)

- មានការប្រឈមមុខនឹងភាពស្លេកស្លាំងនិងកង្វះអាហារូបត្ថម្ភខ្ពស់ដោយសារសម្រាលមានការកើនឡើងជាពិសេសនៅពេលដែលចន្លោះពេលនៃការមានផ្ទៃពោះមានរយៈពេលខ្លីហើយវាអាចបង្កឱ្យមានការធ្លាក់ឈាមក្រោយសម្រាលនិងទារកមានទម្ងន់ទាប[៤] ។ ការប្រឈមមុខទាំងនោះមានការកើន ឡើងខ្ពស់សម្រាប់ស្ត្រីដែលមានការសម្រាលច្រើនជាង ឬ ស្មើ៥ដង ។
- ស្ត្រីដែលមានអាយុចាស់ ហើយការសម្រាលមានចំនួន៥ដង ឬ លើសពី៥ដង អាចបណ្តាលឱ្យមានផលវិបាកដ៏ទៃទៀតផងដែរ ។ (មើល *៣-៣ អាយុស្ត្រី* ទំព័រ៣៨)
- ការវិវត្តនៃការសម្រាលសម្រាប់អ្នកដែលមានការសម្រាលច្រើនដង គឺជាទូទៅមានភាពលឿនជាងកូនដំបូង ហើយវាលឿនទៅៗនៅពេលដែលចំនួនសម្រាលមានការកើនឡើង ។

### ៣-៤-៣-២. ចំនួនសម្រាល ៤ដង

- ម្តាយអាចសម្រាលនៅមណ្ឌលសុខភាពបានប៉ុន្តែមានការប្រឈមមុខនឹងផលវិបាកដូចខាងលើ ។
- តាមដានស្ថានភាពម្តាយ និងទារកក្នុងផ្ទៃជាប្រចាំហើយធ្វើការអង្កេតដោយប្រុងប្រយ័ត្នលើសញ្ញាការវិវត្តនៃការសម្រាលកូន ។

### ៣-៤-៣-៣. ប្រវត្តិធ្លាប់មានរំលូត ឬ រលូត

- ក្នុងករណីស្ត្រីធ្លាប់មានការរំលូត ឬ រលូតបញ្ជាក់ពីប្រវត្តិនៃ**ការរំលូតដោយការបូម (Manual Vacuum Aspiration) ការបើកមាត់ស្បូន និងការកៀរយកកូនចេញ (Dilatation and Curettage)** ឬ **ការបើកមាត់ស្បូន និងកៀបយកកូនចេញ (Dilatation and Evacuation)**។
- ករណីម្តាយមានប្រវត្តិរំលូត ដោយមធ្យោបាយណាមួយម្តាយអាចនឹងមានស្នាមរបួសនៅខាងក្នុងស្បូន ។ ស្នាមរបួសនៅខាងក្នុងស្បូនអាចបណ្តាលឱ្យមាន**សុកពាំងមាត់ស្បូន និងជាប់សុកនៅក្នុងស្បូន** [៦] ។

## ៣-៥. ចំនួនទារកក្នុងផ្ទៃ

《**សង្ខេប**》

- បញ្ជាក់ចំនួនទារកក្នុងផ្ទៃដោយការសួរស្ត្រី ឬ ពិនិត្យសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ។
- ចំពោះស្ត្រីដែលមានកូនច្រើនក្នុងផ្ទៃត្រូវបញ្ជូនភ្លាម ពីព្រោះវាអាចមានផលវិបាកដល់ស្ត្រី កូនក្នុងផ្ទៃ និងការវិវត្តការសម្រាល ។

### ៣-៥-១. របៀបពិនិត្យចំនួនទារកក្នុងផ្ទៃ

- ពិនិត្យសៀវភៅសុខភាពមាតា(សៀវភៅផ្កាឈូក) ឬ សួរម្ដាយថាតើគាត់ធ្លាប់ត្រូវបានគេប្រាប់ ថាមានចំនួន ទារកច្រើនក្នុងផ្ទៃទេនៅពេលពិនិត្យផ្ទៃពោះ (ANC) ឬ ពិនិត្យ ដោយអេកូសាស្ត្រ (Ultrasound) ពីមុនទេ ។
- ការស្ទាបប៉ះក្បាលកូនមានចំនួន ២ គឺជាមធ្យោបាយមួយទៀតក្នុងការធ្វើរោគវិនិច្ឆ័យលើកូនភ្លោះប៉ុន្តែវាពិបាកនៅពេលដែលកូនភ្លោះដេកពីលើគ្នា ។

### ៣-៥-២. ផលវិបាកចំពោះចំនួនទារកច្រើនក្នុងផ្ទៃ

- **ស្ត្រីដែលមានកូនច្រើនក្នុងផ្ទៃ** មានបន្ទុកខ្លាំងទៅលើរាងកាយ ហើយអាចបណ្ដាលឱ្យមាន**ជំងឺបម្រុងក្រឡា ភ្លើង ឬ ស្លេកស្លាំង ។**
- ភាពធំនៃស្បូន (ទារកច្រើនជាងឬស្មើ២) ធ្វើឱ្យ**ស្បូនលាតសន្ធឹងហួសប្រមាណ ។** វាអាចនឹងបណ្ដាលឱ្យមានការ**ឈឺពោះសម្រាលយូរ** ឬ **ធ្លាក់ឈាមក្រោយសម្រាល** (PPH) ។ នៅពេលដែលស្បូនមិនអាចទប់ទល់នឹងភាពធំបានការសម្រាលដែលមិនគ្រប់ខែអាចនឹងកើតមាន ។
- **ការបង្ហាញនិងទម្រង់បង្ហាញ** របស់ទារកក្នុងផ្ទៃជាញឹកញាប់ គឺ**មិនធម្មតា**ដែលអាចបង្កឱ្យមាន**ចង្កាថ្កក់គ្នា ឬ បញ្ច្រាស់/ទទឹង (Interlocking collision)** ឬ មាន**ការឈឺពោះសម្រាល ដែលមានឧបសគ្គ ។ ទងសុកធ្លាក់មកមុនទារកសម្រាល** គឺកើតមានជាញឹកញាប់នៅក្នុងស្ថានភាពនេះ ។

## ៣-៦. កម្ពស់ស្ត្រី

《**សង្ខេប**》
- ទំហំនៃអាងត្រគាកម្តាយជាប់ទាក់ទងនឹងកម្ពស់របស់ម្តាយ។ ដូច្នេះការវាស់ កម្ពស់ម្តាយ មានសារៈសំខាន់ណាស់។
- ពិនិត្យសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) រកកម្ពស់ស្ត្រី ។ ប្រសិនបើគ្មានព័ត៌មានទេវាស់កម្ពស់ស្ត្រី ។
- នៅពេលស្ត្រីដែលមានកម្ពស់ទាបជាង ឬ ស្មើ ១៥០ស.ម វិសមាមាត្ររវាងក្បាលទារកនឹងឆ្អឹងត្រគាកម្តាយអាចកើតមានឡើងដែលធ្វើក្បាលទារកមិនអាចចុះចូលក្នុងអាងត្រគាកម្តាយបាន ។

### ៣-៦-១. គោលបំណងនៃការវាស់កម្ពស់

- វាស់កម្ពស់នៃរាងកាយពីក្បាលដល់ចុងជើង ។
- ទំហំរបស់អាងត្រគាកមានទំនាក់ទំនងនឹងកម្ពស់ដែលចាំបាច់ត្រូវធ្វើការវាស់កម្ពស់ ។
- កម្ពស់មានឥទ្ធិពលលើភាពខុសទ្រង់ទ្រាយរបស់ឆ្អឹងខ្នង ឆ្អឹងត្រគាក ឬ សន្លាក់របស់ត្រគាក ឬ ជើង ។ ការខុសទ្រង់ទ្រាយអាចនឹងមានឥទ្ធិពលក្នុងការធ្វើឱ្យផ្លូវសម្រាលរីកធំ ។ ពិនិត្យការខុសទ្រង់ទ្រាយ នៅពេលវាស់កម្ពស់ ។

### ៣-៦-២. របៀបវាស់កម្ពស់

- វាស់កម្ពស់ដោយឈរឱ្យត្រង់ជាមួយនឹងជើងទទេរនិងប្រអប់ជើងញែកពី ៣០ ទៅ ៤០ ដឺក្រេ ។
- ដាក់ក្បាល ខ្នង ត្រគាក និងកែងជើងលើប្រដាប់វាស់ និងចង្កាបត់ចុះ ។

### ៣-៦-៣. ផលវិបាកនៃកម្ពស់ទាបពេក

#### ៣-៦-៣-១. កម្ពស់តិចជាងឬស្មើ ១៤៥ស.ម

- ស្ត្រីដែលទាបច្រើនតែមានអាងត្រគាកតូច ហើយនាងអាចមាន**អង្កត់ផ្ចិតអាងត្រគាកតូចជាងធម្មតា (Contracted pelvis)** (**ច្រកចូលអាងត្រគាក**) ដែលអាចប៉ះពាល់លើការវិវត្តនៃការសម្រាល ។
- ច្រកចូលនៃអាងត្រគាកដែលតូចជាងធម្មតាអាចនឹងរារាំងមិនអាចឱ្យទារកចុះចូលក្នុងត្រគាកបាន ។ នេះគឺជាមូលហេតុមួយនៃ **វិសមមាត្ររវាងឆ្អឹងក្បាលទារក និងឆ្អឹងអាងត្រគាករបស់ម្តាយ** ហើយការឈឺ

**ពោះសម្រាលអាចនឹងអូសបន្លាយ ឬ មានឧបសគ្គ ។**

**៣-៦-៣-២. កម្ពស់ ១៤៥-១៥០ ស.ម**

ស្ត្រីដែលមាន**កម្ពស់ ១៤៥-១៥០ស**.ម មិនត្រូវការការបញ្ជូនភ្លាមទេ ប៉ុន្តែអាចនឹងមានបញ្ហាវិសមមាត្ររវាងឆ្អឹងក្បាលទារកនិងឆ្អឹងអាងត្រគាករបស់ម្តាយ ។ ត្រូវតែតាមដានការវិវត្តនៃការសម្រាលជាប់ ជាប្រចាំជាពិសេសការចុះនៃក្បាលកូន ។

## ៣-៧. ភាពស្លេកស្លាំង

《សង្ខេប》

- ភាពស្លេកស្លាំងនៅពេលមានផ្ទៃពោះអាចបណ្តាលឱ្យស្រ្តីស្លាប់ពេលមានការធ្លាក់ឈាម ។ ហើយភាពស្លេកស្លាំងធ្ងន់ធ្ងរបង្កឱ្យមានការប្រឈមមុខខ្ពស់ទៅនឹងទារកមានទម្ងន់ទាប ។
- ពិនិត្យកំណត់ត្រាអំពីភាពស្លេកស្លាំងនៅពេលមកពិនិត្យផ្ទៃពោះជាមួយសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ។
- ពិនិត្យពណ៌លើបាតដៃ និងត្របកភ្នែក និងសញ្ញាផ្សេងទៀតនៃភាពស្លេកស្លាំង ។

### ៣-៧-១. និយមន័យនៃភាពស្លេកស្លាំងក្នុងពេលមានផ្ទៃពោះ

- **ភាពស្លេកស្លាំង** គឺជាស្ថានភាពមួយដែលចំនួន**គ្រាប់ឈាមក្រហម ឬ កម្លាំងក្នុងការចាប់យកអុកស៊ីសែននៃកោសិកាគ្រាប់ឈាមក្រហមមិនគ្រប់គ្រាន់**តាមតម្រូវការសរីរៈសាស្រ្ត[៩] ។
- អេម៉ូក្លូប៊ីននៅក្នុងកោសិកាឈាមក្រហមមានមុខងារក្នុងការចាប់យកអុកស៊ីសែន ។ តាមកត្តាសរីរៈសាស្រ្ត **កម្រិតអេម៉ូក្លូប៊ីន (Hb)** ធ្លាក់ចុះនៅពេលមានផ្ទៃពោះ ។
- ភាគច្រើននៃភាពស្លេកស្លាំងបណ្តាលពី**កង្វះជាតិដែក**[៩] ។

### ៣-៧-២. របៀបពិនិត្យភាពស្លេកស្លាំង

- ពិនិត្យសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) រកភាពស្លេកស្លាំង និងលទ្ធផលអេម៉ូក្លូប៊ីន (Hb) ។
- ពិនិត្យរោគសញ្ញា៖
  - ពិនិត្យលើភាពស្លេកស្លាំងនៅលើបាតដៃនិងត្របកភ្នែក ។
  - សួរស្រ្តីថាតើសព្វថ្ងៃមានវិលមុខ អស់កម្លាំង និងពិបាកដកដង្ហើម ឬ ទេ ។
- ប្រសិនបើមានតេស្តឈាមដោយអេម៉ូខ្យូ (Hemocue) តេស្តមើល Hb ។

## ៣-៧-៣. ចំណាត់ថ្នាក់ភាពស្លេកស្លាំងក្នុងពេលមានផ្ទៃពោះ

### ៣-៧-៣-១. ភាពស្លេកស្លាំងធ្ងន់ធ្ងរ

- **Hb តិចជាង ៧.០ក្រាម/ដេស៊ីលីត្រ** ត្រូវបានគេឱ្យនិយមន័យថាជា **ភាពស្លេកស្លាំងធ្ងន់ធ្ងរ ។**
- នៅពេលដែលស្ត្រីមានភាពស្លេកស្លាំងធ្ងន់ធ្ងរនោះគឺមានភាពស្លេកស្លាំងខ្លាំង នៅលើបាតដៃ និង/ឬលើត្របកភ្នែក ។ ស្ត្រីក៏អាចត្អូញត្អែរពីការវិលមុខអស់កម្លាំង និងពិបាកដកដង្ហើមទោះបីជានៅ ពេលសម្រាកផងដែរ ។

### ៣-៧-៣-២. ភាពស្លេកស្លាំងស្រាល

- **Hb ៧.០-១១.០ក្រាម/ដេស៊ីលីត្រ** ត្រូវបានគេឱ្យនិយមន័យថាជា **ភាពស្លេកស្លាំងស្រាល ។**
- នៅពេលដែលស្ត្រីមានភាពស្លេកស្លាំងស្រាលនោះគឺអាចមានភាពស្លេកស្លាំងនៅបាតដៃ និង/ឬលើត្របកភ្នែក។

## ៣-៧-៤. ផលវិបាកនៃភាពស្លេកស្លាំង

### ៣-៧-៤-១. ភាពស្លេកស្លាំងខ្លាំងនៅលើបាតដៃ និង/ឬលើត្របកភ្នែក ឬ Hb តិចជាង ៨.០ក្រាម/ដេស៊ីលីត្រ

- ភាពស្លេកស្លាំងនៅក្នុងអំឡុងពេលមានផ្ទៃពោះកាត់បន្ថយឱកាសរស់រាននៅពេលស្ត្រីមានការធ្លាក់ឈាម នៅក្នុងកំឡុងពេលសម្រាលនិងក្រោយពេលសម្រាល[១] ។ ក្នុងករណីមានការធ្លាក់ឈាមក្រោយសម្រាល ស្ត្រីដែលមានភាពស្លេកស្លាំងធ្ងន់ធ្ងរត្រូវការការព្យាបាលបន្ថែមដូចជាការ**បញ្ចូលឈាម** ។
- ភាពស្លេកស្លាំងធ្ងន់ធ្ងរក្នុងកំឡុង ពេលមានផ្ទៃពោះបង្កើនការប្រឈមមុខទៅនឹង**ទារកកើតមកមានទម្ងន់ទាប** ។

### ៣-៧-៤-២. ភាពស្លេកស្លាំងនៅលើបាតដៃ និង/ឬលើត្របកភ្នែក ឬ Hb ៨.០-១១.០ក្រាម/ដេស៊ីលីត្រ

- ទោះបីជាមានភាពស្លេកស្លាំងស្រាលស្ត្រីក៏ពិបាកក្នុងការធ្វើឱ្យមានភាព ប្រសើរឡើងវិញដែរក្រោយពីបាត់បង់ឈាមនៅក្នុងកំឡុងពេលសម្រាល ។
- ការសង្កេតស្ថានភាពធ្លាក់ឈាមជាប្រចាំ គឺដើម្បីតាមដានភាពមិនប្រក្រតីនៃការធ្លាក់ឈាម និងអាចធ្វើការបញ្ជូនទាន់ពេលវេលា ។

**សម្គាល់៖ ហេតុផលនៅពីក្រោយការបញ្ជូន**

- ការបញ្ជូនត្រូវធ្វើឡើងនៅពេលដែល Hb តិចជាង ៨.0 ក្រាម/ដេស៊ីលីត្រ ដែលខ្ពស់ជាង និយមន័យ នៃភាពស្លេកស្លាំងធ្ងន់ធ្ងរ (Hb តិចជាង ៧.0ក្រាម/ដេស៊ីលីត្រ) (មើល *ពិធីសារជាតិគ្រប់គ្រង គ្លីនិកមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព*[9] ទំព័រ២៧) ដោយផ្អែកទៅលើការ ពិភាក្សាជាមួយគ្រូបង្គោលស្នូលរបស់ការបណ្ដុះបណ្ដាលការថែទាំក្នុងពេលសម្រាល ។
- នេះគឺដោយសារតែការរស់រានរបស់ស្ត្រីមានការប្រឈមមុខនៅពេលកម្រិតអេម៉ូក្លូប៊ីន នៅត្រឹម ៧.0 ក្រាម/ដេស៊ីលីត្រ នៅពេលដែលស្ត្រីមានការធ្លាក់ឈាមធ្ងន់ធ្ងរ ។ នៅមណ្ឌលសុខភាព ស្ត្រីគួរត្រូវបានគេបញ្ជូនទុកជាមុន ។

### ៣-៨-១. ការបង្ករោគ- មេរោគអេដស៍ (HIV)

《**សង្ខេប**》

- មេរោគអេដស៍អាចឆ្លងពីម្ដាយទៅកូនតាមរយៈ (១)ឆ្លងតាមសុក (២)ឆ្លងនៅពេលសម្រាលតាមផ្លូវសម្រាល និង (៣)ឆ្លងតាមការបំបៅដោះកូន ។ មូលហេតុចំបងនៃការចម្លងរោគអេដស៍ពីម្ដាយទៅលើកូនគឺការចម្លង ពីម្ដាយទៅកូនក្នុងកំឡុងពេលសម្រាល ។
- ពិនិត្យលទ្ធផលតេស្តមេរោគអេដស៍នៅ ពេលមកពិនិត្យផ្ទៃពោះ ដែលមាននៅក្នុង*សៀវភៅសុខភាពមាតា* (សៀវភៅពណ៌ផ្កាឈូក) ។
- ប្រសិនបើគ្មានការសរសេរពីលទ្ធផលរកមេរោគអេដស៍ទេ ត្រូវធ្វើតេស្តភ្លាមជាមួយនឹងតេស្តរហ័ស ដែលពិនិត្យបានទាំងមេរោគអេដស៍ និងស្វាយ ។
- ប្រសិនបើលទ្ធផលរកមេរោគអេដស៍វិជ្ជមាន ហើយការសម្រាលមិនទាន់ជិតដល់ទេ ត្រូវបញ្ជូនស្ត្រីទៅកាន់ កន្លែងដែលមាន ART ដើម្បីទទួលបាន ការព្យាបាលដោយថ្នាំអង់ទីរីត្រូវីរ៉ល់ (ART) ។
- ប្រសិនបើមិនដឹងពីមេរោគអេដស៍ ហើយការសម្រាលជិតមកដល់ ត្រូវធ្វើការបញ្ជូនស្ត្រី និងកូនទៅកាន់កន្លែង ដែលមាន ART បន្ទាប់ពីសម្រាល សម្រាប់ការទទួលបាន ART ។

**៣-៨-១-១. អ្វីទៅជាមេរោគអេដស៍?**

- មេរោគអេដស៍ (HIV) គឺជាវីរុសដែលបង្កឱ្យប្រព័ន្ធភាពស៊ាំរបស់មនុស្សចុះខ្សោយ ដែលធ្វើឱ្យមានការពិបាកក្នុងការឆ្លើយតបទៅនឹងការបង្កមេរោគផ្សេងទៀត[៩] ។

**៣-៨-១-២. មធ្យោបាយដើម្បីដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍**

- បើកមើលទំព័រ 'ធ្វើតេស្តរកមេរោគអេដស៍' និង 'ព័ត៌មានផ្នែកសម្ភព' នៃសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ។
- ប្រសិនបើមិនដឹងទេ ផ្តល់ប្រឹក្សានិងសុំការអនុញ្ញាត រួចធ្វើតេស្តរហ័សដែលពិនិត្យបានទាំងមេរោគអេដស៍ និងស្វាយ[១១] ។

**៣-៨-១-៣. ផលវិបាកសម្រាប់ម្តាយដែលមានតេស្តមេរោគអេដស៍ វិជ្ជមាន**

៣-៨-១-៣-១. ម្តាយដែលមានតេស្តមេរោគអេដស៍វិជ្ជមាន

- មេរោគអេដស៍អាចឆ្លងពីម្តាយទៅកូនតាមរយៈ (១)ឆ្លងតាមសុក (២)ឆ្លងនៅពេលសម្រាលតាមផ្លូវសម្រាល និង (៣)ឆ្លងតាមការបំបៅដោះកូន ។ មូលហេតុចំបងនៃការចម្លងរោគអេដស៍ ពីម្តាយទៅលើកូនគឺការចម្លងពីម្តាយទៅកូនក្នុងកំឡុងពេលសម្រាល[៦]។
- ស្ត្រីដែលមានផ្ទុកមេរោគអេដស៍គួរតែសម្រាលកូននៅមន្ទីរពេទ្យបង្អែក ឬមន្ទីរពេទ្យខេត្ត (កន្លែង ដែលមាន ART) ដែលជាកន្លែងអាចផ្តល់ ថ្នាំ ARV ដល់ម្តាយនិង កូនបានត្រឹមត្រូវ [១១]។

៣-៨-១-៣-២. ករណីមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍

- រាល់ស្ត្រីដែលមិនដឹងថាមានផ្ទុកមេរោគអេដស៍ ឬ ក៏អត់ ត្រូវធ្វើ**តេស្តរហ័ស ដែលពិនិត្យបានទាំងមេរោគអេដស៍ និង ស្វាយភ្លាម ។** ប្រសិនបើជិតសម្រាលហើយ ត្រូវធ្វើតេស្តបន្ទាប់ពីសម្រាលឱ្យបានលឿនតាមតែអាចធ្វើបាន ។
- ករណីតេស្តចេញមក '**មានប្រតិកម្ម**' (**Reactive**) ត្រូវធ្វើការបញ្ជូនស្ត្រី ទៅកាន់កន្លែងដែលមាន ART ប្រសិនបើស្ត្រីមិនទាន់ជិតសម្រាល ។ ប្រសិនស្ត្រីជិតសម្រាលត្រូវបញ្ជូនស្ត្រី និងទារកទើប នឹងកើតរបស់គាត់ទៅកាន់កន្លែងដែលមាន ART បន្ទាប់ពីសម្រាលរួច ។

**សម្គាល់៖**

ពេលធ្វើការសម្រាលកូនឱ្យម្តាយដែលមានមេរោគអេដស៍ 'វិជ្ជមាន' 'មានប្រតិកម្ម' ឬ មិនដឹងត្រូវគោរព តាម**គោលការណ៍ការពារជាសកល** ដើម្បីធានាបាននូវការពារពីប៉ះពាល់ឈាមដែល មានមេរោគអេដស៍ ដូចជា ការ**ពាក់អាវប្លាស្ទិចការពារ វ៉ែនតាការពារ ម៉ាស់ មួក និងស្បែកជើងកវែង ក្នុងកំឡុងពេលសម្រាល** ។ សម្រាប់ព័ត៌មានបន្ថែមមើល *គោលការណ៍ណែនាំជាតិ ស្តីពីការការពារការចម្លង HIV និងមេរោគស្វាយពី ម្តាយទៅកូន* ទំព័រ៣៣[១១] ។

## ៣-៨-២. ការបង្ករោគ - មេរោគស្វាយ

《**សង្ខេប**》

- មេរោគស្វាយអាចឆ្លងពីម្តាយទៅកូនក្នុងផ្ទៃតាមរយៈសុក ។ ការព្យាបាលដែលទៀងទាត់ជាមួយនឹងថ្នាំអង់ទីប៊ីយ៉ូទិក (ប៉េនីសស៊ីលីន)នៅត្រីមាសទី ១ គឺមានប្រសិទ្ធភាពក្នុងការការពារការឆ្លងមេរោគពីម្តាយទៅកូនក្នុងផ្ទៃ ។
- ករណីមិនបានព្យាបាលមេរោគស្វាយនៅពេលដែលគភ៌មានអាយុប្រមាណជា ១៤ សប្តាហ៍ទេ ការប្រឈមមុខនឹងការបង្ករោគលើកូនមានការកើនឡើងជាមួយអាយុគភ៌ ។ ទារកស្លាប់ក្នុងពោះ និងការកើតមុនសម្រាល ទារកទើបនឹងកើតមានទម្ងន់ទាបដោយសារតែមានការរិតត្បៀតលើការលូតលាស់អាចនឹងកើតមាន ។
- ពិនិត្យលទ្ធផលតេស្តមេរោគស្វាយនៅពេលមកពិនិត្យផ្ទៃពោះជាមួយសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ។
- ប្រសិនបើគ្មានការសរសេរពីលទ្ធផលរកមេរោគស្វាយទេ ត្រូវធ្វើតេស្តភ្លាមជាមួយ តេស្តរហ័សដែលពិនិត្យបានទាំងមេរោគអេដស៍ និងស្វាយ ។
- ប្រសិនបើលទ្ធផលរកមេរោគស្វាយ '**មានប្រតិកម្ម (Reactive)**' ហើយការសម្រាលមិនទាន់ជិតដល់ទេ ត្រូវបញ្ជូនស្ត្រីទៅមន្ទីរពេទ្យខេត្តដើម្បីទទួលបានការព្យាបាល ។
- ប្រសិនបើមិនដឹងពីមេរោគស្វាយ ហើយការសម្រាលជិតមកដល់ត្រូវធ្វើការបញ្ជូនស្ត្រីទៅមន្ទីរពេទ្យខេត្តបន្ទាប់ពីសម្រាលរួចដើម្បីទទួលបានការព្យាបាលទាំងម្តាយនិងទារក ទើបកើត ។

**៣-៨-២-១. អ្វីទៅជាមេរោគស្វាយ?**

- មេរោគស្វាយគឺជា**ការបង្ករោគដែលឆ្លងតាមរយៈការរួមភេទ** និងបង្កឡើងដោយបាក់តេរីឈ្មោះ 'Treponema pallidum' ។ ការចម្លងបង្កឡើងដោយការប៉ះពាល់ ដំបៅមេរោគស្វាយ (Chancre) ។

**៣-៨-២-២. មធ្យោបាយដើម្បីដឹងពីមេរោគស្វាយ**

- បើកទំព័រ 'ព័ត៌មានផ្នែកសម្ភព' របស់សៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ។
- ប្រសិនបើមិនដឹងថាមានមេរោគស្វាយទេផ្តល់ការប្រឹក្សា និងសុំការអនុញ្ញាតរួចធ្វើតេស្តរហ័សដែលពិនិត្យបានទាំងមេរោគអេដស៍ និងស្វាយ ។
- ប្រសិនបើលទ្ធផលតេស្តរកឃើញថាមាន **'ប្រតិកម្ម (Reactive)'** បញ្ជូនស្ត្រីទៅកាន់មន្ទីរពេទ្យខេត្ត ដើម្បីបញ្ជាក់លទ្ធផល ('វិជ្ជមាន' ឬ 'អវិជ្ជមាន') ជាមួយនឹងតេស្ត RPR ។

**៣-៨-២-៣. ផលវិបាកចំពោះម្តាយដែលមានមេរោគស្វាយវិជ្ជមាន**

៣-៨-២-៣-១.ការប្រឈមមុខនឹងមេរោគស្វាយវិជ្ជមាន

- មេរោគស្វាយអាចឆ្លងពីម្តាយទៅកូនក្នុងផ្ទៃ**តាមរយៈសុក**។ការព្យាបាលដែលទៀងទាត់ជាមួយនឹងថ្នាំអង់ទីប៊ីយ៉ូទិក (**ប៉េនីសស៊ីលីន**) **នៅត្រីមាសទី ១** គឺមានប្រសិទ្ធភាព ក្នុងការការពារការឆ្លង មេរោគពីម្តាយទៅកូនក្នុងផ្ទៃ ។
- ករណីមិនបានព្យាបាលមេរោគស្វាយនៅពេល**ដែលគភ៌មានអាយុប្រមាណជា ១៤ សប្តាហ៍ទេ** ការប្រឈមមុខនឹងការបង្ករោគលើកូនមានការកើនឡើងជាមួយអាយុគភ៌[១៥] ដែលអាចបណ្តាលឱ្យ **ទារកស្លាប់ក្នុងផ្ទៃ និងការសម្រាលមិនគ្រប់ខែ** ។ ទារកទើបនឹងកើតអាចនឹងមានទម្ងន់ ទាប ដោយសារតែមានការរិតត្បៀតលើការលូតលាស់ ហើយអាចនឹង**មានជំងឺស្វាយពីកំណើត ។**
- ប្រសិនបើស្ត្រីមានមេរោគស្វាយវិជ្ជមានស្ត្រីគួរត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យខេត្ត ពីព្រោះគ្រប់ ទារកទើបនឹងកើតទាំងអស់ត្រូវព្យាបាលជាមួយថ្នាំអង់ទីប៊ីយ៉ូទិក បើទោះជាម្តាយបានទទួលការព្យាបាលមេរោគស្វាយ ឬអត់ ក្នុងកំឡុងពេលមានផ្ទៃពោះក៏ដោយ[១(p១១២)] ។

៣-៨-២-៣-២.ករណីមិនដឹងថាមានមេរោគស្វាយ

- គ្រប់ស្ត្រីដែលមិនដឹងថាមានមេរោគស្វាយត្រូវផ្តល់តេស្តរហ័សដែលពិនិត្យបានទាំងមេរោគអេដស៍ និងស្វាយភ្លាម ។ ប្រសិនបើស្ត្រីជិតសម្រាលត្រូវធ្វើតេស្តឱ្យបានលឿនបន្ទាប់ពីសម្រាលតាមដែលអាចធ្វើទៅបាន ។
- នៅពេលដែលលទ្ធផលមាន **'ប្រតិកម្ម'** បញ្ជូនម្តាយទៅកាន់មន្ទីរពេទ្យខេត្តប្រសិនបើការសម្រាលមិនទាន់ជិតមកដល់ ។ ប្រសិនបើការសម្រាលជិតមកដល់ បញ្ជូនស្ត្រីនិងទារកទើបកើតទៅកាន់មន្ទីរពេទ្យ

ខេត្តបន្ទាប់ពីសម្រាល ។

### ៣-៩-១. ប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន - ការធ្លាក់ឈាមមុនសម្រាល

《**សង្ខេប**》

- ស្ត្រីដែលមានការធ្លាក់ឈាមក្នុងអំឡុងពេលមានផ្ទៃពោះអាចនឹងមានសុកពាំងនៅក្បែរមាត់ស្បូន ឬនៅផ្នែកខ្លះនៃមាត់ស្បូន ។
- ពិនិត្យកំណត់ត្រាការថែទាំផ្ទៃពោះមុនសម្រាលក្នុងសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក) ឬសួរស្ត្រីដើម្បីឱ្យដឹងថាតើស្ត្រីមានការធ្លាក់ឈាមមិនធម្មតានៅពេលអាយុនៃគត៌ច្រើនឬទេ ។

#### ៣-៩-១-១. ពិនិត្យមើលប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន

- អានសៀវភៅសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក)ដោយប្រុងប្រយ័ត្នត្រង់'ការពិនិត្យផ្ទៃពោះ' សម្រាប់មើលការធ្លាក់ឈាមតាមទ្វារមាសនៅពេលគភ៌មានអាយុច្រើន ។
- ប្រសិនគ្មានការកត់ត្រាទេអ្នកអាចសួរម្តាយពីការធ្លាក់ឈាមមិនធម្មតានៅពេលគភ៌មានអាយុច្រើន ។

#### ៣-៩-១-២. មូលហេតុដែលអាចនឹងមាននៅពីក្រោយការធ្លាក់ឈាមមុនពេលសម្រាល

- ម្តាយដែលមានការធ្លាក់ឈាមមុនពេលសម្រាលអាចមាន **សុកពាំងនៅក្បែរឬនៅផ្នែកខ្លះនៃមាត់ ស្បូន** ដែលអាចនាំឱ្យមានការធ្លាក់ឈាមក្នុងកំឡុង ពេលសម្រាល ឬ បន្ទាប់ពីសម្រាល ។

### ៣-៩-២. ប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន - ការលើសសម្ពាធឈាម

《**សង្ខេប**》

- ប្រសិនបើម្តាយមានប្រវត្តិសម្ពាធឈាមលើសក្នុងកំឡុងការថែទាំផ្ទៃពោះមុនពេលសម្រាលនោះគឺអាចនឹងមានជំងឺបម្រុងក្រឡាភ្លើង ឬ ក្រឡាភ្លើង ឬ វិបត្តិជំងឺលើសសម្ពាធឈាមដទៃទៀត ។
- ពិនិត្យកំណត់ត្រាការថែទាំផ្ទៃពោះមុនពេលសម្រាលក្នុងសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក) ដើម្បីឱ្យដឹងពីសម្ពាធឈាមក្នុងកំឡុងពេលមានផ្ទៃពោះ។

#### ៣-៩-២-១. ពិនិត្យប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន

- ពិនិត្យសម្ពាធឈាម (BP) ក្នុងកំណត់ត្រាការថែទាំការមានផ្ទៃពោះមុនពេលសម្រាលនិមួយៗ ក្នុងសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក) ។

### ៣-៩-២-២. ហេតុផលដែលអាចទៅរួចនៅក្រោយប្រវត្តិការលើសសម្ពាធឈាម

- ប្រសិនបើម្តាយមានប្រវត្តិសម្ពាធឈាមលើសក្នុងកំឡុងការថៃទាំផ្ទៃពោះមុនពេលសម្រាលនោះ គឺអាចនឹងមានជំងឺបម្រុងក្រឡាភ្លើង ឬ ក្រឡាភ្លើង ឬ វិបត្តិជំងឺលើសសម្ពាធឈាមដទៃទៀត ។
- ប្រសិនស្រ្តីមានការលើសសម្ពាធឈាមកម្រិតធ្ងន់ធ្ងរក្នុងកំឡុងការថៃទាំផ្ទៃពោះមុនពេលសម្រាល ត្រូវបញ្ជូនស្រ្តីភ្លាម ។
- ប្រសិនបើស្រ្តីមានការលើសសម្ពាធឈាមកម្រិតមធ្យមក្នុងកំឡុងការថៃទាំផ្ទៃពោះមុនពេលសម្រាល ត្រូវវាស់សម្ពាធឈាមឡើងវិញ និងរកមើលសញ្ញាដទៃទៀតនៃជំងឺក្រឡាភ្លើង (មើល *៦. សង្កេតស្ថានភាពម្តាយ ៦-១ សម្ពាធឈាម* ទំព័រ៩៥) ។

## ៣-១០. ប្រវត្តិនៃការសម្រាលនៃផ្ទៃពោះមុន

《**សង្ខេប**》
- ប្រសិនបើមានបញ្ហាអំឡុងពេលមានផ្ទៃពោះ ឬ សម្រាលពីមុន វាអាចកើតមានម្តងទៀត ឬ ប៉ះពាល់ដល់ការមានផ្ទៃពោះ និងការវិវត្តការសម្រាលបច្ចុប្បន្ន ។
- ពិនិត្យសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក) ឬ សួរស្ត្រីថាតើគាត់មានបញ្ហាការសម្រាលកូនពីមុន ឬ ទេ ។

### ៣-១០-១. ពិនិត្យប្រវត្តិនៃការសម្រាលនៃផ្ទៃពោះមុន

- ពិនិត្យសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក)ទំព័រ 'បញ្ហាសុខភាពពីមុន' ។
- នៅពេលដែលមិនមានព័ត៌មានណាមួយ ប្រមូលព័ត៌មានលំអិតពីម្តាយ ឬ គ្រួសារស្ត្រី៖
  (១) ប្រវត្តិធ្លាប់សម្រាលពីមុន ដោយប្រើប្រាស់ឧបករណ៍ជំនួយដូចជា**ដង្កៀប ឬ បូម** ។
  (២) ប្រវត្តិលើសសម្ពាធឈាមពេលមានផ្ទៃពោះពីមុន ។
  (៣) ទម្ងន់កូនពេលកើត ។
  (៤) ប្រវត្តិទារកស្លាប់ក្នុងពេលសម្រាល ឬ នៅថ្ងៃដំបូងបន្ទាប់ពីសម្រាល ។
- ពិនិត្យប៉េរីណេរកមើល ផ្លែ ដុះសាច់/សិរមាន់ ឬស្នាមរបួស ។
- ពិនិត្យមើលពោះរកមើល ស្នាមវះកាត់យកកូនពីមុន ។

### ៣-១០-២. ផលវិបាកនៃភាពមិនធម្មតានៃការសម្រាលកូនមុន

- ការសម្រាលកូនមុនដោយប្រើ**ដង្កៀប**ឬបូមបញ្ជាក់ថាមានបញ្ហាណាមួយពីម្តាយ ទារក ឬ ការវិវត្តការសម្រាល ។
- **ផ្លែ ដុះសាច់/សិរមាន់ ឬស្នាមរបួស**នៅប៉េរីណេអាចរាំងស្ទះការវិវត្តការសម្រាលនៅពេលក្បាលកូនចេញក្រៅ ។ ប្រសិនបើមានផ្លែ ដុះសាច់/សិរមាន់ ឬ ស្នាមរបួសទាំងនោះរាំងស្ទះការវិវត្តការសម្រាល បច្ចុប្បន្នត្រូវធ្វើការ**កាត់ទ្វារមាស (Episiotomy)** ។
- ប្រវត្តិនៃ**ការប្រកាច់ ជំងឺក្រឡាភ្លើង និងបម្រុងក្រឡាភ្លើង**អាចកើតឡើងម្តងទៀត ។

- ការសម្រាលមុនដោយ**ការវះកាត់**អាចបញ្ជាក់ថាស្បូនមានស្នាមដោយការវះកាត់ ។ វាធ្វើឱ្យមានការប្រឈមមុខខ្ពស់ទៅនឹង**សុកពាំងមាត់ស្បូន** និង**ការជាប់សុកនៅក្នុងស្បូន ។** នៅពេលដែល ម្ដាយកំពុងឈឺពោះសម្រាលកូននៅផ្ទៃពោះបច្ចុប្បន្ន នោះការរហែកស្បូនអាចនឹងកើតមាន ត្រង់ស្បូនដែលមានស្នាម ។
- ប្រវត្តិទារកតូចបញ្ជាក់ថា**កូនកើតមិនគ្រប់ខែ ឬ មានទម្ងន់ទាបតែគ្រប់ខែ**សម្រាប់មូល ហេតុមួយចំនួន ។ **កូនស្លាប់ក្នុងពោះ ឬ ស្លាប់នៅក្នុងថ្ងៃដំបូង**ក៏បញ្ជាក់ពីបញ្ហាក្នុងពេលមានផ្ទៃពោះ ឬ ការសម្រាលកូនដែរ ។

## ៣-១១. ប្រវត្តិជំងឺទូទៅ

《**សង្ខេប**》

- ប្រវត្តិជំងឺទូទៅខ្លះអាចប៉ះពាល់ដល់កូនក្នុងផ្ទៃឬផ្តល់ផលអាក្រក់ដល់ការមានផ្ទៃពោះ ។
- ពិនិត្យសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក) ឬ សួរស្ត្រីថាតើគាត់ មានប្រវត្តិជំងឺទូទៅពីមុនពេលមានផ្ទៃពោះបច្ចុប្បន្នឬទេ ។

### ៣-១១-១. ពិនិត្យប្រវត្តិជំងឺទូទៅ

- ដំបូងពិនិត្យសៀវភៅសុខភាពមាតា(សៀវភៅពណ៌ផ្កាឈូក) ទំព័រ 'បញ្ហាសុខភាពពីមុន' ។
- នៅពេលដែលមិនមានព័ត៌មានក្នុងសៀវភៅ សួរស្ត្រីឬគ្រួសារស្ត្រីថាតើគាត់មានបញ្ហាសុខភាព មុនពេលមានផ្ទៃពោះបច្ចុប្បន្នឬទេ ។

### ៣-១១-២. ផលវិបាកដោយសារប្រវត្តិជំងឺទូទៅ

- ប្រវត្តិ**ជំងឺទឹកនោមផ្អែមមុនពេលមានផ្ទៃពោះ**គួរត្រូវបានគ្រប់គ្រងផលវិបាកដែលកើតមានក្នុងពេលមានផ្ទៃពោះហើយចាំបាច់ត្រូវការការគ្រប់គ្រងកម្រិតជាតិស្ករឱ្យបានត្រឹមត្រូវនិង/ឬការព្យាបាលបន្ថែមទៀត ។ ទារកក្នុងផ្ទៃអាចនឹងធំ និងអាចបណ្តាលឱ្យ**សម្រាលជាប់ស្មា**។
- ប្រវត្តិ**ជំងឺផ្លូវដង្ហើម ឬ ជំងឺបេះដូងមុនពេលមានផ្ទៃពោះ** អាចនឹងផ្តល់ផលអាក្រក់ដល់ផ្ទៃពោះ ។ នៅពេល ដែល មានបញ្ហាផ្លូវដង្ហើម ឬ បេះដូងនោះអាចប៉ះពាល់ទារកក្នុងផ្ទៃដូចជា**ទារកលូតលាស់មិនល្អ ឬ សម្រាលមិនគ្រប់ខែ** ។

# ជំពូកទី៤ ការសង្កេតមើលស្ថានភាពទារកក្នុងផ្ទៃ

**សង្ខេប**

- វត្ថុបំណងនៅក្នុងជំពូកនេះគឺ (១) កំណត់សណ្ឋានទម្រង់បង្ហាញ និងការបង្ហាញរបស់ទារកដើម្បីបង្ការផលវិបាកក្នុងកំឡុងពេលឈឺពោះសម្រាល និង (២) កំណត់ស្ថានភាពទារកថាទារកស្ថិតក្នុងស្ថានភាពបន្ទាន់ឬអត់ ។
- សណ្ឋានរបស់ទារក ទម្រង់បង្ហាញរបស់ទារក និងការបង្ហាញរបស់ទារក គួរតែស្ថិតក្នុងសភាពធម្មតាសម្រាប់ដំណើរការវិវត្តនៃការឈឺពោះសម្រាលធម្មតា ។
- សណ្ឋានរបស់ទារក ទម្រង់បង្ហាញរបស់ទារក និងការបង្ហាញរបស់ទារក អាចពិនិត្យឃើញតាមរយៈការស្ទាបពោះ និងការលូកពិនិត្យទ្វារមាស ។
- ភាពមិនធម្មតានៃសណ្ឋាន និងទម្រង់បង្ហាញរបស់ទារកអាចជាលទ្ធផលនៃការឈឺពោះសម្រាល ដែលមានឧបសគ្គ ឬ បញ្ឈប់ការវិវត្តនៃការឈឺពោះ និងការធ្លាក់ទងសុកមុនសម្រាល ច្រើនតែកើតមាន ។
- ស្ថានភាពសុខភាពរបស់ទារកក្នុងអំឡុងពេលសម្រាល គឺជាការវាយតម្លៃលើចង្វាក់បេះដូងទារកពណ៌ទឹកភ្លោះ និងចលនារបស់ទារកក្នុងផ្ទៃ ។
- ក្នុងកំឡុងពេលស្បូនកន្ត្រាក់ ជាញឹកញាប់កូនទទួលបានអុកស៊ីសែនទាប ។ ទោះបីជាការឈឺពោះសម្រាលនោះធម្មតាក៏ដោយ ក៏វាជាការលំបាកមួយសម្រាប់ទារកក្នុងផ្ទៃម្តាយផងដែរ ។
- ដូច្នេះការបញ្ជាក់ថាទារកក្នុងផ្ទៃមានសុខភាពល្អ ឬ ខ្សោយក្នុងកំឡុងពេលឈឺពោះសម្រាលមានសារៈសំខាន់ណាស់ ។
- ចង្វាក់បេះដូងរបស់ទារកគឺជាសូចនាករដ៏ជាក់លាក់មួយក្នុងការបញ្ជាក់ពីស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃ ។

# ៤-១. សណ្ឋាន ទម្រង់បង្ហាញ និងការបង្ហាញរបស់ទារក

## ៤-១-១. សណ្ឋាន និង ទម្រង់បង្ហាញរបស់ទារក

《**សង្ខេប**》
- សណ្ឋានរបស់ទារកគឺជាបែបដែលកូនសណ្ដូកនៅក្នុងស្បូន ។
- កូនគួរតែមានសណ្ឋានស្របជាមួយអ័ក្សរបស់ស្បូនចំពោះការវិវត្តការឈឺពោះសម្រាលធម្មតា ។
- ទម្រង់បង្ហាញរបស់ទារកគឺជាផ្នែកមួយនៃរាងកាយទារកបង្ហាញមុនគេបង្អស់នៅក្នុងផ្លូវសម្រាល ។
- នៅពេលដែលទារកមានសណ្ឋានស្របជាមួយអ័ក្សរបស់ស្បូន ក្បាលទារក(ពិសេសគឺបង្ហើយតូច) ត្រូវបង្ហាញមុនគេសម្រាប់ការឈឺពោះសម្រាលធម្មតា ។ ពិនិត្យមើលសណ្ឋានទារក និងទម្រង់បង្ហាញរបស់ទារកដោយការស្ទាបពោះ និងការលូកពិនិត្យទ្វារមាស ។
- គេអាចប៉ាន់ប្រមាណត្រង់កន្លែងដែលគេប៉ះក្បាលកូន (រឹងនិងមូល) និងខ្នង (មានរូបរាងរឹង និងរលោងធំ នៅមួយជំហៀង) នៅលើពោះរបស់ម្ដាយ ។
- ភាពមិនធម្មតានៃសណ្ឋានទារកនិងទម្រង់បង្ហាញរបស់ទារកមិនអាចគ្រប់គ្រងបាននៅថ្នាក់មណ្ឌលសុខភាពនោះទេព្រោះវាអាចនាំឱ្យមានការឈឺពោះសម្រាលមានឧបសគ្គ និងបញ្ឈប់ការវិវត្តនៃការឈឺពោះ សម្រាលនិងការចេញទងសុកមុនពេលទារកកើត ។

### ៤-១-១-១. និយមន័យសណ្ឋានទារក

- **សណ្ឋាន**ទារកគឺមានទំនាក់ទំនងរវាង**អ័ក្សរបស់ទារក** និង**អ័ក្សរបស់ស្បូន** ។

### ៤-១-១-២. និយមន័យទម្រង់បង្ហាញរបស់ទារក

- **ទម្រង់បង្ហាញរបស់ទារក**គឺជាផ្នែកមួយនៃរាងកាយទារក**បង្ហាញមុនគេនៅក្នុងផ្លូវសម្រាល** ។

### ៤-១-១-៣. ការចាត់ថ្នាក់សណ្ឋានទារក និងទម្រង់បង្ហាញរបស់ទារក

៤-១-១-៣-១. សណ្ឋានបណ្តោយស្បូន ទទឹងពោះ និងបញ្ឆិតពោះ

- នៅពេលដែលអ័ក្សរបស់ទារកស្របនឹងអ័ក្សស្បូនរបស់ម្តាយ នោះគឺមានន័យថាកូនស្ថិតក្នុងសណ្ឋានបណ្តោយស្បូន (រូបភាពទី**៤A**) ។




រូបភាពទី**៤A** សណ្ឋានបណ្តោយស្បូន
ប្រភពរូបភាព: *Myles Textbook for midwives*. 16th ed.

- នៅពេលដែលអ័ក្សរបស់ទារកស្ថិតនៅទទឹងនឹងអ័ក្សរបស់ស្បូនម្តាយ នោះត្រូវបានគេហៅថាសណ្ឋាន **ទទឹងពោះ** ។ នៅពេលដែលអ័ក្សរបស់កូនស្ថិតនៅបញ្ឆិតនឹងអ័ក្សរបស់ស្បូន នោះគឺមានន័យថាទារកស្ថិតនៅក្នុងសណ្ឋាន**បញ្ឆិតពោះ** (រូបភាពទី**៤B**) ។




រូបភាពទី**៤B** សណ្ឋានទទឹងពោះនិងបញ្ឆិតពោះ
ប្រភពរូបភាព: *Myles Textbook for midwives.* 16th ed.

៤-១-១-៣-២. ទម្រង់បង្ហាញកំពូលក្បាល បង្ហើយធំ ហុចថ្ងាស និងហុចមុខ (រូបភាពទី៤C)

- នៅពេលដែលក្បាលរបស់ទារកបង្ហាញគឺជាទម្រង់បង្ហាញ**ក្បាល** ។
- ការបង្ហាញក្បាលត្រូវបានគេចាត់ថ្នាក់ចូលទៅក្នុង **ទម្រង់បង្ហាញកំពូលក្បាល ទម្រង់ហុចបង្ហើយធំទម្រង់ហុចថ្ងាស និង ទម្រង់ហុចមុខ** ។
- នៅពេលក្បាលទារកបង្ហាញផ្នែកខាងក្រោយ(បង្ហើយតូច) នោះគឺជា**ទម្រង់បង្ហាញកំពូលក្បាល** ។
- នៅពេលក្បាលទារកបង្ហាញផ្នែកខាងមុខ (បង្ហើយធំ) នោះគឺជា**ទម្រង់បង្ហាញបង្ហើយធំ** ។
- នៅពេលដែលបង្ហាញផ្នែកខាងមុខនៃក្បាលនិង/ឬថ្ងាសទារកនោះគឺជា**ទម្រង់ហុចថ្ងាស** ។
- នៅពេលដែលទារកបង្ហាញ**មុខ** នោះគឺ**ទម្រង់ហុចមុខ** ។




**រូបភាពទី៤C ទម្រង់បង្ហាញកំពូលក្បាល បង្ហើយធំ ហុចថ្ងាស និងហុចមុខ**
ប្រភពរូបភាព៖ ទម្រង់បង្ហាញកំពូលក្បាល ហុចថ្ងាស និងហុចមុខ៖ *Myles Textbook for midwives.* 16th ed.
បង្ហើយធំ៖ https://slideplayer.com/slide/7070627/

៤-១-១-៣-៣. ទម្រង់ហុចគូទ និងទម្រង់ហុចស្មា (រូបភាពទី៤D)




**រូបភាពទី៤D ទម្រង់ហុចគូទ និងទម្រង់ហុចស្មា**
ប្រភពរូបភាព៖ *Myles Textbook for midwives.* 16th ed.

- នៅពេលដែលទារកបង្ហាញជើង ជង្គង់ ឬត្រគាករបស់កូន នោះគឺ **ទម្រង់ហុចគូទ ។**
- នៅពេលដែលទារកបង្ហាញស្មា នោះគឺជា**ទម្រង់ហុចស្មា** ។

### ៤-១-១-៣-៤. ទម្រង់ដៃទូលក្បាល និងទម្រង់ធ្លាក់ដៃ (រូបភាពទី៤F)

- ពេលដែល**ដៃទារកធ្លាក់មកជាមួយនឹងផ្នែកនៃការបង្ហាញ**[៩] នោះគឺជា**ទម្រង់ដៃទូលក្បាល** ។
- ពេលដែលដៃទារកម្ខាងធ្លាក់ចេញពីស្បូន នោះគឺ **ទម្រង់ធ្លាក់ដៃ** ។



**រូបភាពទី៤F ទម្រង់ដៃទូលក្បាល និងទម្រង់ធ្លាក់ដៃ**
ប្រភពរូបភាព៖ ទម្រង់ដៃទូលក្បាល *Integrated Management of Pregnancy and Childbirth, Pregnancy, Managing Complications in Pregnancy and Childbirth: A guide for midwives and doctors (2017)* WHO, S-91
ទម្រង់ធ្លាក់ដៃ https://medicalguidelines.msf.org/viewport/ONC/english/7-6-transverse-lie-and-shoulder-presentation-51417541.html




**រូបភាពទី៤G សង្ខេបសណ្ឋានទារកនិងទម្រង់បង្ហាញទារក**
ប្រភពរូបភាព៖ *Myles Textbook for midwives.* 16th ed.

### ៤-១-១-៤. របៀបដឹងពីសណ្ឋាននិងទម្រង់បង្ហាញរបស់ទារក

- ដំបូង រកសណ្ឋាន និង ទម្រង់បង្ហាញរបស់ទារកដោយការស្ទាបពោះបែបលេអូប៉ូល ។ បន្ទាប់ មកស្តាប់ចង្វាក់បេះដូងទារកនៅត្រង់កន្លែងដែលស្ទាបរកឃើញ ។

៤-១-១-៤-១. ការស្ទាបពោះបែប**លេអូប៉ូល** ( Leopold's manoeuvres )

មុនពេលចាប់ផ្តើមស្ទាបពោះ សុំឱ្យស្ត្រីបន្ទោរបង់ជើងតូចឱ្យអស់ ។ បន្ទាប់មកជួយស្ត្រីឱ្យ គេងផ្ងារ បញ្ឈរជង្គង់ ។ ការស្ទាបពោះគួរត្រូវបានធ្វើឡើងដោយថ្នមៗ ។

**តារាង៤អ: នីតិវិធីស្ទាបពោះបែបលេអូប៉ូល**

| ដាក់បាតដៃលើ | ការរកឃើញ | រោគវិនិច្ឆ័យ |
|---|---|---|
| **ជំហានទី១**: ស្ទាបកំពូលស្បូនដើម្បីប្រាកដថាជាគូទ ឬ ក្បាលនៅត្រង់កំពូលស្បូន។<br>- ឈរនៅពីមុខស្ត្រី<br>- ប្រើដៃពីរស្ទាបកំពូលស្បូនដើម្បីកំណត់ស្ថានភាពរបស់ទារក | | |
|  | ទន់ហើយរដិបរដុប (គូទ) | **ក្បាល** |
| | រឹងហើយមូល (ក្បាល) | **គូទ** |
| | មិនមានប៉ះអ្វីទាំងអស់ទទេរ | **ទទឹង** |
| **ជំហានទី២**: ស្ទាបតាមបណ្តោយ(ពោះទាំងសងខាង) ដើម្បីរកខ្នងទារក។<br>- ប្រើដៃពីរស្ទាបសងខាងពោះពីកំពូលស្បូនចុះមកផ្នែកខាងក្រោមស្បូនដើម្បីកំណត់ខ្នងទារក ។ | | |
|  | មួយចំហៀងរឹងនិងរលោងធំ | **ខ្នង** |
| | មួយចំហៀងទៀតមានផ្នែកតូចៗ រដិបរដុប និងចល័ត | **អវៈយវៈ(ដៃ ជើង)** |
| | រឹងនិងមូល(ក្បាល) | **ទទឹង** |

<table>
<tr><td colspan="3">ជំហានទី៣: ស្ទាបពោះផ្នែកខាងក្រោមពោះលើឆ្អឹងថ្ងាស ដើម្បីបញ្ជាក់ផ្នែកបង្ហាញ និងចលនារបស់ទារក ។<br>- ដាក់ដៃម្ខាងលើកំពូលស្បូន បន្ទាប់មកដាក់ម្រាមដៃនិងមេដៃនៃដៃម្ខាងទៀតលើឆ្អឹងថ្ងាសដើម្បីចាប់ផ្នែកដែលទារកបង្ហាញនៅទីនោះ ។ សង្កត់ថ្នមៗដើម្បីបញ្ជាក់ផ្នែកបង្ហាញរបស់ទារកនិងការចុះចូលក្បាលក្នុង ច្រកលើនៃអាងត្រគាក ។<br>- ប្រសិនបើផ្នែករបស់ទារកធ្វើចលនាទៅខាងលើ មានន័យថាក្បាលរបស់ទារកមិនទាន់ចុះចូលច្រកលើនៃអាងត្រគាកនោះទេ ។</td></tr>
<tr><td rowspan="2"></td><td>រឹងនិងមូល (ក្បាល)</td><td>ក្បាល</td></tr>
<tr><td>ទន់ជាងហើយរដិបរដុប (គូទ)</td><td>គូទ</td></tr>
<tr><td colspan="3">ជំហានទី៤: ស្ទាបផ្នែកខាងក្រោមពោះនៅលើឆ្អឹងថ្ងាសដើម្បីកំណត់កំរិតនៃការចុះនៃក្បាលកូន និងស្ថានភាពរបស់ក្បាល ។<br>- ឈរបែរមុខទៅចុងជើងស្ត្រី<br>- ប្រើម្រាមដៃពីរស្ទាបផ្នែកទាំងសងខាងនៅខាងក្រោមស្បូន ហើយសង្កត់ជ្រៅថ្នមៗតាមទិសដៅអ័ក្សនៃច្រកលើនៃអាងត្រគាកដើម្បីបញ្ជាក់កំរិតនៃការចុះនៃក្បាលកូននិងការបង្ហាញរបស់កូន ។<br>- ប្រសិនបើក្បាលទារកចុះចូលច្រកលើពេញលេញ នោះគឺអាចស្ទាបប៉ះក្បាលតែមួយផ្នែកតូចប៉ុណ្ណោះ ។</td></tr>
<tr><td rowspan="2"></td><td>រឹងនិងមូល (ក្បាល)</td><td>ក្បាល</td></tr>
<tr><td>ទន់ជាងហើយរដិបរដុប (គូទ)</td><td>គូទ</td></tr>
</table>

*អំឡុងពេលស្ទាបពោះបែបលេអូប៉ូល អ្នកក៏អាចរកមើលចលនារបស់ទារកក្នុងពេលជាមួយគ្នាផងដែរ។

ប្រភព៖ *ប៉ាតូក្រាហ្វសម្រាប់ការតាមដានការឈឺពោះសម្រាល*
ចែករំលែកដោយផ្នែកបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក

៤-១-១-៤-២. ការស្តាប់ចង្វាក់បេះដូងទារក

- ស្តាប់**ចង្វាក់បេះដូងទារក**ដើម្បីបញ្ជាក់ពីការរកឃើញរបស់អ្នកនូវសណ្ឋាន និងទម្រង់នៃការបង្ហាញរបស់ទារក ។
- ប្រសិនបើអ្នកអាចឮសម្លេងបេះដូងទារកខ្លាំងនៅត្រង់ផ្នែកខាងលើនៃពោះ នោះអាចជាទម្រង់ហុចគូទ (រូបភាពទី៤) ។




**រូបភាពទី៤I កន្លែងស្តាប់ចង្វាក់បេះដូងកូនដែលមានទម្រង់បង្ហាញបញ្ច្រាស់**
ប្រភពរូបភាព:http://www.open.edu/openlearncreate/mod/oucontent/view.php?id=41&printable=1

៤-១-១-៤-៣. ការលូកពិនិត្យទ្វារមាស

- ការលូកពិនិត្យទ្វារមាសគឺជាវិធីមួយទៀតដើម្បីបញ្ជាក់ពីការរកឃើញតាមការស្ទាបពោះ។ នៅពេលដែលអ្នកស្ទាបដឹងថាជាជើង ជង្គង់ ឬ ត្រគាកនោះគឺជាទម្រង់ទារកបង្ហាញ**បញ្ច្រាស់** ។ នៅពេលអ្នកស្ទាបដឹងថាមូល រលោង និងរឹងជាមួយនឹងការប៉ះថ្នេរក្បាល នោះគឺក្បាល ហើយ ជាទម្រង់បង្ហាញ**ក្បាល** ។
- **ចំពោះទម្រង់បង្ហាញក្បាល ចំណាត់**ថ្នាក់បន្ថែមទៀតតាមរយៈការលូកពិនិត្យទ្វារមាសមាន៖

(១) **ទម្រង់ហុចកំពូលក្បាល**៖ អ្នកស្ទាបប៉ះបង្ហើយតូច ។

(២) **ទម្រង់បង្ហាញបង្ហើយធំ**៖ អ្នកស្ទាបប៉ះបង្ហើយធំ ។

(៣) **ទម្រង់ហុចថ្ងាស**៖ អ្នកស្ទាបប៉ះបង្ហើយធំនិងថ្ងាសឬច្រមុះ ។

(៤) **ទម្រង់ហុចមុខ**៖ អ្នកស្ទាបប៉ះមុខដូចជាមាត់ ។

**<បង្ហើយតូចនិងធំនៃក្បាលកូន>**

- ថ្នេរក្បាលគឺជាការរួមគ្នាដែលបានបង្កើតឡើងដោយឆ្អឹងពីរជួបគ្នា។ បង្ហើយគឺត្រូវបានបង្កើតឡើងត្រង់កន្លែងដែលមានថ្នេរក្បាលពីរឬច្រើនជួបគ្នា (រូបភាពទី**៤J**) ។

- បង្ហើយតូច (ក្រោយ) គឺស្ថិតនៅផ្នែកខាងក្រោយនៃក្បាលរបស់ទារក (អុកស៊ីពុត) ។
- បង្ហើយធំ (មុខ) គឺស្ថិតនៅខាងមុខនៃក្បាលរបស់ទារក (សាំងស៊ីពុត) ។

- បង្ហើយទាំងនេះគឺជាចំនុចសម្គាល់ដឹងពី**ទម្រង់បង្ហាញ**និង**ការបង្ហាញ**របស់ទារក ។




រូបភាពទី៤J លលាដ៍ក្បាលកូន[៩] (មើលពីខាងលើក្បាល)
ប្រភពរូបភាព: Marshall, J. and Raynor, M. (2014). *Myles Textbook for midwives*. 16th ed. Elsevier.

### ៤-១-១-៥. ផលវិបាកនៃសណ្ឋាន និងទម្រង់បង្ហាញមិនធម្មតា

៤-១-១-៥-១. សណ្ឋាន និងទម្រង់បង្ហាញមិនធម្មតារបស់ទារក

សណ្ឋានទទឹងពោះ ឬ បញ្ឆិតពោះទម្រង់ហុចស្មា ទម្រង់បញ្ច្រាស់ទម្រង់បង្ហាញបង្ហើយធំទម្រង់ហុច ថ្ងាសនិង ទម្រង់ហុចមុខ៖

- សម្រាប់ស្ថានភាពមិនធម្មតានៃសណ្ឋាន និងទម្រង់បង្ហាញរបស់ទារកទាំងនេះ គឺមិនសមស្របជាមួយ នឹងអាងត្រគាករបស់ម្ដាយ ។ ករណីទាំងនោះអាចនាំឱ្យការឈឺពោះសម្រាលដែលមាន ឧបសគ្គ ឬ ឈប់មានការវិវត្តនៃការឈឺពោះសម្រាល ។
- **ការធ្លាក់ទងសុកមកមុន** កើតមានជាញឹកញាប់ចំពោះសណ្ឋានទទឹង ឬបញ្ឆិតពោះ និងទម្រង់ បង្ហាញបញ្ច្រាស់ ឬ ទម្រង់ហុចស្មានៅពេល ដែលស្រោមទឹកភ្លោះបែក ។

៤-១-១-៥-២. ទម្រង់បង្ហាញដៃទូលក្បាល និងកូនធ្លាក់ដៃ

- វាអាចបណ្ដាលឱ្យមានការ**ឈឺពោះសម្រាលដែលមានឧបសគ្គ** ឬក៏**ស្វះសរសៃឈាម (Necrosis) ត្រង់ដៃ** ។

### ៤-១-២. ការបង្ហាញរបស់ទារកក្នុងទម្រង់បង្ហាញកំពូលក្បាល

《**សង្ខេប**》

- ការបង្ហាញរបស់ទារកសំដៅទៅលើទំនាក់ទំនងរវាងគោលសម្គាល់របស់ទារក និងអាងត្រគាករបស់ម្ដាយ (ខាងក្រោយឬខាងមុខ ខាងស្ដាំឬខាងឆ្វេង) ។
- ការបង្ហាញរបស់ទារកប្រែប្រួលនៅពេលដែលទារកបង្វិលចុះ ។
- វាអាចត្រូវបានប៉ាន់ប្រមាណត្រង់កន្លែងដែលយើងប៉ះអុកស៊ីពុតជាមួយនឹងបង្ហើយតូចនៅក្នុងអាងត្រគាកម្ដាយក្នុងកំឡុងពេលលូកពិនិត្យទ្វារមាស ។
- ក្នុងដំណើរការធម្មតានៃការបង្វិលចុះរបស់ទារក ការបង្ហាញរបស់ទារកផ្លាស់ប្ដូរ ពីអុកស៊ីពុតទទឹង ទៅអុកស៊ីពុតមុខ ។
- នៅពេលដែលការបង្ហាញកូនមិនធម្មតា ការឈឺពោះសម្រាលមានឧបសគ្គអាចកើតមានឡើង ។

#### ៤-១-២-១. និយមន័យការបង្ហាញរបស់ទារក

- **ការបង្ហាញរបស់ទារក** គឺជាទំនាក់ទំនងរវាង**គោលសម្គាល់របស់ទារក** និង**អាងត្រគាកម្ដាយ** (**ខាងក្រោយ, ខាងមុខ, ខាងស្ដាំ ឬខាងឆ្វេង**) ។ ខាងក្រោយគឺជាឆ្អឹងខ្នងរបស់ម្ដាយ ហើយខាងមុខគឺជាឆ្អឹងថ្ងាសរបស់ម្ដាយ ។ ការបង្ហាញរបស់ទារកប្រែប្រួលនៅពេលដែលទារកបង្វិលចុះ ។

#### ៤-១-២-២. និយមន័យការបង្វិលរបស់ទារក

- **ការបង្វិលរបស់ទារក** (Fetal rotation) គឺជាចលនាត្រលប់នៃក្បាលទារក ដើម្បីឆ្លងកាត់ផ្លូវសម្រាល ។
- **ចំពោះដំណើរ**ការឈឺពោះសម្រាលធម្មតាក្បាលខាងបង្ហើយតូចរបស់កូនធ្វើចលនាបន្តិចម្ដងៗ ពីផ្នែកខាងស្ដាំ/ឆ្វេងរបស់ម្ដាយទៅឆ្អឹងថ្ងាសរបស់ម្ដាយ ។

#### ៤-១-២-៣. ចំណាត់ថ្នាក់នៃការបង្ហាញកូនក្នុងការបង្ហាញកំពូលក្បាល

៤-១-២-៣-១.អុកស៊ីពុតទទឹង[៦] **(OT)**

- នៅពេលដែលបង្ហើយតូចចង្អុលទៅផ្នែកទទឹងនៃអាងត្រគាករបស់ម្ដាយ នោះគឺ**អុកស៊ីពុតទទឹង (Occiput Transverse ឬ OT)** ។
- ជាទូទៅទារកចូលច្រកលើនៃអាងត្រគាកក្នុងការបង្ហាញ OT ដើម្បីឱ្យសមល្មម ទៅនឹងទ្រង់ទ្រាយច្រកលើនៃអាងត្រគាក ។ វាត្រូវបានគេចាត់ចូលទៅក្នុង អុកស៊ីពុតទទឹងឆ្វេង (LOT) ឬអុកស៊ីពុតទទឹងស្ដាំ (ROT) អាស្រ័យទៅលើផ្នែកដែលអុកស៊ីពុតចង្អុលប្រាប់ ។




**រូបភាពទី១១ អុកស៊ីពុតទទឹងឆ្វេង (LOT) និងអុកស៊ីពុតទទឹងស្តាំ (ROT)**
ប្រភពរូបភាព: *Myles Textbook for midwives.* 16th ed.

៤-១-២-៣-២. អុកស៊ីពុតមុខ (OA)

- ពេលដែលអុកស៊ីពុតស្ថិតនៅចំឆ្អឹងថ្ងាសរបស់ម្តាយ ( ឧទាហរណ៍ នៅពីមុខអាងត្រគាក ម្តាយ ), នោះត្រូវបានគេហៅថា **អុកស៊ីពុតមុខ (Occiput Anterior or OA)** ។
- ដំណើរការវិវត្តការបង្វិលចុះរបស់ទារកធម្មតា អុកស៊ីពុតប្រែប្រួលបន្តិចម្តងៗឆ្ពោះទៅរកឆ្អឹងថ្ងាសពីទីតាំងដើម( ខាងឆ្វេងឬខាងស្តាំអាងត្រគាកនៃឆ្អឹងអាងត្រគាករបស់ម្តាយ ) ។ ក្បាលទារកចុះចូលទៅក្នុងអាងត្រគាកនៅមុំ ៤៥ ដឺក្រេគឺនៅទីតាំងអុកស៊ីពុតឆ្វេង មុខ (LOA) ឬ អុកស៊ីពុតស្តាំមុខ (ROA) ។




**រូបភាពទី១២ អុកស៊ីពុតឆ្វេងមុខ(LOA) និង អុកស៊ីពុតស្តាំមុខ (ROA)**
ប្រភពរូបភាព: *Myles Textbook for midwives. 16th ed.*

៤-១-២-៣-៣. អុកស៊ីពុតក្រោយ (OP)

- ពេលដែលអុកស៊ីពុតមានទីតាំងនៅឆ្អឹងខ្នងម្តាយ ( ឧទាហរណ៍នៅខាងក្រោយអាងត្រគាកម្តាយ ) នោះគេហៅថា**អុកស៊ីពុតក្រោយ (Occiput Posterior or OP)** ។

- ពេលខ្លះអុកស៊ីពុតប្រែប្រួលឆ្ពោះទៅឆ្អឹងខ្នងម្តាយពីទីតាំងដើម (ឆ្វេងឬស្តាំអាងត្រគាក ម្តាយ) ។ ទារករំកិលចុះចូលទៅក្នុងឆ្អឹងអាងត្រគាកនៅក្នុងមុំ៤៥ដឺក្រេ គឺ**នៅទីតាំងអុកស៊ីពុត ក្រោយឆ្វេង (LOP) ឬ អុកស៊ីពុតក្រោយស្តាំ (ROP)** ។




**រូបភាពទី ១៣ អុកស៊ីពុតក្រោយឆ្វេង (LOP) និង អុកស៊ីពុតក្រោយស្តាំ (ROP)**
ប្រភពរូបភាព: *Myles Textbook for midwives. 16th ed.*

**៤-១-២-៤.វិធីដើម្បីសម្គាល់ការបង្ហាញរបស់ទារក**

៤-១-២-៤-១.ការលូកពិនិត្យទ្វារមាស

(១) ស្ទាបប៉ះទិសដៅនៃថ្នេរក្បាលនិងបង្ហើយតូចឬធំរបស់ទារក ។

- ពេលអ្នកប៉ះ**បង្ហើយតូច** អ្នកអាចមានអារម្មណ៍ប៉ះថ្នេរជ្រៅរាងត្រីកោណ ឬ ទ្រង់ទ្រាយដូច **អក្សរ ‘Y’** ។ បញ្ជាក់ថាវាបានបង្កើតឡើងដោយតំណឆ្អឹង៣ភ្ជាប់គ្នា ។
- ដោយឡែកពេលដែលអ្នកប៉ះ**បង្ហើយធំ** អ្នកអាចមានអារម្មណ៍ថាប៉ះថ្នេរធំជាង **ជ្រៅរាងដូចគ្រាប់ពេជ្រ (Rhomboid) ។** បញ្ជាក់ថាវាបានបង្កើតឡើងដោយតំណឆ្អឹង ៤ ភ្ជាប់គ្នា ។

(២) រកទីតាំងបង្ហើយតូច

- ប្រសិនបើអ្នកប៉ះបង្ហើយធំ នោះបង្ហើយតូចស្ថិតនៅទិសដៅម្ខាងទៀត(តារាង ៤N) ។

**តារាង ៤N ទីតាំងបង្អើយតូចនិងការបង្ហាញរបស់ទារក**

| ទីតាំងបង្អើយតូច | | ការបង្ហាញរបស់ទារក |
|---|---|---|
| ខាងឆ្វេងម្តាយ |  Left occiput transverse | LOT<br>អុកស៊ីពុតឆ្វេងទទឹង |
| ខាងស្តាំម្តាយ |  Right occiput transverse | ROT<br>អុកស៊ីពុតស្តាំទទឹង |
| ចន្លោះខាងឆ្វេងនិងឆ្អឹងថ្ងាសម្តាយ |  Left occiput anterior | LOA<br>អុកស៊ីពុតមុខឆ្វេង |
| ចន្លោះខាងស្តាំនិងឆ្អឹងថ្ងាសម្តាយ |  Right occiput anterior | ROA<br>អុកស៊ីពុតមុខស្តាំ |
| ខាងឆ្អឹងថ្ងាសម្តាយ |  Occiput anterior | OA<br>អុកស៊ីពុតមុខ |
| ចន្លោះខាងឆ្វេងនិងឆ្អឹងកងខ្នងម្តាយ |  Left occiput posterior | LOP<br>អុកស៊ីពុតក្រោយឆ្វេង |
| ចន្លោះខាងស្តាំនិងឆ្អឹងកងខ្នងម្តាយ |  Right occiput poterior | ROP<br>អុកស៊ីពុតក្រោយស្តាំ |
| ខាងឆ្អឹងខ្នងម្តាយ |  Occiput posterior | OP<br>អុកស៊ីពុតក្រោយ |

ប្រភព: *Integrated Management of Pregnancy and Childbirth, Pregnancy, Managing Complications in Pregnancy and Childbirth: A guide for midwives and doctors (2017)* WHO, S-91




**តារាង៤០. ទីតាំងបង្ហើយតូចនិងការបង្ហាញរបស់ទារក**

ប្រភពរូបភាព៖

http://intranet.tdmu.edu.ua/data/kafedra/internal/ginecology2/classes_stud/en/nurse/adn/ptn/2/Nursing%20Care%20of%20Childbearing%20Family/02.%20Unit%20test%20II.htm

**<ចំណុចដែលត្រូវពិនិត្យតាមរយៈការលូកពិនិត្យទ្វារមាស>**

- កំណត់ទិសដៅនៃថ្នេរក្បាល (Sagittal suture)៖ បង្ហើយតូច (ក្រោយ) ឬ បង្ហើយធំ (មុខ) ។
- ក្នុងការវិវត្តការបង្វិលរបស់ទារកធម្មតា ការបង្ហាញរបស់ទារកផ្លាស់ប្តូរពីអុកស៊ីពុតទទឹង (OT) ទៅអុកស៊ីពីតមុខ (OA) ។
- នៅពេលការបង្ហាញទារក**មិនធម្មតា** នោះអាចនឹងមានការឈឺពោះសម្រាលដែលមានឧបសគ្គ (ការឈឺពោះសម្រាលអូសបន្លាយ ឬឈប់ឈឺពោះសម្រាល) ។
- ប៉ុន្តែយើងមិនអាចវាយតម្លៃការវិវត្តការឈឺពោះសម្រាលត្រឹមតែមួយចំនុចនៃការប៉ាន់ប្រមាណនោះទេ ។ **ការតាមដានបន្តមានសារៈសំខាន់ណាស់ ។**

**៤-១-២-៥.ផលវិបាកការបង្ហាញអុកស៊ីពុតនៅខាងក្រោយ ឬ អុកស៊ីពុតទទឹង**

៤-១-២-៥-១. អុកស៊ីពុតក្រោយ (OP)

- OP គឺការបរាជ័យក្នុងការវិលរបស់កូន៩ ។ វាអាចរំខានដល់ការចុះនៃក្បាលកូនតាមអាងត្រគាក និងបណ្តាលឱ្យមាន**ការឈឺពោះសម្រាលអូសបន្លាយ ឬឈប់ឈឺពោះសម្រាល** ។

- ក្នុងការបង្ហាញ OP អុកស៊ីពុតធ្វើឱ្យមានសម្ពាធខ្លាំងលើឆ្អឹងកងខ្នងស្ត្រី ។ ស្ត្រីអាចត្អូញពីការឈឺចាប់ខ្លាំង**ត្រង់ខ្នង** និងឈឺជាបន្តបន្ទាប់ដោយសាស្បូនកន្ត្រាក់[៩] ។ វាអាចធ្វើឱ្យម្ដាយអស់កម្លាំងហើយអាចធ្វើឱ្យមានការសម្រាលអូសបន្លាយ ។
- ពន្យល់ស្ត្រីឱ្យដើរជុំវិញឬ**ផ្លាស់ប្តូរស្ថានភាព** ( ដូចជា **លុតជង្គង់ អង្គុយចោងហោង** ) ដើម្បីកាត់បន្ថយការឈឺចាប់ខ្នង និងជំរុញឱ្យមានការបង្វិលដោយឯកឯង[៥(៨-៩១),៩] ។ សង្កេតមើលដំណើរការវិវត្ត នៃការឈឺពោះសម្រាលជាប្រចាំ ពិសេសតាមដានការកន្ត្រាក់ស្បូន និងការចុះ នៃក្បាលទារកនិងទីតាំងបង្វើយតូច ។

**៤-១-២-៥-២. អុកស៊ីពុតទទឹង (OT)**

- OT គឺជាការបង្ហាញនៅពេលដែលទារកក្នុងផ្ទៃចុះចូលអាងត្រគាក រួចអាចក្លាយទៅជា OA នៅ ពេលដែលក្បាលទារកវិលជាធម្មតា ។
- ប្រសិនបើ OT នៅតែបន្តមាន ទោះបីជាមានការកន្ត្រាក់ស្បូនដែលមានប្រសិទ្ធភាពក៏ ដោយ នោះ អាចនឹងបណ្តាលមកពី**អុកស៊ីពុតទទឹងគាំងជាប់ (Transverse arrest)** ដែលធ្វើឱ្យក្បាលកូន មិនអាចឆ្លងកាត់តាមអាងត្រគាកបាន ។
- **សង្កេតមើលការកន្ត្រាក់ស្បូន និងការចុះនៃក្បាលទារក** និងទីតាំងបង្វើយតូចជាប្រចាំដើម្បី បញ្ជាក់ថាទារកមានការបង្វិលជាធម្មតាឬទេ ។

## ៤-២. ស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃ:

### ៤-២-១. ចង្វាក់បេះដូងទារក (FHR)/BCF

《**សង្ខេប**》

- ចង្វាក់បេះដូងទារកគឺជាសូចនាករដ៏ជាក់លាក់ដើម្បីដឹងពីសុខភាពទារកក្នុងផ្ទៃអំឡុងពេលសម្រាល ។
- ស្វែងរកទីតាំងស្តាប់ចង្វាក់បេះដូងដោយស្ទាប និងស្តាប់ក្នុងរយៈពេលពេញមួយនាទី ដើម្បីបញ្ជាក់ថាចង្វាក់បេះដូងទារកនៅក្នុងកម្រិតធម្មតាឬទេ ។
- ប្រសិនបើចង្វាក់បេះដូងទារកយឺតជាងកម្រិតធម្មតា វាអាចជាមូលហេតុបណ្តាលមកពីកង្វះអុកស៊ីសែនទៅផ្តល់ឱ្យទារក ឬ/និងមានការគៀបទងសុក។ ផ្លាស់ប្តូរឥរិយាបថរបស់ម្តាយភ្លាមនិងបន្តស្តាប់ចង្វាក់បេះដូងទារក ។
- ប្រសិនបើចង្វាក់បេះដូងទារក ញាប់ជាងកម្រិតធម្មតា វាជាអាចបណ្តាលមកពីការបង្ករោគ ឬ ក៏ ដោយសារមូលហេតុផ្សេងទៀត។សូមបន្តស្តាប់ចង្វាក់បេះដូងទារក ។
- ក្នុងករណីចង្វាក់បេះដូងទារកនៅបន្តមិនធម្មតា វានឹងធ្វើឱ្យទារកស្លាប់ឬបញ្ហាថប់ដង្ហើម ។
- សម្រាប់ចង្វាក់បេះដូងទារកធម្មតា ការតាមដានជាប្រចាំតាមចន្លោះពេលក្នុងដំណាក់កាលនីមួយៗនៃការឈឺសម្រាលជាការចាំបាច់ដែលត្រូវអនុវត្ត ។

#### ៤-២-១-១. និយមន័យនៃចង្វាក់បេះដូងទារក

- ចង្វាក់បេះដូងទារក (FHR) គឺជា**ល្បឿនបេះដូងលោតរបស់ទារក**ដែលត្រូវបានគេរាប់ចំនួននៃការលោតក្នុងពេលវេលាមួយដែលជាធម្មតាគេរាប់ក្នុងមួយនាទី ។

#### ៤-២-១-២. របៀបស្តាប់ចង្វាក់បេះដូងកូន

(១) រក**ការបង្ហាញនិងទម្រង់បង្ហាញ**របស់ទារកដោយការស្ទាបពោះ (មើល *៤-១. សណ្ឋានទម្រង់បង្ហាញ ការបង្ហាញរបស់ទារក* ទំព័រ៥៧) ។

(២) រក**ចំណុចដែលត្រូវស្តាប់ចង្វាក់បេះដូងទារក ។** ខាងលើទ្រូង ឬ ខាងលើផ្នែកខាងខ្នងនៃទារក គឺ ជាកន្លែងដែលបេះដូងទារកលោតឮបំផុត (រូបភាពទី៤P) ។ ដូច្នេះនៅពេលដែលទារក ក្នុងផ្ទៃបែរមុខទៅខាងឆ្វេងម្តាយចំណុចត្រង់កន្លែងស្តាប់បេះដូងកូនគឺនៅខាងស្តាំផ្នែកខាងក្រោម (រូបភាពទី ៤Q)។




**រូបភាពទី៤P.**
**ចំនុចត្រង់កន្លែងបេះដូងកូនលោតលឺជាងគេរូបភាពទី**




**រូបភាពទី៤Q.**
**ទារកបែរមុខទៅរកផ្នែកខាងឆ្វេងរបស់ម្តាយ**

Source: http://www.open.edu/openlearncreate/mod/oucontent/view.php?id=41&printable=1

- កន្លែងស្តាប់ចង្វាក់បេះដូងទារកគឺរំកិលចុះមកក្រោមតាមការចុះរបស់កូន។ កន្លែងស្នូរបេះដូង របស់កូនចុះជាមួយនឹងការចុះរបស់កូន ហើយស្ថិតនៅចំកណ្តាលនៅពេលដែលកូនបង្វិល (រូបភាពទី ៤R) ។



**រូបភាពទី៤R. ការផ្លាស់ប្តូរកន្លែងស្តាប់ចង្វាក់បេះដូងទារកនៅដំណាក់កាលទី ២ នៃការឈឺពោះសម្រាលកូន**
ប្រភពរូបភាព: http://www.open.edu/openlearncreate/mod/oucontent/view.php?id=41&printable=1

## <សំលេងមិនមែនសំលេងបេះដូងកូនពិតប្រាកដ>

- ប្រសិនបើអ្នកឮសំលេង shee-oo, shee-oo, shee-oo អ្នកអាចនឹងឮសំលេង**ជីពចររបស់ទងសុក** ។ សំលេងទងសុកមិនអាចប្រាប់ពីចង្វាក់បេះដូង ទារកបានជាក់លាក់ទេ ។
- អ្នកក៏ប្រហែលជាឮ**សំលេងចង្វាក់បេះដូងរបស់ម្តាយ ។** ស្ទាបជីពចរវ៉ាដ្យាល់របស់ម្តាយជាមួយ នឹងការស្តាប់ចង្វាក់បេះដូងរបស់កូន ដើម្បីឱ្យប្រាកដថាអ្វីដែលឮគឺជាចង្វាក់បេះដូងកូនមិនមែន ចង្វាក់បេះដូងម្តាយ ទេ[១០] ។

(៣) ស្តាប់ចង្វាក់បេះដូងទារក:

**រយៈពេល: ១ នាទីពេញ**
**ពេលរាប់: ភ្លាមៗបន្ទាប់ពីស្បូនកន្ត្រាក់[១]**
**ភាពញឹកញាប់: [ដំណាក់កាលទី១] រៀងរាល់ ៣០ នាទីម្តង, [ដំណាក់កាល ទី២] រៀងរាល់ ៥ នាទីម្តង។**

(៤) កត់ត្រាចង្វាក់បេះដូងទារកនៅក្នុងតារាងវាយតម្លៃដំបូង ប៉ាតូក្រាហ្វ និងកំណត់ត្រានៃការសម្រាលកូន[១] ។

**៤-២-១-៣. ចំណាត់ថ្នាក់ចង្វាក់បេះដូងកូនធម្មតានិងមិនធម្មតា**

- ចង្វាក់បេះដូងកូនធម្មតាសម្រាប់ស្ត្រីមានផ្ទៃពោះគ្រប់ខែគឺ **១១០ ទៅ ១៦០ ក្នុងមួយនាទី[១] ។**
- ចង្វាក់បេះដូងទារកអាចនឹងមិនធម្មតានៅពេលដែលវាខុសពីចន្លោះនេះ មិនថាចុះ ឬកើនឡើង ។

**៤-២-១-៤. ផលវិបាកនៃចង្វាក់បេះដូងកូនខុសពីចន្លោះធម្មតា**

៤-២-១-៤-១. ចង្វាក់បេះដូងកូនតិចជាង ១១០

ទារកក្នុងផ្ទៃទទួលអុកស៊ីសែនពីម្តាយតាមរយៈសុកនិងទងសុក ។ នៅពេលដែលចង្វាក់បេះដូងកូនចុះក្នុងកំឡុងពេលឈឺពោះសម្រាល ការកន្ត្រាក់ស្បូនអាចធ្វើឱ្យ (១) **មានការថយចុះលំហូរឈាមរបស់ សុក ឬ** (**២**) **មានការសង្កត់ទងសុក ។**

(១) **ការថយចុះលំហូរឈាមរបស់សុក**

- ក្នុងកំឡុងពេលកន្ត្រាក់ សរសៃឈាមនៅក្នុងស្បូនត្រូវបានសង្កត់ដោយសាច់ដុំស្បូន។ បន្ទាប់មកលំហូរឈាមរបស់សុកមានការថយចុះ ហើយការផ្តល់**អុកស៊ីសែនពីម្តាយទៅកូនមានការថយចុះ ។**
- ជាលទ្ធផលកូនទទួលអុកស៊ីសែនមិនបានគ្រប់គ្រាន់ ហើយចង្វាក់បេះដូងកូនមានការថយចុះដោយសារ**ការខ្វះអុកស៊ីសែន** ។
- នៅពេលដែលទារកមានកម្លាំងខ្លាំងគ្រប់គ្រាន់ក្នុងការទប់ទល់នឹងការផ្តល់អុកស៊ីសែនដែល មិនគ្រប់គ្រាន់ ចង្វាក់បេះដូងទារកមិនផ្លាស់ប្តូរ ឬ ចុះខ្លាំងទេ ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើ ទារកក្នុងផ្ទៃខ្សោយ ឬ មុខងារសុកធ្វើការមិនបានល្អចង្វាក់បេះដូងទារកក្លាយជាយឺតទាំង ស្រុង ឬ យឺតខ្លាំងទោះបីជាមានការកន្ត្រាក់ ស្បូនស្រាលក៏ដោយ[៦] ហើយវាអាចនាំឱ្យ**ទារក ក្នុងផ្ទៃស្លាប់ ឬ ថប់ដង្ហើម ។**

(២) **ការសង្កត់ទៅលើទងសុក**

- ក្នុងកំឡុងពេលស្បូនកន្ត្រាក់ ទងសុកគឺសង្កត់ដោយសម្ពាធរវាងទារក និង ស្បូន ។ បន្ទាប់មកលំហូរឈាមថយចុះ ដែលធ្វើឱ្យចង្វាក់បេះដូងកូនចុះថយដែរ ។
- ការសង្កត់ទៅលើទងសុកប្រហែលមកពីទងសុករុំខ្លួនឬកទារក ទងសុកចងគួចចូលគ្នា ឬ ទឹកភ្លោះតិច ។
- ប្រសិនបើវាកើតឡើងដដែលៗឬជាបន្តបន្ទាប់ ទារកក្នុងផ្ទៃអាចនឹង**ខ្វះអុកស៊ីសែន** ដែលត្រូវធ្វើការបញ្ជូន ។
- អន្តរាគមន៍ដែលអាចទៅរួចសំរាប់ចង្វាក់បេះដូងទារកដែលតិចជាង ១១០ **គឺការផ្លាស់ប្តូរស្ថានភាពម្តាយដើម្បីបន្ថយសម្ពាធទៅលើទងសុក ។**
- នៅពេលដែលស្រោមទឹកភ្លោះបែក ពិនិត្យថាតើមានទងសុកធ្លាក់មុនទារកចេញ និង ទឹកភ្លោះមានលាយលាមកន៍ព្រៃខាប់ឬទេ ។

៤-២-១-៤-២. ចង្វាក់បេះដូងទារកច្រើនជាង ១៦០

ចង្វាក់បេះដូងទារកដែលលោតញាប់ អាចបណ្តាលមកពីម្តាយមាន**គ្រុនក្តៅ** មាន**ការបង្ករោគប្រើថ្នាំ** ដែលបណ្តាល**ឱ្យ**ចង្វាក់បេះដូងម្តាយញាប់ (ឧ. ថ្នាំតូកូលីទិច) ឬ **លើសសម្ពាធឈាម** ។ ប្រសិនបើម្តាយមិនមានចង្វាក់បេះដូងញាប់ទេ ភាពញាប់នៃចង្វាក់បេះដូងទារកអាចជាសញ្ញា **ទារកខ្សោយ**[៦, ១ (p៨៧),៥(S១០៩)] ។

**សម្គាល់៖** ប្រសិនបើចង្វាក់បេះដូងកូនមិនធម្មតា (តិចជាង ១១០ ដង/ ១ នាទី ឬច្រើនជាង ១៦០ដង/ ១ នាទី) ត្រូវដាក់ស្ត្រីក្នុងស្ថានភាពគេងផ្អៀងឆ្វេង និងចង្វាក់បេះដូងម្តងទៀត ។)

## ៤-២-២. ទឹកភ្លោះ

《**សង្ខេប**》
- ពណ៌ទឹកភ្លោះគឺជា សូចនាករមួយទៀតដែលបញ្ជាក់ពីស្ថានភាពទារក ក្នុងអំឡុងពេលឈឺពោះ សម្រាល ឬ ការហូរឈាម នៅខាងក្នុងដែលចេញពីសុក ។
- ប្រសិនបើស្រោមទឹកភ្លោះបែក ពិនិត្យមើលពណ៌ទឹកភ្លោះ ដោយការលូកពិនិត្យទ្វារមាស ។
- ប្រសិនបើទឹកភ្លោះមានលាយលាមក៏ព្រៃខាប់ ពិនិត្យចង្វាក់បេះដូងទារក ។ ប្រសិនបើចង្វាក់បេះដូងទារកមិនធម្មតា វាបញ្ជាក់ថាទារកខ្សោយ ។

**៤-២-២-១. លក្ខណៈធម្មតានៃទឹកភ្លោះ**

ទឹកភ្លោះ គឺជាសារធាតុរាវថ្លានៅព័ទ្ធជុំវិញទារក ។

**៤-២-២-២. មធ្យោបាយក្នុងការពិនិត្យទឹកភ្លោះ**

នៅពេលដែលស្រោមទឹកភ្លោះបែក ឆ្មបគួរតែពិនិត្យលក្ខណៈដូចខាងក្រោម៖
- កំហាប់ (ស្អិត ឬ រាវ)
- ពណ៌ (លឿង បៃតងខ្ចី បៃតងចាស់ ឬ បៃតងក្រម៉ៅ)
- ក្លិន (អត់ក្លិន ឬ មានក្លិនស្អុយ)
- បរិមាណ៖ (ពិនិត្យថាតើមានការហូរទឹកភ្លោះឬអត់)

**៤-២-២-៣. ផលវិបាកដោយសារទឹកភ្លោះមានលក្ខណៈមិនធម្មតា**

៤-២-២-៣-១. ទឹកភ្លោះមានលាយឈាម (មើល *៦. សង្កេតមើលស្ថានភាពម្ដាយ ៦-៦-៣. ផលវិបាកដោយសារការធ្លាក់ឈាមមិនធម្មតា* ទំព័រ១០៨)

៤-២-២-៣-២. ទឹកភ្លោះដែលមានលាមក៏ព្រៃខាប់
- **លាមក៏ព្រៃគឺជាលាមក៏របស់ទារក ។**
- ពេលទារកមាន**អុកស៊ីសែនតិច** ពេលខ្លះទារកជុះលាមក៏ព្រៃចូលទៅក្នុងទឹកភ្លោះក្នុងកំឡុង ពេលឈឺពោះសម្រាល ។
- ទឹកភ្លោះដែលមានលាមក៏ព្រៃត្រូវបានគេឃើញជាញឹកញាប់ចំពោះទារកដែល**គ្រប់ខែ ។** ដូច្នេះទឹកភ្លោះដែលមានលាមក៏ព្រៃតិចតួចមិនមែនជាសូចនាករដែលបញ្ជាក់ថាទារកក្នុងផ្ទៃខ្សោយនោះទេ[៥,៦] ។

- ទោះបីជាយ៉ាងណាក៏ដោយ **ទឹកភ្លោះដែលមានលាមក៏ព្រៃខាប់**គឺជាសញ្ញាមួយដែលបញ្ជាក់ ថា**ទារកខ្សោយ**ជាពិសេសប្រសិនបើមានវត្តមានចង្វាក់បេះដូងកូនមិនធម្មតា[១] ។
- អាចនឹងមាន **Meconium Aspiration Syndrome (MAS)** ដែលជាបញ្ហាផ្លូវដង្ហើមពេលទារកដកដង្ហើមស្រូបចូលលាមក៏ព្រៃ ។

៤-២-២-៣-៣. ទឹកភ្លោះដែលមានក្លិនស្អុយ

វាបញ្ជាក់ពី**ការបង្ករោគ**នៅក្នុងទឹកភ្លោះ ហើយត្រូវការការព្យាបាលនិង បញ្ជូន ។

៤-២-២-៣-៤. អវត្តមានទឹកភ្លោះពេលបែកស្រោមទឹកភ្លោះ

- អវត្តមានទឹកភ្លោះដែលហូរចេញមកបន្ទាប់ពីបែកស្រោមទឹកភ្លោះ គឺបញ្ជាក់ថាមានការថយចុះបរិមាណទឹកភ្លោះ[៥] ។
- វាបញ្ជាក់ថាការ**សង្កត់ទៅលើទងសុក**អាចនឹងកើតមាន ។ ស្តាប់ចង្វាក់បេះដូងទារកឱ្យបាន សមស្រប និងសង្កេតឱ្យបានជិតដល់នៅពេលដែលឮចង្វាក់បេះដូងកូនមិនធម្មតា ។

# ជំពូកទី ៥ ការប៉ាន់ប្រមាណការវិវត្ត ការឈឺពោះសម្រាល

**សង្ខេប**

- វត្ថុបំណងនៅក្នុងជំពូកនេះគឺ (១) ប៉ាន់ប្រមាណការវិវត្តការសម្រាលតាមរយៈ**៤Ps** (**កម្លាំង (Power) ផ្លូវឆ្លងកាត់ (Passage) អ្នកធ្វើដំណើរ (Passenger) និង ផ្លូវចិត្ត (Psychology)**) និង (២) កំណត់ដំណាក់កាលការឈឺពោះសម្រាល ។
- ត្រូវយល់ពី**៤Ps** សម្រាប់ការប៉ាន់ប្រមាណការវិវត្ត ការឈឺពោះសម្រាលដែលមាន **កម្លាំង (Power) ផ្លូវឆ្លងកាត់ (Passage) អ្នកធ្វើដំណើរ (Passenger) និង ផ្លូវចិត្ត (Psychology) ។**
- ការឈឺពោះសម្រាលចែកចេញជា**បួនដំណាក់កាល ។** ដំណាក់កាលទី ១ និងទី ២ ផ្តោតនៅក្នុងជំពូកនេះ ។ លក្ខណៈវិនិច្ឆ័យក្នុងការបែងចែកដំណាក់កាលនិមួយៗគឺ ‘**ការបើកមាត់ស្បូន**’ ។
- ៤Ps - កម្លាំង (Power) ផ្លូវឆ្លងកាត់ (Passage) អ្នកធ្វើដំណើរ (Passenger) និង ផ្លូវចិត្ត (Psychology) គួរត្រូវបានគេប៉ាន់ប្រមាណគ្រប់ដំណាក់កាល (និងរយៈ) នៃការឈឺពោះសម្រាល ។

## ៥-១. ៤Ps - **កម្លាំង ផ្លូវឆ្លងកាត់ អ្នកធ្វើដំណើរនិង ផ្លូវចិត្ត**

《**សង្ខេប**》

- ការវិវត្ត ការសម្រាលល្អអាស្រ័យលើសមាសភាគ៤ ដែលគេហៅថា ៤Ps ( ១ ) **កម្លាំង (Power)** ( **២** ) **ផ្លូវឆ្លងកាត់ (Passage)** ( **៣** ) **អ្នកធ្វើដំណើរ (Passenger) និង** ( **៤** ) **ផ្លូវចិត្ត (Psychology) ។**
- ( ១ ) **កម្លាំង** គឺជាអ្នកជម្រុញការសម្រាលទារក ។ ដូច្នេះវាគឺជា '**ការកន្ត្រាក់ស្បូន**' ឬ '**ការឈឺពោះពេលសម្រាល**' ។
- ( ២ ) **ផ្លូវឆ្លងកាត់** ជាមធ្យោបាយដែលឆ្លងពីស្បូនមកក្រៅរាងកាយម្តាយ ។ វាមាន**មាត់ស្បូន អាងត្រគាក ( ឆ្អឹង ) ទ្វារមាស និង ប៉េរីណេ ។**
- ( ៣ ) **អ្នកធ្វើដំណើរ** គឺជាទារក ( ទម្រង់និងទំហំ ) ។
- ( ៤ ) **ផ្លូវចិត្ត**របស់ម្តាយជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការវិវត្ត នៃការឈឺពោះទាំងមូលពិសេសការកន្ត្រាក់ស្បូន ។

### ៥-១-១. កម្លាំង

- **កម្លាំង**: ជាអ្នករុញច្រានទារកឱ្យចេញពីក្នុងស្បូនមកក្រៅដើម្បីឃើញពិភពលោកយើងនេះ ។ វាគឺជា**ការកន្ត្រាក់ស្បូន ឬការឈឺពោះសម្រាល ។**
- ការកន្ត្រាក់ស្បូនមានបីចំណុចដែលមាន '**រយៈពេល**' នៃការកន្ត្រាក់ស្បូនម្តងៗ '**ភាពញឹកញាប់**' ( ជាធម្មតារាប់ចំនួនដងក្នុង ១០ នាទី ) និង**កម្លាំង** (ទោះបីជាញឹកញាប់វាជាសូចនាករដែលពិបាកវាស់ស្ទង់ )។ ចំនុចទាំងបីនេះ គឺត្រូវប៉ាន់ប្រមាណដាច់ ដោយឡែកពីគ្នា ។
- ការកន្ត្រាក់ស្បូនត្រូវខ្លាំងគ្រប់គ្រាន់ បើមិនដូច្នោះទេការសម្រាលនឹងគ្មានការវិវត្តឡើយ ។ ទោះជាយ៉ាងនេះក្តី ត្រូវសម្គាល់ថាការកន្ត្រាក់ស្បូនខ្លាំងត្រូវសមស្របទៅនឹងទារកក្នុងស្បូនពីព្រោះការកន្ត្រាក់ស្បូនខ្លាំងធ្វើអោយមានការថយចុះលំហូរឈាម នៅក្នុងស្បូនដែលជាលទ្ធផលនៃការថយចុះ អុកស៊ីសែនដែលផ្គត់ផ្គង់ដល់កូន ។
- ដូច្នេះការតាមដានដោយប្រុងប្រយ័ត្ននូវការកន្ត្រាក់ស្បូន និងស្ថានភាពកូនមានសារៈសំខាន់ណាស់ក្នុងការថែទាំការសម្រាល ។

### ៥-១-២. ផ្លូវឆ្លងកាត់

- **ផ្លូវឆ្លងកាត់**: គឺជាផ្លូវដែលឆ្លងពីស្បូនមកក្រៅរាងកាយម្តាយ ។ វារួមមាន **អាងត្រគាក** (**ឆ្អឹង**) **មាត់ស្បូន ទ្វារមាសនិងប៉េរីណេ ។**
- មាត់ស្បូនទន់ ហើយបើកអស់ ឆ្អឹងអាងត្រគាកមានទម្រង់និងទំហំគ្រប់គ្រាន់ ទ្វារមាស និងប៉េរីណេទន់ ជាតម្រូវការសម្រាប់ការសម្រាលប្រព្រឹត្តទៅស្រួល ។
- **ការបើកមាត់ស្បូន** មានការផ្លាស់ប្តូរជាបន្តបន្ទាប់ ដូច្នេះចាំបាច់ត្រូវធ្វើការតាមដាន ឱ្យបានទៀងទាត់ ។
- **ឆ្អឹងអាងត្រគាក** មិនផ្លាស់ប្តូរ ប៉ុន្តែអ្វីដែលសំខាន់នោះគឺសមាមាត្ររវាង ទំហំឆ្អឹងនិង ទារក (អ្នកធ្វើដំណើរ) ។ ទោះបីជាទំហំនៃឆ្អឹងអាងត្រគាកធំគ្រប់គ្រាន់តែទារកធំខ្លាំង នោះផ្លូវឆ្លងកាត់ (ឆ្អឹងអាងត្រគាក) នឹងរារាំងទារកមិនឱ្យចេញរួច ។ ដោយឡែកទារកដែលតូចអាចឆ្លងកាត់អាងត្រគាកតូចបាន ។
- ដូច្នេះ ជានិច្ចកាលយើងត្រូវពិនិត្យ **សមាមាត្ររវាងផ្លូវឆ្លងកាត់និងអ្នកធ្វើដំណើរ ។**

### ៥-១-៣. អ្នកធ្វើដំណើរ

- **អ្នកធ្វើដំណើរ** គឺ**ទារក** (**ទម្រង់និងទំហំ**) **។ ផ្នែកដែលធំបំផុតរបស់ទារកគឺក្បាល ។ ដូច្នេះរបៀបដែលក្បាលទារកចូលក្នុងអាងត្រគាក**មានសារៈសំខាន់ណាស់សម្រាប់ការសម្រាលធម្មតា ។ (មើល *៤. សង្កេតស្ថានភាពទារក ៤-១. សណ្ឋាន ទម្រង់បង្ហាញ និងការបង្ហាញរបស់ទារក* ទំព័រ៥៧)
- ដូចដែលបានរៀបរាប់ពីខាងលើ **សមាមាត្ររវាងផ្លូវឆ្លងកាត់និងអ្នកធ្វើដំណើរ** មានសារៈសំខាន់ ។
- សម្រាប់ការសម្រាលធម្មតា នោះគឺចាំបាច់ណាស់ក្នុងការប៉ាន់ប្រមាណ**'ការចុះនៃក្បាលកូន' ។** វាត្រូវបានវាស់វែងទៅជា**កម្រិតចុះចូលនៃក្បាលកូនទៅក្នុងអាងត្រគាក ។**

### ៥-១-៤. ផ្លូវចិត្ត

- **ផ្លូវចិត្ត** (ស្ថានភាពផ្លូវចិត្ត) របស់ម្តាយជាកត្តាសំខាន់ក្នុងការវិវត្តការឈឺពោះសម្រាល ។ ប្រសិនបើម្តាយខ្លាចឬមានការថប់បារម្ភ នោះប្រាកដជាមានការថយចុះអរម៉ូននៅខាងក្នុង (ឧទាហរណ៍ **អុកស៊ីតូ-ស៊ីន** អង់ដូហ្វីន) ដែលជួយសម្រួលដល់ការឈឺពោះសម្រាល (មើល *៦. សង្កេតមើលស្ថានភាពម្តាយ ៦-៧. ស្ថានភាពផ្លូវចិត្ត* ទំព័រ១១០) ។

## ៥-២. កំណត់ពីដំណាក់កាលនៃការឈឺពោះសម្រាល

《**សង្ខេប**》
- ដំណាក់កាលនៃការឈឺពោះសម្រាលមាន៤៖ ទី១ ទី២ ទី៣ និងទី៤ ។
- ដំណាក់កាលទី ១ នៃការឈឺពោះសម្រាលចែកជា២រយៈ៖ រយៈ**យឺត** និងរយៈ**សកម្ម** ។
- ការបើកមាត់ស្បូន (គិតជាសង់ទីម៉ែត្រ) គឺជាសូចនាករក្នុងការកំណត់ដំណាក់កាល និងរយៈ ។ ទោះជាយ៉ាងនេះក្តី ការកន្ត្រាក់ស្បូនទៀងទាត់ (ការឈឺពោះសម្រាល) គួរមានជាមួយការបើកមាត់ស្បូន ។
- ការបើកមាត់ស្បូនតែឯងមិនបញ្ជាក់ពីការចាប់ផ្តើមឈឺពោះសម្រាលនោះទេ ។

### ៥-២-១. និយមន័យដំណាក់កាលការឈឺពោះសម្រាល

- ការសម្រាលកូនចែកជា**បួនដំណាក់កាល** ។ មានតែ**ដំណាក់កាលទី១**នៃការឈឺពោះសម្រាលតែប៉ុណ្ណោះដែលចែកចេញជា**រយៈយឺត និងរយៈសកម្ម** (មើលតារាង៥A) ។

(១) នៅប្រទេសកម្ពុជារយៈយឺតនៃដំណាក់កាលទី១ ត្រូវបានគេឱ្យនិយមន័យថាស្បូន បើកបាន ‘៣ សង់ទីម៉ែត្រ ឬ តិចជាងនេះ ។

(២) រយៈសកម្មនៃដំណាក់កាលទី១ ជាការបើកមាត់ស្បូនច្រើនជាង៣សង់ទីម៉ែត្រ (ឧទាហរណ៍ ៤សង់ទីម៉ែត្រ) រហូតដល់មាត់ស្បូនបើកអស់ ។

- ដំណាក់កាលទី ២ នៃការឈឺពោះសម្រាលគឺចាប់ពីមាត់ស្បូនបើកអស់ដល់ទារក សម្រាលរួច ។

**តារាង៥A៖ និយមន័យដំណាក់កាលនិងរយៈនៃការឈឺពោះសម្រាល**

| ដំណាក់កាល | រយៈ | និយមន័យ |
|---|---|---|
| ទី១ | យឺត | ពីពេលចាប់ផ្តើមឈឺពោះសម្រាលរហូតដល់មាត់ស្បូនបើកបាន ៣ស.ម ។ |
| | សកម្ម | ពីពេលមាត់ស្បូនបើកបានច្រើនជាង ៣ស.ម រហូតដល់មាត់ស្បូនបើកអស់ ។ |
| ទី២ | | ពីពេលមាត់ស្បូនបើកអស់ដល់ទារកសម្រាល (ការរុញច្រានទារកចេញ) |
| ទី៣ | | ពីពេលទារកសម្រាលដល់សុកចេញផុត ។ |
| ទី៤ | | ពីសុកចេញផុតដល់តាមដាន២ម៉ោងក្រោយសម្រាល ។ |

**សំគាល់៖ និយមន័យខុសពីគ្នានៃរយៈយឺត និងសកម្មក្នុងដំណាក់កាលទី១ នៃការឈឺពោះ សម្រាល**

- អង្គការសុខភាពពិភពលោក (WHO) បានធ្វើបច្ចុប្បន្នភាពនិយមន័យរយៈសកម្មក្នុងឆ្នាំ ២០១៨ ។ និយមន័យថ្មីនៃរយៈសកម្មគឺមាត់ស្បូនបើកបាន៥ស.ម រហូតដល់មាត់ស្បូនបើកអស់[១៣] ។
- ពីព្រោះភស្តុតាងវិទ្យាសាស្ត្រជាច្រើនបង្ហាញថា ការវិវត្តលឿននៃការសម្រាល (មាត់ស្បូនបើក និងរលប់)គឺចាប់ពីពេលមាត់ស្បូនបើកបាន ៥ ស.ម ។ ភស្តុតាងក៏បង្ហាញថារយៈពេលនៃរយៈយឺតខុសគ្នាពីស្ត្រីម្នាក់ទៅស្ត្រីម្នាក់ទៀត ។ ដូច្នេះវា មិនចាំបាច់ក្នុងការបន្ថយរយៈយឺតមកត្រឹម៨ម៉ោងនោះទេ ។
- ការធ្វើបែបនេះគឺដើម្បីបន្ថយការប្រញាប់បញ្ជូនពេកនិងការអន្តរាគមន៍ផ្នែកសម្ភព មិនចាំបាច់ចំពោះស្ត្រីដែលមានការវិវត្តយឺតប៉ុន្តែធម្មតា ។
- ទោះជាយ៉ាងនេះក្តី សមាជិកបង្គោលនៃគោលការណ៍ណែនាំនេះបានកំណត់ប្រើនិយមន័យដូចគ្នាទៅនឹងអនុសាសន៍របស់អង្គការសុខភាពពិភពលោកពីមុន ។ ដូច្នេះយើងទុកនិយមន័យ **រយៈសកម្ម** គឺពីពេលមាត់ស្បូនបើកបាន **៣ស.ម រហូតមាត់ស្បូនបើកអស់ ។** វាក៏គោរពទៅតាមពិធីសារថ្នាក់ជាតិរបស់ប្រទេសកម្ពុជាដែរ ។
- ចេតនាក្នុងការទុកនិយមន័យនេះគឺ**ដើម្បីការពារការបញ្ជូនយឺតយ៉ាវការឈឺពោះសម្រាលដែលអូសបន្លាយ**ពីមណ្ឌលសុខភាព ពិសេសនៅតំបន់ជនបទ ។ ដូច្នេះយើងមិនគួរធ្វើតាមអនុសាសន៍ចាស់នៃរយៈសកម្មនិងនិយមន័យការឈឺពោះ សម្រាលអូសបន្លាយក្នុងថ្នាក់មន្ទីរពេទ្យបង្អែកនោះទេ ។ អនុសាសន៍ថ្មីរបស់អង្គការ សុខភាពពិភពលោក នឹងត្រូវបានពិនិត្យនៅក្នុងការពិភាក្សាផ្សេងទៀតសម្រាប់ថ្នាក់មូលដ្ឋានសុខាភិបាលដែលមានកម្រិតខ្ពស់ ។

## ៥-៣. អនុវត្តការប៉ាន់ប្រមាណការវិវត្តនៃការឈឺពោះសម្រាល

《**សង្ខេប**》
– ចាំបាច់ក្នុងការប៉ាន់ប្រមាណការវិវត្ត ការសម្រាលឱ្យបានគ្រប់ជ្រុងជ្រោយដោយ ការសង្កេតទៅលើ ៤Ps ។
– លក្ខណ្ឌនៃសមាសភាគ ៤Ps ( **កម្លាំង (Power) ផ្លូវឆ្លងកាត់ (Passage) អ្នកធ្វើដំណើរ (Passenger) និងផ្លូវចិត្ត (Psychology)** ) ផ្លាស់ប្តូរបន្តិចម្តងៗផ្អែកលើដំណាក់កាលនៃការឈឺពោះសម្រាល ។

### ៥-៣-១. កម្លាំង

- '**កម្លាំង**'គឺជា**ការកន្ត្រាក់ស្បូន ។** វាគឺជាកម្លាំងក្នុងការរុញច្រានទារកចេញពីស្បូនឆ្លងកាត់ផ្លូវសម្រាល ។ អរគុណដល់កម្លាំងនៃការកន្ត្រាក់ស្បូនដែលធ្វើឱ្យមានបម្រែបម្រួល**ផ្លូវឆ្លងកាត់** ( **មាត់ស្បូននិង ទ្វារមាស** ) និង**អ្នកធ្វើដំណើរ** ( **ទារកក្នុងផ្ទៃ ពិសេសភាពជ្រួសឆ្អឹងក្បាល និងការបង្វិលក្បាល** ) ។
- មានសមាសបីនៃការកន្ត្រាក់ស្បូនដែលត្រូវធ្វើការវាស់វែង និងប៉ាន់ប្រមាណ ។ សមាសភាគនោះមាន **រយៈពេល**នៃការកន្ត្រាក់ **ភាពញឹកញាប់**នៃការកន្ត្រាក់ និង**អាំងតង់ស៊ីតេ** ( **កម្លាំង** ) នៃការកន្ត្រាក់ ។ របៀបវាស់សមាសភាគនិមួយៗមាន៖
  - **រយៈពេល**៖ កំណត់រយៈពេលនៃ**ការកន្ត្រាក់ម្តងៗគិតជាវិនាទី ។**
  - **ភាពញឹកញាប់**៖ រាប់**ចំនួននៃការកន្ត្រាក់ក្នុងរយៈពេល ១០ នាទី ។**
  - **អាំងតង់ស៊ីតេ**( **កម្លាំង** )៖ សង្កេតមើល**ប្រតិកម្ម**របស់ស្ត្រីទាក់ទងនឹងការកន្ត្រាក់ស្បូន និងស្ទាបរក**ភាពរឹងនៃពោះ ។**
- លក្ខណៈនៃសមាសភាគនិមួយៗ ផ្លាស់ប្តូរបន្តិចម្តងៗ តាមដំណាក់កាលនៃការឈឺពោះសម្រាល ។ វាត្រូវបានបង្ហាញនៅក្នុងតារាង៥B ។

**តារាង៥ខ៖ ការផ្លាស់ប្តូរលក្ខណៈនៃការកន្ត្រាក់ស្បូន**

| ដំណាក់កាលនៃការឈឺពោះសម្រាល | រយៈពេល | ភាពញឹកញាប់ | អាំងតង់ស៊ីតេ (កម្លាំង) |
|---|---|---|---|
| (មុនឈឺពោះសម្រាល) | ត្រឹម ៣០វិនាទី | ១៥-២០នាទីម្តង | ខ្សោយ (ពេលខ្លះពិបាកប៉ាន់ស្មាន) គ្មានការឈឺពោះជាប់ មានពេលសម្រាក |
| ដំណាក់កាលទី១/ រយៈយឺត | ចន្លោះ ២០ ទៅ ៤០វិនាទី | កើនឡើងបន្តិចម្តងៗពីកន្ត្រាក់ ពីម្តងដង ឬ ២ដង ទៅ ៤ ឬ៥ដងក្នុង១០ នាទី | ខ្សោយទៅមធ្យម គ្មានការឈឺពោះជាប់ មានពេលសម្រាក |
| ដំណាក់កាលទី១/ រយៈសកម្ម | ត្រឹម ៦០វិនាទី | កន្ត្រាក់ត្រឹម៥ដងក្នុង១០ នាទី | មធ្យមទៅខ្លាំង គ្មានការឈឺពោះជាប់ មានពេលសម្រាក |
| ដំណាក់កាលទី២ | ប្រហែល ៦០វិនាទី | ដូចគ្នានឹងរយៈសកម្មដែរ | ខ្លាំង គ្មានការឈឺពោះជាប់ មានពេលសម្រាក |

- ដូចដែលបានបង្ហាញនៅក្នុងតារាង៥ខការកន្ត្រាក់ស្បូនជាធម្មតាចាប់ផ្តើមពី ‘ភាពញឹកញាប់ ដែលខ្លី និងតិច’ ។ ភាពញឹកញាប់កាន់តែវែងទៅ ច្រើនឡើង និងខ្លាំងជាងមុន បន្តិចម្តងៗ ។ ទោះជាយ៉ាងនេះក្តីសូមកត់សម្គាល់ថា**ការវិវត្តនេះខុសគ្នាពីស្ត្រី ម្នាក់ទៅស្ត្រីម្នាក់ទៀត ។** ទោះបីរយៈពេលខ្លីជាង ហើយភាពញឹកញាប់តិចជាងការរំពឹងទុក អ្នកអាចបន្តសង្កេតស្ត្រីដរាបណាមានការវិវត្តការឈឺពោះសម្រាល (ការបើកមាត់ស្បូននិងការចុះនៃក្បាលកូន) ។

<ការប្រុងប្រយ័ត្នក្នុងការសង្កេត**ការកន្ត្រាក់ស្បូន**>

- ប្រសិនបើស្បូនកន្ត្រាក់ ‘**ខ្សោយពេក**’ ឬ ‘**ខ្លាំងពេក**’ នោះបញ្ជាក់ពី**ភាពមិនធម្មតា ។**

- **'ខ្សោយពេក'** អាចត្រូវបានគេវាយតម្លៃបានដោយ **រយៈពេលខ្លី (ត្រឹម ៣០ វិនាទី)**; ភាពញឹកញាប់តិចជាងពីរដងក្នុង ១០ នាទី ហើយអាំងតង់ស៊ីតេខ្សោយ ។ វាអាចស្ថិត នៅក្នុងដំណាក់កាលការ**ឈឺពោះសម្រាលមិនពិត(មុនឈឺពោះសម្រាល) ។** ប្រសិន បើមានការឈឺពោះសម្រាលមិនពិត ការកន្ត្រាក់ស្បូននឹងបាត់ទៅវិញដោយគ្មានការផ្លាស់ប្តូរមាត់ស្បូន ។ ដូច្នេះការ**តាមដានបន្ត**គឺការចាំបាច់ ។ សូមកុំច្រលំការឈឺពោះសម្រាលមិនពិតជាមួយនឹងការឈឺពោះសម្រាលអូសបន្លាយ (នឹងធ្វើការពិពណ៌នាបន្ទាប់ពីនេះ) ។
- **'ខ្លាំងពេក'** អាចត្រូវបានគេវាយតម្លៃប្រសិនបើរយៈពេលនៃការកន្ត្រាក់**ច្រើនជាងមួយនាទី ឬ ជាបន្តបន្ទាប់**; ភាពញឹកញាប់នៃការកន្ត្រាក់ស្បូន (**៦ដងឬច្រើនជាងនេះក្នុង ១០នាទី**) ឬ ស្ត្រីត្អូញត្អែរថាមានការ**កន្ត្រាក់ខ្លាំងហួស ។** ការកន្ត្រាក់ស្បូនខ្លាំងហួសអាច ជាសញ្ញា**សុករបើកមុនសម្រាល (DPPNI) ការរហែក ឬ ការត្រៀមរហែកស្បូន ឬ ការប្រើប្រាស់ថ្នាំមិនត្រឹមត្រូវ** (អុកស៊ីតូស៊ីន មីហ្សូប្រូស្តូល ថ្នាំបុរាណ-ល-) ដែលភ្ញោចការកន្ត្រាក់ស្បូន ។ ត្រូវវាយតម្លៃភ្លាមៗលើស្ថានភាពទារក និងម្តាយ ប្រសិនបើរកឃើញប្រភេទនៃការកន្ត្រាក់ស្បូនមិនធម្មតាបែបនេះ ។

## ៥-៣-២. ផ្លូវឆ្លងកាត់

- **'ផ្លូវឆ្លងកាត់'** មានន័យថាជា **ផ្លូវសម្រាប់ឆ្លង**ពីក្នុងស្បូនមកក្រៅរាងកាយរបស់ម្តាយ ។
- **អាងត្រគាក** គឺជាផ្នែកសំខាន់នៃផ្លូវឆ្លងកាត់។ វាមានឆ្អឹងនិងមានប្រហោងមួយនៅខាងក្នុង ។ ធ្វើការពិនិត្យទម្រង់រូបរាងនិងទំហំនៃអាងត្រគាកដោយប្រុងប្រយ័ត្ន ពីព្រោះការសម្រាលធម្មតានឹងមិនអាចទៅរួចទេប្រសិនបើមានការខូចទ្រង់ទ្រាយអាងត្រគាកធ្ងន់ធ្ងរ ។ ការខូចទ្រង់ទ្រាយនៅក្នុងសន្លាក់ត្រគកក៏អាចជាឧបសគ្គនៃការសម្រាលធម្មតាផងដែរ ។
- **មាត់ស្បូនបើកនិងរលប់** ដោយសារការកន្ត្រាក់ស្បូននិងសម្ពាធពីខាងក្នុងស្បូន។ **ការបើកមាត់ស្បូន**អាចវាស់បានដោយម្រាមដៃនៅពេលដែលអ្នកប៉ះមាត់ស្បូន ។ វាមានលក្ខណៈប្រសើរជាងក្នុងការអនុវត្តន៍ការវាស់វែងដោយប្រើប្រាស់គំរូមួយនៃការបើកមាត់ស្បូន ។ ការត្រួតពិនិត្យការពិនិត្យទ្វារមាសសារឡើងវិញដោយគ្រូដឹកនាំ (អ្នកបណ្តុះបណ្តាល) ក៏ជាវិធីសាស្រ្តដ៏មានប្រសិទ្ធភាពមួយសម្រាប់ការរៀនសូត្ររបស់អ្នកទទួលការបណ្តុះបណ្តាលផងដែរ ។
- **ការរលប់មាត់ស្បូន**អាចពិនិត្យដឹងដោយម្រាមដៃ ។ វាគឺជា**ប្រវែងនៃមាត់ស្បូន ។** ប្រសិនបើការបើកមាត់ស្បូនតិចតួច (ឧទាហរណ៍ ២ឬ៣ស.ម) អ្នកប្រហែលជាស្ទាបដឹងថាមាត់ស្បូនវែង ។ នៅពេលមាត់ស្បូនបើកអស់ ជាធម្មតាមាត់ស្បូនរលប់បាត់ ។ ដោយសារតែការបើកមាត់ស្បូនកើតឡើង ដោយ

អសកម្ម ការតាមដានសមាសភាគផ្សេងទៀតដូចជា កម្លាំង ផ្លូវឆ្លងកាត់ អ្នកធ្វើដំណើរ និងផ្លូវចិត្តមានសារៈសំខាន់ណាស់ ពិសេសប្រសិនបើអ្នកគិតថា ការបើកមាត់ស្បូនមិនគ្រប់គ្រាន់ ។

### ៥-៣-៣. អ្នកធ្វើដំណើរ

#### ៥-៣-៣-១. អ្វីដែលត្រូវតាមដាន

- អ្នកធ្វើដំណើរគឺ**ទារក** ដែលបន្តធ្វើដំណើរតាមផ្លូវដ៏តូចចង្អៀត ។ ទារកព្យាយាមសម្របសម្រួលក្បាលរបស់គេទៅនឹងទម្រង់រូបរាងនៃអាងត្រគាកម្តាយ ។ ការសម្របសម្រួលនេះមាន **'ការជ្រមុជ (Flexion)' 'ការបង្វិល (Rotation) ' និង 'ភាពជ្រួសនៃឆ្អឹងក្បាល (Moulding) '** ។
- **ក្នុង**ដំណើរការនៃការសម្រាលកូនរបស់ទារក ក្បាលទារកបន្តចុះចូលក្នុងអាងត្រគាក និងចុះចេញមកខាងក្រៅ ។ វាមានសារៈសំខាន់ណាស់ក្នុងការដឹងពីកាយវិភាគសាស្ត្រនៃអាងត្រគាក និងក្បាលរបស់ទារកក្នុងស្ថានភាពវិមាត្របីដើម្បីដឹងពីការវិវត្តន៍ ។ អ្វីដែលយើងត្រូវតាមដាន និងប៉ាន់ប្រមាណគឺ**ដំណើរការទាំងមូលនៃការចុះនៃក្បាលកូន** និង**ការបង្វិល** និង**ភាពជ្រួសគ្នា** ។

#### ៥-៣-៣-២. កាយវិភាគសាស្ត្រ

- **<u>ការជ្រមុជក្បាល (Flexion)</u>** មានន័យថា**ការបត់ក្បាលទៅមុខ** ។ វាអាចឱ្យក្បាលចូលក្នុងអាងត្រគាកក្នុងបរិមាត្រដែលតូចបំផុត ។ ទោះជាយ៉ាងណាក៏ ដោយប្រសិនបើក្បាលទារកតូចពេក ឬ អាងត្រគាកម្តាយធំពេក ការជ្រមុជនេះអាចនឹងមានតិចតួច ឬមិនមានការជ្រមុជ ។
- **<u>ការបង្វិល</u>** គឺជា**ការវិវត្តក្នុងការសម្របសម្រួលទម្រង់នៃក្បាលខាងក្នុងប្រហោងអាងត្រគាក ។** ក្បាលទារកមានរាងពងក្រពើប្រសិនបើយើងមើលពីកំពូល ។ ទម្រង់រូបរាងនៃអាងត្រគាកច្រកលើនិងច្រកក្រោមក៏មានរាងពងក្រពើផងដែរ តែទិសដៅនៃអ័ក្សវែងនិងអ័ក្សខ្លីខុសគ្នា ។ ចំងាយនៃឆ្អឹងបណ្តោយអាងត្រគាក (Antero-posterior) ខ្លីជាងចំងាយទទឹងអាងត្រគាក (Transverse) នៅច្រកលើនៃអាងត្រគាក ។ ដោយឡែកចំងាយទទឹងអាងត្រគាក ខ្លីជាងបណ្តោយអាងត្រគាកនៅច្រកក្រោមនៃអាងត្រគាក ។ នេះគឺជាហេតុផលដែលក្បាលទារកគួរតែបង្វិលនៅក្នុងអាងត្រគាក ។
- **<u>ភាពជ្រួសគ្នា</u>** គឺជា**យន្តការផ្សេងទៀតក្នុងការធ្វើឱ្យក្បាលទារកតូចជាង ។** ក្បាលទារកមានឆ្អឹងប្រឡង់តាលពីរ **ឆ្អឹងប៉ារីយ៉េតាល់ពីរ** និង**ឆ្អឹងអុកស៊ីពុតមួយ** ។ នៅតាមព្រំដែននៃឆ្អឹងនិមួយៗមានការបើកតូចដែលគេហៅថា **ថ្នេរ** និង**បង្ហើយ ។** ភាពជ្រួសគ្នា គឺជាការ**ផ្លាស់ប្តូរកាយវិភាគមួយនៃរូបរាង**ដែលជាយ**ឆ្អឹងក្បាលគងគ្នានៅត្រង់ថ្នេរក្បាល** ។ វាអនុញ្ញាតិឱ្យមានការកាត់បន្ថយក្នុងទំហំនៃអង្កត់ផ្ចិតនៃក្បាលទារកបង្ហាញ ។

- **Caput succedaneum** គឺជា**ការហើមនៃស្បែក**ក្បាល ។ វាបណ្តាលមកពីការសង្កត់ពីខាងក្រៅលើក្បាលទារកពីផ្លូវសម្រាល ។

**៥-៣-៣-៣. ការវាស់កម្រិតចុះនៃក្បាលកូន**

- វាគឺជាវិធីនៃការស្ទាបពោះដើម្បីប៉ាន់ប្រមាណការចុះនៃក្បាលកូន ។ កម្រិតចុះនៃក្បាលកូនត្រូវបានវាស់ដោយការ**ស្ទាបពោះជាមួយនឹងម្រាមដៃ**ដោយដាក់ម្រាមដៃនៅពីលើឆ្អឹងថ្ងាស (Symphysis pubis) (ដែលនៅគែមខាងមុខនៃឆ្អឹងពុយប៊ីស) ហើយត្រូវបានបង្ហាញ តាមរយៈ**ចំនួនប្រាំនៅខាងលើជាយឆ្អឹងមាន៥/៥, ៤/៥, ៣/៥, ២/៥, ១/៥, ០/៥** (រូបភាព៥C) ។
- ចំណុចដែលត្រូវបញ្ជាក់គឺក្បាលកូនទាំងមូល '**លលាដ៏ក្បាលខាងមុខ (Sinciput)**' '**លលាដ៏ក្បាលខាងក្រោយ (Occiput)**' ។ រូបភាពបួនឬប្រាំនៃការវាស់ត្រូវបានបង្ហាញដូចខាងក្រោម (រូបភាព៥D, ៥E) ។ រូបភាពខាងក្រោមបង្ហាញពីរូបភាពក្បាល និងចំណុចពីរនៃក្បាល (លលាដ៏ក្បាលខាងមុខ និងលលាដ៏ក្បាលខាងក្រោយ)។ រូបភាព ៥D ក៏បញ្ជាក់ពីរបៀបដែលក្បាលកូនបង្វិលតាមរយៈការចុះនៃក្បាលកូនដែរ ។ អ្នកត្រូវដឹងថាការបង្វិលចាប់ផ្តើមនៅពេលក្បាលទារកមកដល់ជិតអាងត្រគាក ។




**រូបភាពទី៥C កំរិតនៃក្បាលវាស់ដោយការស្ទាបពោះប្រើម្រាមដៃ**
ប្រភពរូបភាព៖ *ប៉ាតូក្រាហ្វតាមដានការឈឺពោះសម្រាល* ផ្តល់ដោយផ្នែកបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក




រូបភាព ៥០ ការចុះនិងការបង្វិលនៃក្បាលកូន




S: សាំងស៊ីពុត Sinciput - O: អុកស៊ីពុត Occiput

**រូបភាព៥E ការចុះនៃក្បាលកូន**

ប្រភពរូបភាព៖ *https://www.madeformums.com/pregnancy/what-does-it-mean-when-your-babys-head-is-engaged/*

## ៥-៣-៣-៤. ការវាស់ភាពជ្រួសគ្នានៃឆ្អឹងក្បាលនិង*ការហើមនៃស្បែកក្បាល*

《**សង្ខេប**》

- ភាពជ្រួសគ្នានៃឆ្អឹងក្បាលនិងការហើមស្បែកក្បាលអាចជាសូចនាករមួយក្នុងចំនោមសូចនាករផ្សេងទៀតដែលអាចឱ្យដឹងពីវិសមាមាត្ររវាងឆ្អឹងក្បាលទារកនិងអាងត្រគាកម្តាយ (CPD) ឬការឈឺពោះសម្រាលអូសបន្លាយ ។
- នៅពេលពិនិត្យទ្វារមាស ប៉ះក្បាលទារករកមើលថាមានការជ្រួសគ្នានៃឆ្អឹងប៉ារីយ៉េតាល់ (ភាពជ្រួសគ្នា) និងការហើមនៃស្បែកក្បាលត្រង់ផ្នែកដែលទារកបង្ហាញ (Caput Succedaneum) ឬទេ ។
- ភាពប្រែប្រួលនៃក្បាលនេះគឺដោយសារសម្ពាធខ្លាំងពីផ្លូវសម្រាល ។
- ភាពជ្រួសគ្នាខ្លាំងពេកអាចបញ្ជាក់ថាអាចនឹងមានវិសមមាត្ររវាងឆ្អឹងក្បាលទារក និងអាងត្រគាកម្តាយ។

### ៥-៣-៣-៤-១. ភាពជ្រួសនៃឆ្អឹងក្បាល

- កម្រិតនៃភាពជ្រួសគ្នាអាចវាស់វែងបាននៅពេលមាន**ការប្រែប្រួលឆ្អឹងលលាដ៏ក្បាលរបស់ទារក** ។ វាចែកជាបួនកម្រិតដូចខាងក្រោម៖

0 ឆ្អឹងនៅដាច់ពីគ្នា ហើយថ្នេរក្បាលត្រូវបានស្ទាបប៉ះយ៉ាងស្រួល ។

\+ ឆ្អឹងលើបន្ទូលក្បាល គ្រាន់តែប៉ះគ្នាប៉ុណ្ណោះ ។

++ ឆ្អឹងនៅលើបន្ទូលក្បាលគងលើគ្នាបន្តិច (ជ្រួស) ។

+++ឆ្អឹងលើបន្ទូលក្បាលគងលើគ្នាចូលជ្រៅខ្លាំង (ជ្រួសខ្លាំង) ។




**រូបភាព៥F កំរិតនៃភាពជ្រួសគ្នានៃឆ្អឹងក្បាល**

ប្រភពរូបភាព៖ https://elearning.rcog.org.uk//easi-resource/maternal-and-fetal-assessment/examination/moulding

- សូមចងចាំថាកម្រិតនៃភាពជ្រួសគ្នានេះអាស្រ័យលើ **ទំនាក់ទំនងរវាងទំហំនៃក្បាលទារក** (**អ្នកធ្វើដំណើរ**) **និង ទំហំនៃឆ្អឹងអាងត្រគាក** (**ផ្លូវឆ្លងកាត់**) ។
- កម្រិតនៃភាពជ្រួសគ្នាខ្លាំង (+++) បញ្ជាក់ថាអាងត្រគាកតូចចង្អៀតសម្រាប់ក្បាលរបស់កូន ។ ប៉ុន្តែនេះមិនមែនសុទ្ធតែមានន័យ ថាមានវិសមមាត្ររវាងក្បាលទារកនឹងឆ្អឹងអាងត្រគាកម្តាយ (CPD) នោះទេ ពីព្រោះភាពជ្រួសគ្នាគឺជាវិធីសាស្រ្តមួយសម្រាប់ឱ្យទារកឆ្លងកាត់ផ្លូវសម្រាលតូចចង្អៀតបាន ។ ដរាបណាមានការវិវត្តនៃការឈឺពោះសម្រាល៖ ជាឧទាហរណ៍ការចុះនៃក្បាលកូនបានល្អសមស្របនឹងការកន្ត្រាក់ស្បូន នោះគឺអាចបញ្ជាក់ថាការវិវត្តមានភាពធម្មតា ។
- នៅក្នុងន័យផ្សេងទៀត **ចូលកុំធ្វើរោគវិនិច្ឆ័យវិសមាមាត្រ** រវាងក្បាលទារកនិងឆ្អឹងអាងត្រគាកម្តាយតែជាមួយភាពជ្រួសគ្នានៃក្បាលកូន ។
- ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកគិតថាមានភាពជ្រួសគ្នាខ្លាំងហើយក្បាលទារកនៅតែអណ្តែត (មិនចុះចូលច្រកលើនៃអាងត្រគាក) នោះជាសញ្ញានៃវិសមាមាត្ររវាងក្បាលទារក និងឆ្អឹងអាងត្រគាកម្តាយ ។

៥-៣-៣-៤-២. ការហើមនៃស្បែកក្បាល (Caput Succedaneum)

- មានការពិបាកក្នុងការដាក់ឱ្យត្រូវ ‘ស្តង់ដា’ នៃការពិនិត្យការហើមស្បែកក្បាល ពីព្រោះមានតែមធ្យោបាយតែមួយគត់គឺការលូកពិនិត្យទ្វារមាស ហើយជាញឹកញាប់មានការពិបាកក្នុងការប៉ះគ្រប់ផ្នែកនៃក្បាលកូន ។

- ទោះជាយ៉ាងនេះក្តី ពេលខ្លះការហើមនេះរាំងស្ទះដល់ការវាយតម្លៃភាពជ្រួសគ្នា ព្រោះតែការ**ហើមក្រាស់**នៅនឹងស្បែកមិនអាចឱ្យដឹងបានពីភាពជ្រួសគ្នានៃឆ្អឹងក្បាល ។
- ដូច្នេះ អ្នកគួរពិភាក្សាជាមួយអ្នកធ្វើការជាមួយគ្នាដើម្បីការវាយតម្លៃទាំងអស់គ្នា ។

## ៥-៤. ការប៉ាន់ប្រមាណរយៈពេលនៃការឈឺពោះសម្រាល

### ៥-៤-១. លក្ខណៈវិនិច្ឆ័យនៃការប៉ាន់ប្រមាណ

- លក្ខណៈវិនិច្ឆ័យគឺត្រូវបានគេឱ្យនិយមន័យតែក្នុងដំណាក់កាលទីមួយនៃការឈឺពោះសម្រាលតែប៉ុណ្ណោះ ប៉ុន្តែចែកគ្នារវាងរយៈយឺតនិងរយៈសកម្ម។

**សំគាល់៖** សមាជិកបង្គោលនៃគោលការណ៍ណែនាំនេះកំណត់យកការប្រើប្រាស់ប៉ាតូក្រាហ្វមុនរបស់អង្គការសុខភាពពិភពលោក ។ ដូច្នេះលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃរយៈពេលនៃការឈឺពោះសម្រាលអាស្រ័យលើប៉ាតូក្រាហ្វមុននោះ ។

**តារាង ៥៤. លក្ខណៈវិនិច្ឆ័យរយៈពេលឈឺពោះសម្រាលក្នុងរយៈយឺតនិងរយៈសកម្មក្នុង ដំណាក់កាលទីមួយ**

| រយៈ | រយៈពេលឈឺពោះសម្រាល | ការឈឺពោះសម្រាលអូសបន្លាយ |
|---|---|---|
| យឺត | ៨ ម៉ោង<br>(ត្រូវបញ្ជាក់ច្បាស់ថាជាការឈឺពោះសម្រាលពិត ឬ មិនពិត) | ច្រើនជាង ៨ ម៉ោងក្នុងរយៈយឺត<br>(បញ្ជាក់ថាតើជាការឈឺពោះសម្រាលពិត ឬ មិនពិត) |
| សកម្ម | យ៉ាងហោចមាត់ស្បូនបើកបាន ១ស.ម ក្នុង ១ម៉ោង | មាត់ស្បូនបើកបានតិចជាង ១ស.ម ក្នុង ១ម៉ោង នៅរយៈសកម្ម |

## ៥-៥. ស្ថានភាពដែលត្រូវពិចារណា

ដូចដែលបានពន្យល់នៅក្នុង *៥.១. ៤Ps - កំលាំង ផ្លូវឆ្លងកាត់ អ្នកធ្វើដំណើរ និងផ្លូវចិត្ត* មាន**កត្តាបួនសំខាន់**សម្រាប់ការវិវត្តការឈឺពោះសម្រាល ។

- **‘កម្លាំង’** វាគឺជា **‘ការឈឺពោះ’** ឬ **‘ការកន្ត្រាក់ស្បូន’** ដែលជាសមាសភាគសំខាន់ក្នុងការសម្រាល ។ ប្រសិនបើអ្នកគិតថាកម្លាំងមិនគ្រប់គ្រាន់ក្នុងរយៈយឺត សូមគិតទៅដល់ **‘ការឈឺពោះសម្រាលមិនពិត’** ដែលប្រហែលជាកើតមាន ។
- កម្លាំងមិនគ្រប់គ្រាន់ក្នុងរយៈសកម្ម អាចជា **‘ការឈឺពោះសម្រាលខ្សោយ’ ។**
- មានមូលហេតុសំខាន់ៗមួយចំនួននៃការ ‘ឈឺពោះសម្រាលខ្សោយ’ ដូច្នេះត្រូវសង្កេតមើល ដោយប្រុងប្រយ័ត្នពីមូលហេតុនិងការគ្រប់គ្រងដែលសមស្រប ។
- ‘**អ្នកធ្វើដំណើរ**’ និង ‘**ផ្លូវឆ្លងកាត់**’ ជានិច្ចកាលមាន**ទំនាក់ទំនងជាមួយគ្នា ។** អាចប្រើពាក្យម៉្យាងទៀតថា**ត្រូវវាយតម្លៃ**ស្ថានភាពនិងទំនាក់ទំនងទាំងពីរនេះ ។ ឧទាហរណ៍មានឡានមួយ ដែលមានល្បឿនយឺត ។ សូមទស្សទាយ៍ថាមូលហេតុ មកពីអ្វី ។ វាប្រហែលមកពីស្ថានភាពផ្លូវ ដែលជាកត្តា ‘ផ្លូវឆ្លងកាត់’ ។ វាប្រហែលជា មកពីស្ថានភាពអាក្រក់ របស់ឡានផ្ទាល់ដែលជាកត្តានៃ ‘អ្នកធ្វើដំណើរ’ ។ វាប្រហែលជាមកពីទំហំឡានធំនៅក្នុងផ្លូវតូចចង្អៀត ដែលបណ្តាលមកពីកត្តាទាំងពីរ ‘អ្នកធ្វើដំណើរ’ និង ‘ផ្លូវឆ្លងកាត់’ ។
- សូមចង់ចាំ៤Ps ( **កំលាំង ផ្លូវឆ្លងកាត់ អ្នកធ្វើដំណើរ និងផ្លូវចិត្ត** ) និងទំនាក់ទំនងរបស់វានៅពេលកត់ត្រាចូលក្នុង**ប៉ាតូក្រាហ្វ ។**
- ពេលវេលាតាមដានបន្តត្រូវបានបង្ហាញនៅក្នុង ‘ឧបសម្ព័ន ២ តារាងពេលវេលាសង្កេត’ ។
- យើងមិនអាចធ្វើការវាយតម្លៃតែមួយចំណុចដើម្បីឱ្យដឹងពីការវិវត្តនៃការឈឺពោះសម្រាលបានទេ ។ បន្ទាប់ការវាយតម្លៃដំបូង សូមតាមដានបន្តតាមតារាងនៃឧបសម្ព័ន ២ ។

# ជំពូកទី ៦ ការសង្កេតមើលស្ថានភាពម្តាយ

**សង្ខេប**

- វត្ថុបំណងនៅក្នុងជំពូកនេះគឺ (១) កំណត់ពីភាពមិនធម្មតានៃស្ថានភាពម្តាយ និង (២) ផ្តល់ការសង្គ្រោះបឋមមុនពេលបញ្ជូន ។
- ចាំបាច់ត្រូវពិនិត្យមើលសញ្ញាជីវិត (សម្ពាធឈាម ជីពចរ សីតុណ្ហភាពរាងកាយ) ការពិនិត្យទឹកនោម និងការធ្លាក់ឈាមដើម្បីបញ្ជាក់ ថាតើស្ថានភាពម្តាយមានសញ្ញាមិនធម្មតាណាមួយដែរឬទេក្នុងអំឡុងពេលឈឺពោះសម្រាល ។
- ជំងឺបម្រុងក្រឡាភ្លើង ការបង្ករោគនៅក្នុងស្បូន ការធ្លាក់ឈាម គឺជាសញ្ញាគ្រោះថ្នាក់ដល់ជីវិតដែលកើតមានជាញឹកញាប់ចំពោះម្តាយនិងទារកក្នុងកំឡុងពេលឈឺពោះសម្រាល ។
- សញ្ញាគ្រោះថ្នាក់របស់ម្តាយទាំងនោះ ក៏ប៉ះពាល់ដល់ស្ថានភាពរបស់ទារកនៅក្នុងផ្ទៃដែរ ។

## ៦-១. សម្ពាធឈាម

《**សង្ខេប**》

- ការលើសសម្ពាធឈាមរបស់ម្ដាយ ប៉ះពាល់ដល់សរីរាង្គផ្សេងៗ និងអាចឈានទៅដល់ការខូចមុខងារនៃសរីរាង្គ ។ វាអាចបណ្ដាលឱ្យទារកក្នុងផ្ទៃចុះខ្សោយ និងគ្រោះថ្នាក់ដល់ម្ដាយ។ វាអាចវិវត្តទៅជាជម្ងឺក្រឡាភ្លើង ។
- វាស់សម្ពាធឈាមក្នុងស្ថានភាពសម្រាក និង ពេលស្បូនឈប់កន្ត្រាក់ ។
- នៅពេលសម្ពាធឈាមអតិបរិមា ឬសម្ពាធឈាមអប្បបរិមាលើសខ្លាំង ត្រូវធ្វើការបញ្ជូនស្ត្រី ។
- នៅពេលសម្ពាធឈាមអតិបរិមា ឬ សម្ពាធឈាមអប្បបរិមាលើសមធ្យម ត្រូវឱ្យស្ត្រីសម្រាក និងវាស់សម្ពាធឈាមនៅរយៈពេល ១៥នាទីបន្ទាប់ម្ដងទៀត ។ ត្រូវពិនិត្យរកសញ្ញានៃការលើសសម្ពាធឈាម (ឈឺក្បាលខ្លាំង ស្រវាំងភ្នែក ឬឈឺនៅចុងដង្ហើម) ផងដែរ ។

### ៦-១-១. និយមន័យនៃសម្ពាធឈាម និងប្រូតេអ៊ីនក្នុងទឹកនោម

#### ៦-១-១-១. សម្ពាធឈាម

- នៅពេលបេះដូងលោត ឈាមត្រូវបានរុញចេញពីបេះដូងទៅកាន់ដងខ្លួន ។ សម្ពាធឈាមគឺជា សម្ពាធចរន្តឈាមរត់ទល់នឹងសរសៃឈាម ។ សម្ពាធឈាមពីរប្រភេទត្រូវបានវាស់:

  (១) សម្ពាធឈាម**អតិបរិមា**: សម្ពាធឈាម**ខ្ពស់បំផុត**ក្នុងពេលបេះដូងលោត ។

  (២) សម្ពាធឈាម**អប្បបរិមា**: សម្ពាធឈាម**ទាបបំផុត**នៅចន្លោះពេលបេះដូងលោត ។

#### ៦-១-១-២. របៀបវាស់

៦-១-១-២-១. សម្ពាធឈាម

- ការវាស់សម្ពាធឈាម គឺត្រូវវាស់ក្នុងស្ថានភាពសម្រាក និងពេលស្បូនឈប់កន្ត្រាក់ ពីព្រោះសម្ពាធឈាមនឹងកើនឡើងទៅតាមសកម្មភាពដូចជា ការកន្ត្រាក់របស់ស្បូន និងការឈឺពោះ ហើយតាមកត្តាសុខភាពផ្លូវចិត្ត ដូចជាធុញថប់ ឬ ភ័យខ្លាច ។
- នៅពេល**សម្ពាធឈាមអតិបរិមា ធំជាងឬស្មើ ១៤០-១៦០** មមបារត **ឬសម្ពាធឈាមអប្បបរិមា ធំជាងឬស្មើ ៩០-១១០ មមបារត ៖**

(១) ទុកឱ្យស្ត្រីសម្រាក និងវាស់សម្ពាធឈាមនៅ**រយៈពេល១៥ នាទីបន្ទាប់ម្ដងទៀត**

(២) ពិនិត្យរក**សញ្ញាលើសសម្ពាធឈាម** (មើល *៦-២. សញ្ញាលើសសម្ពាធឈាម* ទំព័រ៩៨)

### ៦-១-១-៣. ចំណាត់ថ្នាក់នៃសម្ពាធឈាម

| | **សម្ពាធឈាមធម្មតា** | **លើសសម្ពាធឈាមមធ្យម** | **លើសសម្ពាធឈាមធ្ងន់ធ្ងរ** |
|---|---|---|---|
| សម្ពាធឈាម អតិបរិមា Systolic | តិចជាង ១៤០មមបារត | ច្រើនជាងឬស្មើ ១៤០មមបារត | ច្រើនជាងឬស្មើ ១៦០មមបារត |
| | **និង** | **ឬ** | **ឬ** |
| សម្ពាធឈាម អប្បបរិមា Diastolic | តិចជាង ៩០មមបារត | ច្រើនជាងឬស្មើ ៩០មមបារត | ច្រើនជាងឬស្មើ ១១០មមបារត |

### ៦-១-១-៤. គ្រោះថ្នាក់នៃការលើសសម្ពាធឈាម

៦-១-១-៤-១. សម្ពាធឈាមអតិបរិមាច្រើនជាង ឬ ស្មើ ១៦០ មមបារត ឬ សម្ពាធឈាម អប្បបរិមាច្រើនជាង ឬ ស្មើ ១១០ មមបារត

- **ជំងឺបម្រុងក្រឡាភ្លើង**គឺបណ្តាលមកពីសុកតោងភ្ជាប់ជាមួយស្បូនមានភាពមិនធម្មតា ធ្វើឱ្យប៉ះពាល់ដល់ចរន្តឈាមរត់ក្នុងសុក ហើយការដែលសុកបំពេញមុខងារមិនបានល្អបែបនេះអាចបណ្តាលឱ្យលើសសម្ពាធឈាម ។ ការលើសសម្ពាធឈាមរបស់ម្តាយបណ្តាលឱ្យខូចខាតសរសៃឈាមនៃ សរីរាង្គផ្សេងៗ និងឈានទៅដល់ការខូចមុខងាររបស់សរីរាង្គនោះថែមទៀត ។ (មើល *១. ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ ១-៤. សញ្ញាជីវិតមិនធម្មតា - ការលើសសម្ពាធ ឈាមអប្បបរមា* ទំព័រ១៣)
- ជាពិសេសវាអាចប៉ះពាល់ដល់សរីរាង្គសំខាន់ដូចជា**តម្រងនោម ខួរក្បាល ភ្នែក ថ្លើម និងសួត** ហើយបង្កឱ្យមានគ្រោះថ្នាក់ផ្សេងទៀតដូចមានរៀបរាប់ខាងក្រោម ។
- សុកខូចមុខងារ បណ្តាលឱ្យមានកង្វះអុកស៊ីសែន និងសារជាតិចិញ្ចឹម ។ ជាហេតុធ្វើឱ្យការ**លូតលាស់របស់ទារកមិនល្អ** ក្នុងកំឡុងពេលមានផ្ទៃពោះ និងប្រឈមខ្ពស់នឹងទារកកើតមកមានទម្ងន់ទាប ។ ចង្វាក់បេះដូងរបស់ទារកងាយនឹងចុះខ្សោយយ៉ាងងាយ ក្នុងកំឡុងពេលឈឺពោះសម្រាលដោយសារកង្វះការផ្គត់ផ្គង់អុកស៊ីសែន ។
- ការខូចមុខងាររបស់សុក អាចបណ្តាលឱ្យមានការ**របើកសុកមុនសម្រាល ។**
- ការខូចមុខងាររបស់តម្រងនោម អាចធ្វើឱ្យមាន**ប្រូតេអ៊ីននៅក្នុងទឹកនោម** (មើល *៦.៥. ការពិនិត្យទឹកនោម* ទំព័រ១០៤)។

- ការខូចមុខងាររបស់ថ្លើម អាចបណ្តាលឱ្យ**ឈឺនៅចុងដង្ហើម ចង្អោរ ឬ ក្អួត**(មើល *៦-២. សញ្ញានៃការលើសសម្ពាធឈាម,* ទំព័រ៩៨) ។
- ការខូចខាតសរសៃឈាមខួរក្បាល អាចបណ្តាលឱ្យ**ឈឺក្បាល ។** នៅពេលដែលការខូចខាតមានសភាពធ្ងន់ធ្ងរ ឬចេះតែបន្ត វាអាចវិវត្តទៅជាការ**ប្រកាច់** (មើល *៦-២. សញ្ញានៃការលើសសម្ពាធឈាម,* ទំព័រ ៩៨) ។
- ការខូចខាតសរសៃឈាមបាតភ្នែក អាចប៉ះពាល់**គំហើញរបស់ភ្នែក** (**ស្រវាំងភ្នែក**) (មើល *៦-២. សញ្ញានៃការលើសសម្ពាធឈាម,* ទំព័រ៩៨) ។
- ការខូចមុខងាររបស់សួត អាចបណ្តាលឱ្យដកដង្ហើមញាប់ខ្លាំង ឬ**ពិបាកដកដង្ហើម ។**

៦-១-១-៤-២. សម្ពាធឈាមអតិបរិមាច្រើនជាង ឬ ស្មើ ១៤០មមបារត ឬ សម្ពាធឈាមអប្បបរិមាច្រើនជាង ឬ ស្មើ ៩០មមបារត

- សូម្បីតែការលើសសម្ពាធឈាមមធ្យម ក៏មានការប្រឈមនឹងគ្រោះថ្នាក់ដូចបានរៀប រាប់ខាងលើដែរ ហើយក៏ប្រឈមនឹងការកើនឡើងនៃសម្ពាធឈាមក្នុងកំឡុងពេលឈឺពោះសម្រាលផងដែរ ។ សម្ពាធឈាមត្រូវតាមដានទៀងទាត់រៀងរាល់មួយម៉ោងម្តង[១(p២២)] និងពិនិត្យរកមើលសញ្ញានៃការលើសសម្ពាធឈាម(មើល *៦-២. សញ្ញានៃការលើសសម្ពាធឈាម,* ទំព័រ៩៨) ។
- ចង្វាក់បេះដូងរបស់ទារកត្រូវតាមដានជាទៀងទាត់រៀងរាល់ ១៥ នាទីម្តងនៅដំណាក់កាលទី១ និងរៀងរាល់ ៥នាទីម្តងនៅដំណាក់កាលទី២នៃការឈឺពោះសម្រាល ។

## ៦-២. សញ្ញានៃការលើសសម្ពាធឈាម

《**សង្ខេប**》

- សញ្ញាខ្លះអាចកើតឡើង នៅពេលសម្ពាធឈាមកើនឡើង ឬ ការលើសសម្ពាធឈាមមិនថយចុះ ។ សញ្ញាទាំងនោះអាចបង្ហាញប្រាប់ពីភាពធ្ងន់ធ្ងរនៃការលើសសម្ពាធឈាម ។
- នៅពេលស្ត្រីលើសសម្ពាធឈាម ពិនិត្យសញ្ញាធំៗបីគឺ ឈឺក្បាលខ្លាំង ស្រវាំងភ្នែក ឬឈឺនៅចុងដង្ហើម ។ ពីព្រោះសញ្ញាទាំងនោះអាចប្រាប់ពីការខូចខាតលើសរីរាង្គខួរក្បាល និងថ្លើម ដោយសារការលើសសម្ពាធឈាមរបស់ម្តាយ ។
- នៅពេលស្ត្រីមានសញ្ញានៃការលើសសម្ពាធឈាម ស្ត្រីអាចមានជំងឺបម្រុងក្រឡាភ្លើង ឬក្រឡាភ្លើង ។

### ៦-២-១. សញ្ញានៃការលើសសម្ពាធឈាម

- សញ្ញាខ្លះអាចកើតឡើង នៅពេលសម្ពាធឈាមកើនឡើង ឬ ការលើសសម្ពាធឈាមមិនថយចុះ ។ សញ្ញាទាំងនោះអាចបង្ហាញប្រាប់ពីភាពធ្ងន់ធ្ងរនៃការលើសសម្ពាធឈាម ។

### ៦-២-២. បញ្ជាក់សញ្ញានៃការលើសសម្ពាធឈាមដោយការវាស់សម្ពាធឈាម

សាកសួរ ថាតើស្ត្រីមាន:

(១) **ឈឺក្បាលខ្លាំង**

(២) **ស្រវាំងភ្នែក**

(៣) **ឈឺនៅចុងដង្ហើម**

### ៦-២-៣. ផលវិបាកនៃការលើសសម្ពាធឈាមតាមការស្វែងចេញនូវរោគសញ្ញា

#### ៦-២-៣-១.ឈឺក្បាលខ្លាំង ស្រវាំងភ្នែក និង ឈឺនៅចុងដង្ហើម

- សញ្ញាទាំងនេះអាចចង្អុលប្រាប់ពីការខូចខាតខួរក្បាល និងថ្លើមដោយសារការលើសសម្ពាធឈាម ។ ស្ត្រីអាចមាន**ជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ** និងប្រឈមនឹងការវិវត្តទៅជាជំងឺ**ក្រឡាភ្លើង** ។
- ទោះបីជាស្ត្រីមិនមានរោគសញ្ញា ប៉ុន្តែនៅពេលដែលស្ត្រីចាប់ផ្តើមត្អូញត្អែរ អ្នកត្រូវពិនិត្យសម្ពាធឈាមរបស់គាត់ភ្លាម ។

## ៦-៣. ជីពចរ

《**សង្ខេប**》

- ជីពចរញាប់អាចបណ្ដាលមកពីធ្លាក់ឈាម គ្រុនក្ដៅ កង្វះជាតិទឹក ស្លេកស្លាំង ជំងឺបេះដូង -ល-។
- ជីពចរយឺតគឺបណ្ដាលមកពីជំងឺបេះដូង ឬអាចមកពីជំងឺខ្សោយបេះដូង ។
- ជីពចរញាប់ ហើយសម្ពាធឈាមអតិប្បរមាទាបជាសញ្ញាស្ដុកដែលអាចបណ្ដាលមកពីការធ្លាក់ឈាម ។
- រាប់ជីពចរពេលសម្រាកនិងចន្លោះពេលស្បូនឈប់កន្ត្រាក់។

### ៦-៣-១. ជីពចរក្នុងពេលមានផ្ទៃពោះ

- ជីពចរធម្មតារបស់មនុស្សពេញវ័យគឺស្ថិតនៅចន្លោះ ៦០ ទៅ ១០០ដង/មួយនាទី ។
- សម្រាប់ស្ត្រីមានផ្ទៃពោះជីពចរអាចកើនលើសពី ១០-២០ដង/ មួយនាទីច្រើនជាងស្ត្រីដែលគ្មានផ្ទៃពោះ[៦,៩] ។
- តាមសរីរៈសាស្ត្រ ជីពចរញាប់ច្រើនមានពេលធ្វើលំហាត់ប្រាណ ពេលឈឺចាប់ ឬ បញ្ហាផ្លូវចិត្ត ហើយជីពចរយឺតច្រើនឃើញមានពេលគេង និងសម្រាក ។

### ៦-៣-២. របៀបរាប់ជីពចរមនុស្សពេញវ័យ

- ជាធម្មតាគេរាប់ជីពចរនៅកដៃ ( **សរសៃអាទ័ររ៉ាដ្យាល់** ) ។
- ពេលដែលអ្នកស្ទាបមិនបាននៅកដៃ អ្នកត្រូវស្ទាបជីបចរនៅកន្លែងផ្សេងទៀត ដូចជា នៅ ក ( **សរសៃអាទ័រការ៉ូទីត** ) ឬ នៅក្រលៀន ( **សរសៃអាទ័រហ្វេម៉ូរ៉ាល់** ) ។ រាប់វាពេលដែលស្ត្រីសម្រាក និងចន្លោះពេលស្បូនឈប់កន្ត្រាក់ ។

### ៦-៣-៣. ផលវិបាកដោយសារជីពចរមិនធម្មតារបស់មនុស្សពេញវ័យ

#### ៦-៣-៣-១. ជីពចរញាប់លើសពី ១០០ ដង/មួយនាទី

- បើស្ត្រីគ្មានការធ្លាក់ឈាម និងគ្មានការឈឺចាប់មិនធម្មតាដែលបណ្ដាលមកពីការហូរឈាមខាងក្នុងទេ នោះជីពចរញាប់អាចបណ្ដាលមកពីមូលហេតុផ្សេងទៀតដូចជាគ្រុនក្ដៅ កង្វះជាតិទឹក ស្លេកស្លាំង ជំងឺបេះដូង -ល-។

- ប្រសិនបើចង្វាក់បេះដូងលោតមិនធម្មតា ត្រូវបញ្ជូនស្ត្រី ។
- ពិនិត្យរកគ្រុនក្តៅ និងរោគសញ្ញានៃការបង្ករោគដទៃទៀត (មើល *៦-៤. សីតុណ្ហភាពរាងកាយ* ទំព័រ ១០១) ។
- ប្រសិនបើស្ត្រីពិសារទឹកមិនគ្រប់គ្រាន់ លើកទឹកចិត្តស្ត្រីឱ្យពិសារទឹកបានច្រើន ។

## ៦-៤. សីតុណ្ហភាពរាងកាយ

《សង្ខេប》

- ប្រសិនបើសីតុណ្ហភាពរាងកាយលើសពី ៣៨.0 ℃, វាអាចមានការបង្ករោគ ។
- វាស់សីតុណ្ហភាពរាងកាយម្ដាយតាមក្លៀក ។
- ប្រសិនបើមានគ្រុនក្ដៅដោយសារការបង្ករោគ នោះនឹងមានរោគសញ្ញានៃការបង្ករោគផ្សេងទៀត ។
- ការបង្ករោគនៅក្នុងស្បូន និងទារកក្នុងផ្ទៃគឺជាការបង្ករោគច្រើនកើតមានក្នុងកំឡុងពេលឈឺពោះ សម្រាលជាពិសេសក្រោយពេលបែកស្រោមទឹកភ្លោះ ។ ពិនិត្យរករោគសញ្ញាផ្សេងទៀតដូចជាការធ្លាក់ស ឬ ទឹកភ្លោះមានក្លិនស្អុយ និងឈឺផ្នែកខាងក្រោមពោះពេលស្ទាប ។

### ៦-៤-១.សីតុណ្ហភាពរាងកាយស្ត្រីមានផ្ទៃពោះ

- សីតុណ្ហភាពរាងកាយស្ត្រីកើនឡើងក្នុងពេលមានផ្ទៃពោះក្នុងត្រីមាសទី ១ ដោយសារសកម្មភាពរបស់អរម៉ូន ហើយនឹងចុះមកកម្រិតធម្មតានៅចុងនៅត្រីមាសទី ២ ។

### ៦-៤-២. របៀបវាស់សីតុណ្ហភាពរាងកាយ

- កម្ដៅរាងកាយរបស់មនុស្ស**ពេញវ័យ**ជាទូទៅត្រូវបានគេវាស់នៅនឹង**ក្លៀក** ។
- ដាក់ចុងនៃក្បាលទែម៉ូម៉ែត្រ នៅចំកណ្ដាលក្លៀក ។ **ប្រសិនបើ**ក្លៀកមានបែកញើសត្រូវជូតសម្អាតជាមុនសិន ។

### ៦-៤-៣. ការចាត់ថ្នាក់សីតុណ្ហភាពរាងកាយក្នុងពេលមានផ្ទៃពោះ

- សីតុណ្ហភាពរាងកាយមិនធម្មតាគឺ **លើសពី៣៨.0**℃ ។

### ៦-៤-៤. ផលវិបាកដោយសារសីតុណ្ហភាពរាងកាយខ្ពស់

- ពេលស្ត្រីមានក្លាយរោគជាធម្មតាសីតុណ្ហភាពរាងកាយស្ត្រីកើនឡើង ដោយសារប្រព័ន្ធភាពស៊ាំស្ត្រីកំពុងប្រយុទ្ធប្រឆាំងនឹងមេរោគ ។
- ក្រៅពីការឡើងសីតុណ្ហភាពរាងកាយ ក៏មានសញ្ញាបង្ករោគផ្សេងៗទៀតផងដែរ ។

### ៦-៤-៤-១. សីតុណ្ហភាពរាងកាយលើសពី៣៨.០℃

មូលហេតុចំបងបួននៃការបង្ករោគគឺ (១) ការបង្ករោគក្នុងស្បូននិងទារកក្នុងផ្ទៃ (២) ការបង្ករោគ ផ្លូវបង្ហូរនោម (៣) ការបង្ករោគនៅផ្លូវដង្ហើម (៤)ជំងឺគ្រុនចាញ់ ។

(១) **ការបង្ករោគក្នុងស្បូននិងទារកក្នុងផ្ទៃ៖**

- ពេលខ្លះមេរោគបាក់តេរីនៅទ្វារមាសចូលទៅក្លាយរោគនៅមាត់ស្បូននិងទៅដល់ស្រោមទឹកភ្លោះ ។ បន្ទាប់មកបន្តបង្ករោគចូលដល់ទឹកភ្លោះ ទងសុក និង ចុងក្រោយដល់ទារកក្នុងផ្ទៃ ។
- ប្រសិនបើស្រោមទឹកភ្លោះបែក ការបង្ករោគអាចការរីករាលដាលលឿនជាងធម្មតា ។ ស្ត្រីអាចមានសញ្ញាដូចជា ជីពចរញាប់ ធ្លាក់សក្លិនស្អុយ ឈឺផ្នែកខាងក្រោមពោះ ។ ចង្វាក់បេះដូងទារកអាចនឹងកើនឡើង ហើយទឹកភ្លោះអាចមានក្លិនស្អុយ

  (មើល *១. ករណីបញ្ជូនបន្ទាន់ភ្លាមៗ សម្រាប់ស្ត្រីមាន ផ្ទៃពោះ ១-៥. សញ្ញាជីវិតមិនធម្មតា - គ្រុនក្តៅ* ទំព័រ១៥) ។

(២) **ការបង្ករោគផ្លូវបង្ហូរនោម៖**

- ពេលផ្លូវបង្ហូរនោមមានការបង្ករោគ ស្ត្រីអាចនឹងត្អូញត្អែរថានោមមកឈឺ ក្រហាយ ឬពិបាកនោម នោម ញឹកញាប់ និងនោមទាស់ ហើយឈឺពោះ ឬ មានគ្រុនក្តៅញាក់[១]

  (មើល *១. ករណីបញ្ជូន បន្ទាន់ភ្លាមៗ សម្រាប់ស្ត្រីមានផ្ទៃពោះ ១-៥. សញ្ញាជីវិតមិនធម្មតា - គ្រុនក្តៅ* ទំព័រ១៥) ។

(៣) **ការបង្ករោគនៅផ្លូវដង្ហើម៖**

- ពេលសួតមានការបង្ករោគ ស្ត្រីអាចនឹងត្អូញត្អែរពីការពិបាកដកដង្ហើម ក្អកមានស្លេស ។ ក្នុងករណីនេះគឺអាចសង្ស័យថាមានជំងឺរលាកសួតឬរបេង ។

(៤) **ជំងឺគ្រុនចាញ់៖**

- ករណីស្ត្រីមកពីតំបន់គ្រុនចាញ់ ស្ត្រីអាចប្រឈមនឹងការកើតជំងឺគ្រុនចាញ់ ។ រោគសញ្ញានៃជំងឺគ្រុនចាញ់មានដូចជា គ្រុនក្តៅញាក់ មានបែកញើស ឈឺក្បាល ឬឈឺសាច់ដុំសន្លាក់ ។

### ៦-៤-៤-២. សីតុណ្ហភាពរាងកាយលើសពី ៣៧.៥ ℃

- ដំបូងគេបង្ហស់គឺពិនិត្យមើលសញ្ញានៃការបង្ករោគដែលបានរៀបរាប់ខាងលើ ។ ប្រសិនបើមានសញ្ញាណាមួយត្រូវបញ្ជូនស្ត្រី។

- ប្រសិនបើគ្មានសញ្ញានៃការបង្ករោគទេ ត្រូវតាមដានកម្តៅរាងកាយឱ្យបានដិតដល់រៀងរាល់មួយម៉ោង ម្តង[១(p២២)] ។ លើកទឹកចិត្តស្ត្រីឱ្យបរិភោគទឹកឱ្យបានច្រើន និងកំណត់សីតុណ្ហភាពក្នុងបន្ទប់ឱ្យមានផា សុកភាពដល់ស្ត្រី បើទោះជាទារកទើបនឹងកើតត្រូវការសីតុណ្ហភាពលើសពី ២៥°C ។

## ៦-៥. ការពិនិត្យទឹកនោម

《**សង្ខេប**》

- ប្រសិនបើមានប្រូតេអ៊ីននៅក្នុងទឹកនោម នោះអាចនឹងបញ្ជាក់ថាមានការថយចុះមុខងារតម្រងនោម ដោយសារការលើសសម្ពាធឈាម ។
- តេស្តប្រូតេអ៊ីនក្នុងទឹកនោមនៅពេលចូលសម្រាកពេទ្យ ដោយប្រដាប់តេស្តទឹកនោម (Dipstick) ។
- លទ្ធផលតេស្តប្រូតេអ៊ីនក្នុងទឹកនោម (+/-) ឬ (+) គឺជាលក្ខណៈធម្មតានៃបម្រែបម្រួលសរីរៈសាស្ត្រ របស់ស្ត្រីមានផ្ទៃពោះ ។
- លទ្ធផលតេស្តប្រូតេអ៊ីនក្នុងទឹកនោម(++) ឬ (+++) គឺជាសូចនាករមួយក្នុងចំណោមសូចនាករ ផ្សេងទៀតដែលកំណត់រោគវិនិច្ឆ័យជំងឺបម្រុងក្រឡាភ្លើង ។
- ករណីដែលអ្នកមិនមានប្រដាប់តេស្តទឹកនោម ពិចារណាលើការបញ្ជូនតាមរយៈការវាស់សម្ពាធ ឈាមតែមួយគត់ ។

### ៦-៥-១. និយមន័យប្រូតេអ៊ីនក្នុងទឹកនោមក្នុងពេលមានផ្ទៃពោះ

- **ប្រូតេអ៊ីននៅក្នុងទឹកនោម** គឺជាវត្តមាននៃ**ប្រូតេអ៊ីនច្រើនហួសនៅក្នុងទឹកនោម** ។ តម្រងនោមដែលមាន មុខងារធម្មតាមិនអនុញ្ញាតិឱ្យមានប្រូតេអ៊ីនចេញតាមទឹកនោមច្រើនទេ ។ ដូច្នេះជាធម្មតាប្រូតេអ៊ីន នៅក្នុង ទឹកនោមមានតិចតួចណាស់ ។
- ក្នុងកំឡុងពេលមានផ្ទៃពោះ ចំនួនប្រូតេអ៊ីនធ្លាក់តាមទឹកនោមមានការកើនឡើងបណ្ដាលមកពី តម្រង់នោមទទួលបន្ទុកខ្លាំងដោយ ការកើនឡើងនៃបរិមាណឈាម ។ ទោះជាយ៉ាងនេះក្ដីប្រសិនបើ បរិមាណប្រូតេអ៊ីនធ្លាក់តាមទឹកនោមច្រើនខុសពីធម្មតា វាបញ្ជាក់ពីមុខងារតម្រងនោមខ្សោយ ។

### ៦-៥-២. និយមន័យជំងឺបម្រុងក្រឡាភ្លើង និងក្រឡាភ្លើង

- ជំងឺបម្រុងក្រឡាភ្លើងគឺជាស្ថានភាពនៃការមានផ្ទៃពោះ ដែលមាន**សម្ពាធឈាមកើនខ្ពស់ និងប្រូតេអ៊ីន នៅក្នុងទឹកនោមបន្ទាប់ពីអាយុគភ៌ ២០សប្ដាហ៍**[៥]។ វត្តមានប្រូតេអ៊ីននៅក្នុងទឹកនោម ប្ដូររោគ វិនិច្ឆ័យ ពីការលើសសម្ពាធឈាមទៅជាជំងឺបម្រុងក្រឡាភ្លើង[៥] ។
- ជំងឺក្រឡាភ្លើងគឺជាស្ថានភាពមួយដែល ស្ត្រីមានផ្ទៃពោះមានសញ្ញាប្រកាច់ជាមួយនឹងរោគសញ្ញាបម្រុង ក្រឡាភ្លើង ។ ប្រកាច់ជាសញ្ញាដែលផ្លាស់ប្ដូររោគវិនិច្ឆ័យពីជំងឺបម្រុងក្រឡាភ្លើងទៅជាជំងឺក្រឡាភ្លើង ។

### ៦-៥-៣. របៀបវាស់ប្រូតេអ៊ីននៅក្នុងទឹកនោម

- **ជ្រលក់ប្រដាប់តេស្តទឹកនោម** ត្រង់ផ្នែកដែលមានគំនូសពណ៌ **ចូលទៅក្នុងទឹកនោម** ហើយរង់ចាំមួយរយៈ (មើលការណែនាំនៅលើប្រដាប់តេស្តទឹកនោម) ។
- ប្រៀបធៀប លទ្ធផលជាមួយពណ៌ ហើយមើលលទ្ធផលថាជាសញ្ញា (–) និង (+) ។

### ៦-៥-៤. ចំណាត់ថ្នាក់ប្រូតេអ៊ីននៅក្នុងទឹកនោម

**ធម្មតា**: (-) , (+/-) , (+)

**ប្រូតេអ៊ីននៅក្នុងទឹកនោម**: (++)

**ប្រូតេអ៊ីននៅក្នុងទឹកនោមធ្ងន់ធ្ងរ**: (+++)

### ៦-៥-៥. ផលវិបាកដោយសារមានប្រូតេអ៊ីននៅក្នុងទឹកនោមនិងការលើសសម្ពាធឈាម

(មើល *ករណីបញ្ជូនបន្ទាន់ភ្លាមៗសម្រាប់ស្ត្រីមានផ្ទៃពោះ ១-៤. សញ្ញាជីវិតមិនធម្មតា - ការលើសសម្ពាធឈាម អប្បបរមា* ទំព័រ១៣ និង *៦-១. សម្ពាធឈាម* ទំព័រ៩៥)

**៦-៥-៥-១. ប្រូតេអ៊ីននៅក្នុងទឹកនោម** (+++)

- នៅពេលដែលមុខងារតម្រងនោមចុះខ្សោយ ប្រូតេអ៊ីនច្រោះចូលទៅក្នុងទឹកនោម។ វាបញ្ជាក់ថា មាន **ជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ** ហើយបណ្ដាលឱ្យមានផលវិបាកមួយចំនួន ។ វាអាចវិវត្តន៍ទៅជា**ជំងឺក្រឡាភ្លើង** នៅពេលដែលមានប្រកាច់ ។

**៦-៥-៥-២. ប្រូតេអ៊ីនក្នុងទឹកនោម** (++)

- ប្រសិនបើសម្ពាធឈាមធម្មតា ភាគច្រើនប្រូតេអ៊ីនក្នុងទឹកនោមក៏អាចនៅក្នុងកម្រិតធម្មតាដែរសម្រាប់ស្ត្រីមានផ្ទៃពោះ ។ គួរតាមដានសម្ពាធឈាមជាទៀងទាត់ ។
- ប្រសិនបើមានសម្ពាធឈាមលើស នោះបញ្ជាក់ថាស្ត្រីមានជំងឺបម្រុងក្រឡាភ្លើង ដែលធ្វើឱ្យមានផលវិបាកមួយចំនួន ។
- ប្រសិនមានសម្ពាធឈាមខ្ពស់ និងមានសញ្ញានៃការ**លើសសម្ពាធឈាម**បញ្ជាក់ថា ស្ត្រីមាន**ជំងឺបម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ។** ហើយវាអាចវិវត្តន៍ទៅជាជំងឺ**ក្រឡាភ្លើង ។**
- ប្រសិនបើស្ត្រីមិនពិសារទឹកគ្រប់គ្រាន់ លើកទឹកចិត្តឱ្យគាត់ពិសារឱ្យបានច្រើន ។

**៦-៥-៥-៣. តារាងនៃជំងឺបម្រុងក្រឡាភ្លើង បម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ក្រឡាភ្លើង**

| | សម្ពាធឈាមអប្បបរមា | ប្រូតេអ៊ីនក្នុងទឹកនោម | សញ្ញាលើសសម្ពាធឈាម | ការប្រកាច់ |
|---|---|---|---|---|
| **សម្ពាធឈាមខ្ពស់** | ≥ ៩០មមបារតវាស់២ដង(បន្ទាប់ពី១៥នាទី) | | | អត់មាន |
| **បម្រុងក្រឡាភ្លើង** | ៩០-១១០មមបារតវាស់២ដង (បន្ទាប់ពី១៥នាទី) | ++ | | អត់មាន |
| **បម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ** | ១) ≥ ១១០មមបារត | +++ | | អត់មាន |
| | ២) ≥ ៩០មមបារតវាស់២ដង(បន្ទាប់ពី១៥នាទី) | ++ | -ឈឺក្បាលខ្លាំង<br>-ស្រវាំងភ្នែក<br>-ឈឺនៅចុងដង្ហើម | អត់មាន |
| **ក្រឡាភ្លើង** | ≥ ៩០មមបារត | ++ ឬ +++ | | មាន |

## ៦-៦. ការធ្លាក់ឈាម

《សង្ខេប》
- នៅពេលដែលការធ្លាក់ឈាមច្រើនជាងទឹករំអិលលាយឈាម នោះអាចនឹងមានផលវិបាកមួយចំនួន ។
- ពិនិត្យស្ថានភាពការធ្លាក់ឈាម នៅពេលដែលស្ត្រីត្អូញត្អែរពីការធ្លាក់ឈាម ។ គួរសង្កេតផងដែរ នៅពេលលូកពិនិត្យទ្វារមាស ។
- សង្កេត ឬវាស់បរិមាណឈាមនៅលើសំឡីឬក្រណាត់ដែលស្ត្រីទ្រាប់ ។
- សញ្ញាផ្សេងទៀតនៃផលវិបាក (ការឈឺចាប់មិនធម្មតា និងការកន្ត្រាក់ស្បូន) គួរត្រូវបានសង្កេតមើលជាមួយគ្នា ។

### ៦-៦-១. សរីរៈសាស្ត្រនៃការធ្លាក់ឈាមក្នុងកំឡុងពេលឈឺពោះសម្រាលកូន

#### ៦-៦-១-១. ទឹករំអិលលាយឈាម(A show)

- **ទឹករំអិលលាយឈាមគឺជាបរិមាណឈាមតិចតួច ឬ ឈាមដែលមានលាយរំអិលដែលឃើញមាន** នៅរយៈពេលពីរ ឬ បីម៉ោងមុន ឬ បន្ទាប់ពីការឈឺពោះសម្រាលចាប់ផ្តើម ។ វាបណ្តាលមកពីការរបេះចេញនៃភ្នាសពីមាត់ស្បូននៅពេលដែលមាត់ស្បូនចាប់ផ្តើមបើក ។

#### ៦-៦-១-២. ការធ្លាក់ឈាមតាមផ្លូវសម្រាល

- ក្នុងកំឡុងពេលឈឺពោះសម្រាលកូន ការធ្លាក់ឈាមច្រើនជាងការធ្លាក់រំអិលលាយឈាមច្រើន តែត្រូវបានគេសង្កេតឃើញមានជាញឹកញាប់ ។ នេះគឺដោយសាររបួសទៅលើមាត់ស្បូន ឬ ទ្វារមាស នៅពេលដែលទារកឆ្លងកាត់ផ្លូវសម្រាល ។
- បរិមាណឈាមអាចនឹងកើនឡើងនៅពេលស្រោមទឹកភ្លោះបែក ហើយទឹកភ្លោះជ្រាបចេញមកជាមួយ ។

### ៦-៦-២. មធ្យោបាយដឹង/ប៉ាន់ប្រមាណការធ្លាក់ឈាមក្នុងពេលឈឺពោះសម្រាល

- នៅពេលដែលស្ត្រីត្អូញត្អែរពីការធ្លាក់ឈាម អ្នកត្រូវពិនិត្យស្ថានភាពនៃការធ្លាក់ឈាម ។ បន្ថែមពីលើនេះទៀត ការធ្លាក់ឈាមគួរតែត្រូវបានតាមដាន និងកត់ត្រា ជានិច្ចកាលនៅពេលលូកពិនិត្យទ្វារមាស ។
- ប្រសិនបើស្ត្រីប្រើសំឡីអនាម័យក្នុងអំឡុងពេលឈឺពោះសម្រាល សង្កេតមើល សំឡី ឬ ប៉ាន់ប្រមាណការកើនឡើងនៃការធ្លាក់ឈាម ។ អ្នកត្រូវដឹងទម្ងន់នៃសំឡីអនាម័យ ពេលមិនទាន់ប្រើ ។
- ករណីស្ត្រីមិនប្រើសំឡីអនាម័យទេ តាមដានមើលពីការសើមក្រណាត់ទ្រាប់ ។

## ៦-៦-៣. ផលវិបាកដោយសារការធ្លាក់ឈាមមិនធម្មតា

### ៦-៦-៣-១. ការធ្លាក់ឈាមច្រើនជាង ១០០មីលីលីត្រ តាំងពីពេលចាប់ផ្តើមឈឺពោះសម្រាល / ដែលជោកសំឡី ឬ ក្រណាត់ទ្រាប់ក្នុងរយៈពេលតិចជាង ៥ នាទី ។

មូលហេតុបីដែលអាចបណ្តាលឱ្យធ្លាក់ឈាមមិនធម្មតាក្នុងកំឡុងពេលឈឺពោះសម្រាលមាន (១) **សុករបើកមុនសម្រាល** (២) **រហែកស្បូន** និង (៣) **សុកពាំងមាត់ស្បូន ។** សូមពិនិត្យករណីធ្លាក់ឈាមនៃរាល់ការឈឺពោះសម្រាលមិនធម្មតា (មើល, *២. ស្តាប់ការត្អូញត្អែររបស់ស្ត្រី,២.១ ការធ្លាក់ ឈាម* ទំព័រ២០) ។ ចង្វាក់បេះដូងទារកថយចុះខ្លាំងក្នុងករណីមានការធ្លាក់ឈាម ដោយសារមូលហេតុទាំងបីនេះ ។

(១) **សុករបើកមុនសម្រាល** គឺជាការរបើកពីទីតាំងធម្មតារបស់សុកចេញពីស្បូនមុនសម្រាល ។

- ការរបើកសុកមុនសម្រាលអាចមានឈាមធ្លាក់ចេញមកក្រៅតាមទ្វារមាស ឬ លាយជាមួយទឹកភ្លោះ ហើយពេលខ្លះមានឈាមដក់នៅក្នុងស្បូន ។
- ជាញឹកញាប់ស្ត្រីមានការឈឺពោះខ្លាំង ឬ ឈឺពោះពេលប៉ះ ហើយស្បូនមានសភាពរឹង (មើល *២. ស្តាប់ការត្អូញត្អែររបស់ស្ត្រី,២-៣-៤. ផលវិបាកនៃការឈឺពោះមិនធម្មតា* ទំព័រ២៦) ។

(២) **រហែកស្បូន** គឺជាការរហែកជញ្ជាំងស្បូននៅទីតាំងមានស្នាមវះកាត់ពីមុន ។

- បរិមាណនៃការហូរឈាមចេញមកក្រៅតាមទ្វារមាសមិនសូវធ្ងន់ធ្ងរ តែមានការហូរឈាមដក់ក្នុងពោះខ្លាំង[5] ។
- ស្ត្រីត្អូញត្អែរថាមានការឈឺពោះខ្លាំង (មើល *'២. ស្តាប់ការត្អូញត្អែររបស់ស្ត្រី,២-៣-៤. ផលវិបាកនៃការឈឺពោះមិនធម្មតា* ទំព័រ២៦) ។

(៣) **សុកពាំងមាត់ស្បូន** គឺជាស្ថានភាពមួយនៅពេលដែលសុកស្ថិតនៅផ្នែកខាងក្រោមនៃស្បូន ហើយសុកស្ថិតនៅក្បែរឬនៅចំមាត់ស្បូន ។

- ការធ្លាក់ឈាមធ្ងន់ធ្ងរកើតឡើងនៅពេលដែលមាត់ស្បូនចាប់ផ្តើមបើក ដោយសារការ របើកចេញរបស់សុក ។
- ជាធម្មតា ស្ត្រីមិនត្អូញត្អែរពីការឈឺពោះធ្ងន់ធ្ងរទេ (មើល *២. ស្តាប់ការត្អូញត្អែររបស់ ស្ត្រី,២-១. ការធ្លាក់ឈាម* ទំព័រ២០) ។



ឈាមហូរពីខាងក្រៅ ឈាមហូរពីខាងក្នុង

**សុករបើកមុនសម្រាល**



ក្បែរមាត់ស្បូន ផ្នែកខ្លះនៃមាត់ស្បូន ចំមាត់ស្បូន

**សុកពាំងមាត់ស្បូន**

**៦-៦-៣-២. ការធ្លាក់ឈាមច្រើនជាងការធ្លាក់រំអិលលាយឈាម**

- ប្រសិនបើមានការ**ឈឺពោះសម្រាលមិនធម្មតា** ហើយ**ចង្វាក់បេះដូងទារកមិនធម្មតា** វាប្រហែល ជាការធ្លាក់ឈាមមកពីផ្លូវសម្រាល ។
- បន្តតាមដាន**បរិមាណឈាមដែលធ្លាក់** ចង្វាក់បេះដូងទារក និងការឈពោះមិនធម្មតា។ ប្រសិនបើទារកខ្សោយ ឬ មានការឈឺពោះសម្រាលមិនធម្មតាជាមួយនឹងការធ្លាក់ឈាមនោះអ្នកត្រូវគិតដល់**សុករបើកមុនសម្រាល ឬ រហែកស្បូន** (មើល *២.ការស្លាប់ការតួញត្អែររបស់ស្ត្រី ២.៣.ស្បូនកន្ត្រាក់និងការឈឺពោះសម្រាល* ទំព័រ២៥) ។

## ៦-៧. ស្ថានភាពផ្លូវចិត្ត

《សង្ខេប》

- ការធុញថប់ ឬ ការភ័យខ្លាចខ្លាំងអាចប៉ះពាល់ដល់ដំណើរការនៃការសម្រាល ។
- ត្រូវយកចិត្តទុកដាក់ជានិច្ចលើអារម្មណ៍ ការបង្ហាញទឹកមុខរបស់ស្ត្រី និងស្ដាប់ការត្អូញត្អែររបស់គាត់ក្នុងកំឡុងពេលឈឺពោះសម្រាល ។
- ជៀសវាងទុកស្ត្រីឱ្យនៅតែឯង និង ត្រូវបង្កើតបរិស្ថានដែលមានផាសុកភាពសម្រាប់ស្ត្រី ។

### ៦-៧-១. សុខភាពផ្លូវចិត្តក្នុងកំឡុងពេលឈឺពោះសម្រាល

- នៅពេលស្ត្រីកំពុងឈឺពោះសម្រាល វាជាការធម្មតាដែលស្ត្រីមានអារម្មណ៍ច្របូកច្របល់ទាំងរំភើប សង្ឃឹម ធុញថប់ ឬ ភ័យខ្លាច[៩] ។
- ស្ថានភាពផ្លូវចិត្តក៏ទទួលឥទ្ធិពលពីបរិយាកាសខាងក្រៅដូចជាអ្នកកំដរស្ត្រី បរិស្ថានសម្រាល និងអាកប្បកិរិយារបស់អ្នកផ្ដល់សេវាថៃទាំ ។

### ៦-៧-២. ការសង្កេតសុខភាពផ្លូវចិត្ត១៤

- សង្កេតមើលទឹកមុខរបស់ស្ត្រី អារម្មណ៍ និងស្ដាប់ការត្អូញត្អែររបស់គាត់ឱ្យបានល្អ ។ ស្ថានភាពភ័យស្លន់ស្លោ ឬស្រែកឡូឡា ជាញឹកញាប់គឺបណ្ដាលមកពីការធុញថប់ និងភ័យខ្លាចខ្លាំងពេក ។

### ៦-៧-៣. ឥទ្ធិពលនៃការធុញថប់ និងភ័យខ្លាចក្នុងកំឡុងពេលឈឺពោះសម្រាល១៤

- ការភ័យខ្លាច ឬ ធុញថប់ រារាំងការផលិត**អុកស៊ីតូស៊ីន** ដែលជា**អរម៉ូនសំខាន់សម្រាប់ដំណើរការសម្រាល ។** វាអាចពន្យឺតការឈឺពោះសម្រាល និងពន្យារការបើកមាត់ស្បូនដោយសារការកន្ត្រាក់ ស្បូនខ្សោយ។
- នៅពេលដែលស្ត្រីមានអារម្មណ៍ស្ត្រេសខ្លាំង នឹងធ្វើឱ្យមានការបញ្ចេញ**អាដ្រេណាលីន ។** អាដ្រេណាលីន រារាំងការផលិតអុកស៊ីតូស៊ីន និងអង់ដូហ្វីន (វាគឺជាអរម៉ូនមួយផ្សេងទៀតដែលធ្វើឱ្យអារម្មណ៍ស្ងប់ និងបំបាត់ការឈឺចាប់) ។ ការវិវត្តការសម្រាលអាចនឹងត្រូវរារាំងដោយសារកម្រិតទាបនៃអុកស៊ីតូស៊ីន ហើយស្ត្រីមានអារម្មណ៍ឈឺចាប់ជាងមុនដោយសារកម្រិតអង់ដូហ្វីនទាប ។

- មិនត្រូវទុកស្ត្រីឱ្យនៅម្នាក់ឯងហើយត្រូវសុំឱ្យអ្នកកំដរនៅជាមួយស្ត្រីជានិច្ច ។ បង្កើតបរិស្ថានដែលមានផាសុកភាពដូចជា ស្ងប់ស្ងាត់ និងពន្លឺភ្លើងស្រទន់ (ពន្លឺតិចៗ) ។
- សូមយោងទៅតាមសៀវភៅ *ការណែនាំស្តីពីការថែទាំផ្នែកសម្ភពចំពោះបុគ្គលម្នាក់ៗសម្រាប់ការមានផ្ទៃពោះនិងការសម្រាលធម្មតា*[១៤] ដើម្បីផ្តល់ការគាំទ្រសុខភាពផ្លូវចិត្តល្អដល់ស្ត្រី ។

<ឥទ្ធិពលនៃការធុញថប់ និងភ័យខ្លាចក្នុងកំឡុងពេលឈឺពោះសម្រាល>



# ឧបសម្ព័ន្ធ ១

តារាងវាយតម្លៃដំបូង

1. ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ

| សញ្ញា | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|
| 1) ស្មារតី | សន្លប់ [1(p13,18,23)]<br>ប្រកាច់[1(p18,23,24)] | សង្ស័យក្រឡាភ្លើង ឆ្កួតជ្រូក គ្រុនចាញ់ធ្ងន់ធ្ងរ រលាកស្រោមខួរ[1(p18),2(B6),5(S53-54)] |
| 2) ផ្លូវខ្យល់និងការដកដង្ហើម | ពិបាកដកដង្ហើម ដង្ហើមខ្លីនិងញាប់ (>30ដង/១នាទី)<br>មានស្វាយ(ជុំវិញបបូរមាត់)[1(p14)] | រលាកសួត ហឺត ស្លេកស្លាំងធ្ងន់ធ្ងរ ខ្សោយបេះដូង ហើមសួតស្រួចស្រាវ(APO) ស្ទះផ្លូវដង្ហើម |
| 3) សញ្ញាស្តុក | ជីពចរញាប់លើសពី100ដង/នាទី និងបែកញើសត្រជាក់ និងស្បែកស្លិត 1(p.14)<br>សម្ពាធឈាមអតិបរមាចុះទាប (<90មមបារត)[1(p14)] | ស្តុក[2(B3)] |
| 4) សញ្ញានៃជំងឺបម្រុងក្រឡាភ្លើង ឬ ជំងឺក្រឡាភ្លើង | សម្ពាធឈាមអប្បបរមា ≥110មមបារត ហើយប្រូតេអ៊ីនក្នុងទឹកនោម (+++)<br>សម្ពាធឈាមអប្បបរមា ≥90មមបារត ហើយប្រូតេអ៊ីនក្នុងទឹកនោម (++) រួមមានសញ្ញាណាមួយ (ឈឺក្បាលខ្លាំង ស្រវាំងភ្នែកឈឺចុងដង្ហើម)1(p.24) | បម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ |
| 5) គ្រុនក្តៅ | សីតុណ្ហភាពរាងកាយ>38.0℃ | ការបង្ករោគនៅស្បូននិងទារក |
| 6) ការធ្លាក់ឈាម | ដោកសំឡីឬក្រណាត់ទ្រាប់ < 5នាទី | ការធ្លាក់ឈាមធ្ងន់ធ្ងរ |
| 7) ការបង្ហាញមិនធម្មតា | ហុចថ្ពាស, ហុចបង្ហើយធំ, ហុចមុខ | ការបង្ហាញមិនធម្មតា |

* បញ្ជូនស្ត្រីភ្លាមទៅមូលដ្ឋានសុខាភិបាលដែលមានការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងទារកទើបកើត (CEmONC/CPA2 or CPA3)ប្រសិនបើស្ត្រីមានសញ្ញាណាមួយដែលត្រូវបញ្ជូន មុនពេលបញ្ជូនសូមផ្តល់ការសង្គ្រោះបឋម និងសូមបំពេញ អាយុគភ៌ និងការចាប់ផ្តើមឈឺពោះសម្រាល ( មុនសម្រាល ពេលសម្រាល ក្រោយសម្រាល)

ការសោកសរ!

**2.** ស្តាប់ការត្អូញត្អែររបស់ស្ត្រី

| **2.1** ធ្លាក់ឈាម | ពិនិត្យ 4.2. ស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃ និង 6. ការតាមដានស្ថានភាពស្ត្រី | | | |
|---|---|---|---|---|
| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
| 1) បរិមាណនៃការធ្លាក់ឈាម | អត់មានធ្លាក់ឈាម<br>ធ្លាក់រំអិលលាយឈាមតិចៗតាមទ្វារមាស [1(p47)] | ធ្លាក់ឈាមច្រើនជាងធម្មតាតាមទ្វារមាស[4(p22)] | ធ្លាក់ឈាមដោតសំឡីអនាម័យ ឬក្រណាត់ទ្រាប់ ក្នុងអំឡុងតិចជាង 5នាទី [2(B4)]<br>→មិនត្រូវលូកទ្វារមាស វាបណ្តាលអោយធ្លាក់ឈាមរឹតតែខ្លាំង! [1(p54)] | សង្ស័យសុកពាំងមាត់ស្បូន 1(p36)<br>សង្ស័យរបើកសុកមុនសម្រាល[1(p35)]<br>សង្ស័យរហែកស្បូន[1(p36)] |

| 2.2 ជ្រាបទឹកតាមទ្វារមាស | បញ្ជាក់សភាពរបស់ស្រោមទឹកភ្លោះ បែក(A) ឬ មិនទាន់បែក(B) |
|---|---|

A. ស្រោមទឹកភ្លោះបែក៖ ពិនិត្យ 4.2.2) ទឹកភ្លោះ, 6.4) សីតុណ្ហភាពរាងកាយ

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) ពេលវេលាបែកស្រោមទឹកភ្លោះ | ស្រោមទឹកភ្លោះមិនទាន់បែក | បែកស្រោមទឹកភ្លោះមុនពេលឈឺពោះសម្រាលកូន (PROM) | បែកស្រោមទឹកភ្លោះលើសពី18ម៉ោង[1(p130, 139)] | ប្រឈមមុខនឹងមានការបង្ករោគនៅក្នុងស្បូន និងនៅលើទារក[1(p130)] |

**B.** ស្រោមទឹកភ្លោះមិនទាន់បែក៖ ប្រាប់ស្ត្រីឱ្យរាយការណ៍បើមានជ្រាបទឹកភ្លោះតាមទ្វារមាស

| 2.3 ស្បូនកន្ត្រាក់ | ពិនិត្យ 5.2.) ការកន្ត្រាក់ស្បូន | | | |
|---|---|---|---|---|
| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
| 1) ស្បូនកន្ត្រាក់ | ស្បូនកន្ត្រាក់ទៀងទាត់ | ស្បូនកន្ត្រាក់មិនទៀងទាត់<br>ស្បូនមិនកន្ត្រាក់ | ឈឺពោះជាប់ចន្លោះស្បូនកន្ត្រាក់ [1(p36-37, 55)]<br>ឈឺពោះខ្លាំងភ្លាមៗ/ មានផ្ទត់ផ្តេកនៅផ្នែកខាងក្រោមផ្ចិត[1(p53,55)]<br>ឈឺពោះដែលខុសប្លែកពីការឈឺពោះដោយកន្ត្រាក់ស្បូន<br>ធម្មតាដែលរាយការណ៍ដោយស្ត្រី[4(p22)] | សង្ស័យរបើកសុកមុនសម្រាល[1(p35)]<br>សង្ស័យបម្រុងរហែកស្បូន[1(p36)]<br>សង្ស័យឈឺពោះខ្លាំងហួសកម្រិត<br>សង្ស័យមានរលាកខ្នែងពោះវៀន និងមូលហេតុផ្សេងៗទៀត[5(S-142,143)] |

| 2.4 ចលនាទារកក្នុងផ្ទៃ | ពិនិត្យ 4.2. ស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃ | | | |
|---|---|---|---|---|
| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
| 1) ចលនាទារកក្នុងផ្ទៃ | ទារកមានចលនាធម្មតា | ទារកក្នុងផ្ទៃគ្មានឬមានចលនាតិចតួច[1(p40)]<br>→ពិនិត្យចង្វាក់បេះដូងទារក | | សង្ស័យថាទារកក្នុងផ្ទៃចុះខ្សោយឬស្លាប់[5(S-155)] |

ការសាកសួរ! ពិនិត្យសៀវភៅសុខភាពមាតា (សៀវភៅពណ៌ផ្កាឈូក)!

3. ព័ត៌មានទូទៅ និងប្រវត្តិសម្ភពរបស់ស្ត្រី (ដើម្បីកំណត់ថាស្ត្រីអាចសម្រាលកូននៅមូលដ្ឋានសុខាភិបាលរបស់អ្នកបាន)

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) អាយុនៃគភ៌ | សម្រាលគ្រប់ខែ<br>(អាយុគភ៌ 37សប្តាហ៍ 0ថ្ងៃ<br>- 41សប្តាហ៍ 6ថ្ងៃ) | មិនដឹងអាយុគភ៌ | សម្រាលមិនគ្រប់ខែ: (≤36សប្តាហ៍ 6ថ្ងៃ)[1(p40), 3(p81)]<br>សម្រាលលើសខែ (≥42សប្តាហ៍ 0ថ្ងៃ) | សម្រាលមិនគ្រប់ខែ<br>សម្រាលលើសខែ |
| 2) កម្ពស់ស្បូន<br>ពេលចូលសម្រាកពេទ្យ | 29 - 32ស.ម | 33 - 34 ស.ម | ≥35ស.ម<br>≤28 សម | គភ៌កូនមួយហើយធំ និងសង្ស័យវិសមាមាត្ររវាងឆ្អឹងក្បាលទារកនឹងអាងត្រគាករបស់ម្តាយ(CPD)[5(S-83)]<br>គភ៌កូនភ្លោះឬកូនច្រើន<br>មានទឹកភ្លោះច្រើនហួស[5(S-101,102)]<br>ការសម្រាលកូនមិនគ្រប់ខែ ឬទារកតូច |
| 3) អាយុស្ត្រី | 18 - 34 ឆ្នាំ | 16, 17 ឆ្នាំ<br>≥35ឆ្នាំ កូនច្រើនដង | ≤15ឆ្នាំ<br>≥35 ឆ្នាំ ស្ត្រីកូនដំបូង | |
| 4) ក. ចំនួនផ្ទៃពោះ | | | ចំនួនផ្ទៃពោះ≥5ដង | សង្ស័យសម្រាលកូនចំនួន៥ដងឬច្រើនជាង៥ដង |
| ខ. ចំនួនសម្រាល | ≤ 3 ដង | 4ដង[4(p15,68)] | ≥ 5ដង | សម្រាលកូនចំនួន៥ដងឬច្រើនជាង៥ដង ប្រឈមមុខនឹងធ្លាក់ឈាមក្រោយសម្រាល[4(p68)] |
| គ. ចំនួនរលូត ឬរំលូត | គ្មានរលូត ឬរំលូត | រលូត ឬរំលូត ≥1ដង | | សង្ស័យមានប្រវត្តិរំលូតដោយការបូម(MVA),<br>ការកាយយកកូនចេញ ការបើកមាត់ស្បូន& គាបយកកូនចេញ)និងប្រឈមមុខនឹងធ្លាក់ឈាមក្រោយសម្រាល |
| 5) ចំនួនកូនក្នុងផ្ទៃ | គភ៌កូនមួយ | | គភ៌កូនច្រើន[1(p91)] | គភ៌កូនច្រើន[5(S-105)] |
| 6) កំពស់ស្ត្រី | >150 ស.ម | 145 - 150 ស.ម | <145 ស.ម | សង្ស័យCPD |
| 7) ភាពស្លេកស្លាំង | អេម៉ូក្លូប៊ីន >11.0 ក្រាម/ដេស៊ីលីត្រ[2(C4)]<br>គ្មានស្លេកស្លាំង[2(C4)] | អេម៉ូក្លូប៊ីន 8.0-11.0 ក្រាមដេស៊ីលីត្រ[1(p28)]<br>ភ្នាសត្របកភ្នែកក្រោមនិងបាតដៃស្លេកស្លាំងល្មម[1(p28)] | អេម៉ូក្លូប៊ីន <8.0ក្រាម/ដេស៊ីលីត្រ[1(p27, 56)]<br>ស្លេកស្លាំងធ្ងន់ធ្ងរនៅបាតដៃនិង/ឬភ្នាសត្របកភ្នែកក្រោម[1(p27)] | ស្លេកស្លាំងធ្ងន់ធ្ងរ[1(p100)] |
| 8)ស្ថានភាព<br>- ផ្ទុកមេរោគ/ជំងឺអេដស៍<br>- ជំងឺស្វាយ | តេស្តរកមេរោគអេដស៍អវិជ្ជមាន | មិនធ្លាប់ធ្វើតេស្ត[1(p31,54)] –ធ្វើតេស្ត | តេស្តរកមេរោគអេដស៍មានប្រតិកម្ម ឬវិជ្ជមាន[1(p54)] | ប្រឈមមុខនឹងការចម្លងមេរោគងអេដស៍ពីម្តាយទៅកូន[1(p107)] |
| | តេស្តរកមេរោគស្វាយ (RPR) អវិជ្ជមាន | មិនធ្លាប់ធ្វើតេស្ត[1(p54)] –ធ្វើតេស្ត | តេស្តរកមេរោគស្វាយមានប្រតិកម្ម ឬវិជ្ជមាន[1(p28)] | ប្រឈមមុខនឹងជំងឺស្វាយពីកំណើត[1(p130,142)] |
| 9) ប្រវត្តិនៃផ្ទៃពោះបច្ចុប្បន្ន | គ្មានប្រវត្តិមានផលវិបាក | | ធ្លាក់ឈាមមុនសម្រាល[4(p68)]<br>ប្រវត្តិជំងឺលើសឈាម [4(p12),5(S-50)] | សង្ស័យសុកពាំងមាត់ស្បូន (ក្បែរមាត់ស្បូន ផ្នែកខ្លះនៃមាត់ស្បូន ចំមាត់ស្បូន)[1(p36)]<br>មានជំងឺលើសឈាម[5(S-50)] |
| 10) ប្រវត្តិនៃការសម្រាលនៃផ្ទៃពោះមុន | គ្មានប្រវត្តិមានផលវិបាក | សម្រាលដោយដង្កៀប ឬដោយបូម [1(p22)]<br>រហែកទ្វារមាសកម្រិត3[1(p53), 2(D5), 4(p15)]<br>បើរីណេមានស្នាមថ្មេរ មានផ្លែ ឬដុះសាច់/សិរមាន់ រំខានដល់ការសម្រាល[1(p54,69), 2(D5)] | ប្រវត្តិជំងឺក្រឡាភ្លើង ឬ បម្រុងក្រឡាភ្លើង[2(C2, C3)]<br>ប្រវត្តិប្រកាច់[1(p22),2(C2)]<br>ប្រវត្តិធ្លាក់ឈាមក្រោយសម្រាល[1(p22, 53)]<br>ធ្លាប់សម្រាលដោយវះកាត់ (មានស្នាមវះកាត់)[1(p22,53)]<br>ប្រវត្តិធ្លាប់មានកូនកើតមកមានទម្ងន់ទាប ធៀបនឹងអាយុគភ៌,<br>កូនស្លាប់ក្នុងពោះ ឬ កូនស្លាប់នៅថ្ងៃដំបូង[1(p22)] | សង្ស័យមានការកើតឡើងវិញនូវជំងឺក្រឡាភ្លើង<br>ការប្រកាច់ និងធ្លាក់ឈាមក្រោយសម្រាល<br>ប្រឈមមុខនឹងរហែកស្បូន[5(S-107)] |
| 11) ប្រវត្តិជំងឺទូទៅ | គ្មានប្រវត្តិមានផលវិបាក | | ប្រវត្តិមានជំងឺទឹកនោមផ្អែម, ជំងឺផ្លូវដង្ហើម, ជំងឺបេះដូង | សម្រាប់ការគ្រប់គ្រងដែលសមស្រប[1(p159), 5(S-152,153)] |

មើល! ស្តាប់! ស្ទាប!

4. ការសង្កេតមើលស្ថានភាពទារកក្នុងផ្ទៃ

4.1 សណ្ឋាន ទម្រង់បង្ហាញ ការបង្ហាញរបស់ទារក

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) | សណ្ឋានបណ្តោយស្បូន | | ទារកទទឹងពោះ ទារកបញ្ឆិតពោះ[1(p55,87)] | ទីតាំងនិងការបង្ហាញទារកមិនធម្មតា<br>ប្រឈមមុខការសម្រាលមានឧបសគ្គ |
| 2) ទម្រង់បង្ហាញរបស់ទារក | ទម្រង់បង្ហាញកំពូលក្បាល | | ទម្រង់បង្ហាញបញ្ច្រាស់, ទម្រង់ហុចស្មា , ហុចថ្ងាស ,ហុចមុខ, ទម្រង់បង្ហាញបង្អើយធំ ទម្រង់បង្ហាញដៃទូលក្បាល, ទម្រង់កូនទទឹងពោះធ្លាក់ដៃ, ទម្រង់ធ្លាក់ទងសុកមកមុន [1(p86)] | |
| 3) ការបង្ហាញរបស់ទារក | ការបង្ហាញអុកស៊ីពុតនៅខាងមុខ | ការបង្ហាញអុកស៊ីពុតនៅក្រោយ[1(p84)]<br>ការបង្ហាញអុកស៊ីពុតនៅទទឹង | | |

4.2 ស្ថានភាពសុខភាពរបស់ទារកក្នុងផ្ទៃ

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) ចង្វាក់បេះដូងទារក | 110 -160ដង/1នាទី[1(p60)7(p. 74)] | 100-110ដង/1នាទី[1(p53,87) 3(p53)]<br>160 -180 ដង/1នាទី[1(p53,87) 3(p53)]<br>→ឱ្យម្តាយគេងផ្អៀងទៅឆ្វេង[1(p88)] បន្តតាមដានក្នុង15នាទីបន្ទាប់ ប្រសិនចង្វាក់នៅតែមិនមានការប្រែប្រួលត្រូវបញ្ជូន[1(p88), 2(p14)] | គ្មានចង្វាក់បេះដូងទារក<br>≤100ដង/1នាទី[3(p53)]<br>≥180ដង/1នាទី[3(p53)] | ទារកក្នុងផ្ទៃស្លាប់ ទារកក្នុងផ្ទៃចុះខ្សោយ<br>សង្ស័យម្តាយមានជំងឺគ្រុនផ្តាសាយ ប្រើប្រាស់ថ្នាំដែលធ្វើអោយបេះដូង<br>ម្តាយដើរលឿន (ឧទាហរណ៍ ថ្នាំតូកូលីទិច)លើសសម្ពាធឈាម ឬមានការបង្កពោគនៅក្នុងស្បូននិងលើទារកក្នុងផ្ទៃ[1(p87)] |
| 2) ទឹកភ្លោះ | | ទឹកភ្លោះលាយលាមក់ព្រៃរាវ ហើយមិនមានក្លិនស្អុយ[5(S-110)]<br>អត់មានទឹកភ្លោះក្រោយស្រោមទឹកភ្លោះបែក[3(p53), 5(C81)] | ទឹកភ្លោះលាយឈាម[1]<br>ទឹកភ្លោះលាយលាមក់ព្រៃខាប់[1(p87)] (ទឹកភ្លោះពណ៌បៃតងចាស់ ឬខ្មៅ មានលាយលាមកព្រៃដុំៗ)[4(p26)]<br>មានក្លិនស្អុយ[1(p41,54,56)] | សង្ស័យរបើកសុកមុនសម្រាល<br>ប្រឈមមុខនឹងរោគសញ្ញាទារកឈ្លក់លាមកព្រៃ (MAS)[5(S-110)]<br>សង្ស័យទារកក្នុងផ្ទៃចុះខ្សោយ[1(p87)] |

មើល! ស្តាប់! ស្ទាប!

**5.** ការប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល

**5.1** កំណត់ពីដំណាក់កាលនៃការឈឺពោះសម្រាល

| | | |
|---|---|---|
| ការបើកមាត់ស្បូន | ≤ 3ស.ម | រយៈយឺត (5.2) |
| | >3-10ស.ម | រយៈសកម្ម (5.3) |
| | មាត់ស្បូនបើកអស់ | ដំណាក់កាលទី2 (5.4) |

**5.2.**រយៈយឺត

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) ការចុះនៃក្បាលកូន -ដោយស្ទាប | ≤3/5 | 4/5-5/5[4(p22)] [ក្បាលកូនអណ្តែត] | | |
| 2) ការកន្ត្រាក់របស់ស្បូន | | | | |
| ក. ភាពញឹកញាប់នៃការ | ≤3 ដងក្នុង10នាទី | 4 - 5ដងក្នុង10នាទី | ≥6 ដងក្នុង10នាទី | ឈឺខ្លាំងហួសកម្រិត<br>សង្ស័យសុករបើកមុនសម្រាល[1(p36)]<br>រហែកស្បូន[1(p36,37)] |
| ខ. រយៈពេលកន្ត្រាក់ម្តងៗ(គិតជាវិនាទី) | 20 - 40 វិនាទី | >40វិនាទីពេលកន្ត្រាក់ម្តងៗ | ឈឺពោះជាប់ | |
| គ. កម្លាំង | មិនមានការឈឺជាប់ មានពេលសម្រាក | | ឈឺពោះពេលប៉ះ ពោះមានសភាពរឹងដូចជាបន្ទះក្តារ | |
| 3) រយៈពេលនៃរយៈយឺត | < 8 ម៉ោង | | ≥8ម៉ោង | សង្ស័យឈឺពោះយូរនៅរយៈយឺត |

**5.3** រយៈសកម្ម

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) ការចុះនៃក្បាលកូន -ដោយស្ទាប | ≤2/5 [ក្បាលកូនឆ្លងផុតច្រកលើ] | 3/5 | 4/5-5/5[4(p22)] [ក្បាលកូនអណ្តែត] | (ក្រហម)សង្ស័យCPD កូនវិលខុសប្រក្រតី ការបង្ហាញកូមិនធម្មតា ទីតាំងកូនខុសធម្មតា (លឿង)ប្រឈមមុខនឹងឈឺពោះយូរនៅរយៈសកម្ម |
| 2) ការកន្ត្រាក់របស់ស្បូន | | | | |
| ក. ភាពញឹកញាប់នៃការ | 3 - 5ដងក្នុង10នាទី | | ≥6ដងក្នុង10នាទី | ឈឺពោះខ្លាំងហួសកម្រិត សង្ស័យសុករបើកមុនសម្រាល[1(p36)] រហែកស្បូន[1(p36,37)] |
| ខ. រយៈពេលកន្ត្រាក់ម្តងៗ(គិតជាវិនាទី) | 20 - 60ពេលកន្ត្រាក់ម្តងៗ | >60 វិនាទី | ឈឺពោះជាប់រហូត | |
| គ. កម្លាំង | មិនឈឺជាប់ | | ឈឺពោះពេលប៉ះ ស្បូនមានសភាពរឹងដូចបន្ទះក្តារ | |
| 3) ភាពជ្រួសគ្នានៃលលាដ៍ក្បាលទារក | (0) - (+)[1(P60)] | (++) ជាមួយក្បាលកូនឆ្លងផុតច្រកលើ | (++) ជាមួយក្បាលកូនមិនទាន់ឆ្លងផុតច្រកលើ<br>(+++) ឬស្បែកក្បាលទារកហើម (Caput succedaneum) ដោយមិនចុះចូលក្នុងអាងត្រគាក | សង្ស័យCPD[1(p60)] ប្រឈមមុខនឹងឈឺពោះសម្រាលយូរនៅរយៈសកម្ម |

5.4 ដំណាក់កាលទី2

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) ការចុះនៃក្បាលកូន | នៅពេលបើរីណេចាប់ផ្តើមស្តើង លាតសន្ធឹង និងប៉ោង ជាមួយការកន្ត្រាក់ស្បូន និងមើលឃើញក្បាលទារក [1(p68)] | ស្បែកក្បាលទារកហើម (Caput succedaneum) | លលាដ៍ក្បាលជ្រួសគ្នា(+++) | សង្ស័យCPD1(p60) ប្រឈមមុខនឹងឈឺពោះសម្រាលយូរ |
| 2) ការកន្ត្រាក់របស់ស្បូន | | | | |
| ក. ភាពញឹកញាប់នៃការ | 4 - 5ដងក្នុង10នាទី | | ≥ 6ដង ក្នុង10នាទី | ឈឺខ្លាំងហួសកម្រិត ប្រឈមមុខនឹងរហែកស្បូន |
| ខ. រយៈពេលកន្ត្រាក់ម្តងៗ (គិតជាវិនាទី) | ប្រហែល60 វិនាទី | >60 វិនាទី | ឈឺពោះជាប់ | ឈឺខ្លាំងហួសកម្រិត ប្រឈមមុខនឹងរហែកស្បូន |
| គ. កម្លាំង | មិនមានការឈឺជាប់ មានពេលសម្រាក | | មានផ្នត់ផ្តេកនៅផ្នែកខាងក្រោមផ្ចិត [p37,53,55] រឹងគួរសម | ប្រឈមមុខនឹងរហែកស្បូន |
| 3) រយៈពេលស្ត្រីប្រឹងបញ្ចេញកូន មុនចូលសម្រាលនៅមូល | <45 នាទី (កូនដំបូង)<br><30 នាទី (កូនច្រើនដង) | 45នាទី (កូនដំបូង) [3(p46)]<br>30នាទី (កូនច្រើនដង) [3(p46)] | >60 នាទី (កូនដំបូង) * [3(p46)]<br>>30នាទី (កូនច្រើនដង) * [3(p46)]<br>*ជាមួយសញ្ញាចុះនៃក្បាលកូនមិនបានល្អប្រសើរ, លលាដ៍ក្បាលកូនជ្រួសគ្នាខ្លាំង, សញ្ញាទារកខ្សោយ | សង្ស័យការការសម្រាលមានឧបសគ្គ និងទារកខ្សោយ |

មើល! ស្តាប់!

6. តាមដានស្ថានភាពរបស់ស្ត្រី

| | សញ្ញាធម្មតា | សញ្ញាប្រឈមគ្រោះថ្នាក់ | សញ្ញាមិនធម្មតា/ផលវិបាក/សង្គ្រោះបន្ទាន់ | មូលហេតុបញ្ជូន |
|---|---|---|---|---|
| 1) សម្ពាធឈាម | សម្ពាធឈាមអតិបរមា< 140មមបារត និង សម្ពាធឈាមអប្បរមា< 90មមបារត | 160មមបារត>សម្ពាធឈាមអតិបរមា ≥ 140មមបារត [4(p22),5(S-51)] 110មមបារត>សម្ពាធឈាមអប្បរមា ≥ 90មមបារត →សូមទុកអោយស្ត្រីសម្រាកនិងវាស់សម្ពាធឈាមនៅរយៈពេល១៥នាទីបន្ទាប់ម្តងទៀត | សម្ពាធឈាមអតិបរមា ≥160មមបារត[4(p22), 5(S-51)] សម្ពាធឈាមអប្បរមា≥110មមបារត[1(p24)] | បម្រុងក្រឡាភ្លើង ឡើងសម្ពាធឈាមនៅពេលមានផ្ទៃពោះ[5(S-51)] |
| 2)សញ្ញានៃការលើសសម្ពាធឈាម | មិនមានសញ្ញាលើសសម្ពាធឈាម | | ឈឺក្បាលខ្លាំង ស្រវាំងភ្នែក ឬ ឈឺនៅចុងដង្ហើម[1(p24)] | បម្រុងក្រឡាភ្លើង ក្រឡាភ្លើង |
| 3) ជីពចរ | 60 - 100 ដង/1នាទី | >100/1នាទី[1(p14)] | | ស្ពុក[2(B3)] |
| 4) កម្តៅរាងកាយ | <37.5°C | 37.5°C- 38°C[4(p22)] | >38°C[1(p19,56,82)] មានបែកស្រោមទឹកភ្លោះ[1(p56)] ធ្លាក់សមានក្លិនស្អុយ[1(p41,56)] មានសញ្ញាបង្ករោគ[1(p38-39,83)] | សង្ស័យមានការបង្ករោគនៅក្នុងស្បូន និងនៅលើទារកក្នុងផ្ទៃ[1(p56)] មានការបង្ករោគនៅផ្លូវនោមផ្នែកខាងលើឬខាងក្រោម ជំងឺរលាកសួតរបេង គ្រុនចាញ់[1(p38-39,83)] |
| 5) ការពិនិត្យទឹកនោម | គ្មានប្រតេអ៊ីន ឬមានប្រូតេអ៊ីននៅក្នុងទឹកនោម (+) | ប្រូតេអ៊ីននៅក្នុងទឹកនោម (++)[1(p24,56)] | ប្រូតេអ៊ីននៅក្នុងទឹកនោម ≥ (+++) [1(p.24, 56)] | បម្រុងក្រឡាភ្លើង ក្រឡាភ្លើង |
| 6) ធ្លាក់ឈាមតាមទ្វារមាស | ធ្លាក់រំអិលលាយឈាមតិចៗតាមទ្វារមាស[1(p47)] | ធ្លាក់ឈាមច្រើនជាងធម្មតាតាមទ្វារមាស[4(p22)] | ធ្លាក់ឈាមជោកសំឡីអនាម័យ ឬក្រណាត់ទ្រាប់ក្នុងកំឡុងពេលតិចជាង 5នាទី [2(B4)] | សង្ស័យរបើកសុកមុនសម្រាល សុកពាំងមាត់ស្បូន (ក្បែរ មួយផ្នែក ឬចំមាត់ស្បូន), រហែកស្បូន |
| 7) ស្ថានភាពផ្លូវចិត្ត | មិនមានការត្អូញត្អែរ | ធុញថប់ ភ័យខ្លាច[1(p59)] | | |


Reference

1. *Safe Motherhood Clinical Management National Protocol for health center* (2016) Ministry of Health, Kingdom of Cambodia
2. *Integrated Management of Pregnancy and Childbirth, Pregnancy, Childbirth, Postpartum and Newborn care: A guide for essential practice* (2015) WHO
3. *Midwifery Curriculum for Health Center* (2016) NMCHC
4. *Intrapartum core for health women and babies, Clinical guidelines190* (2014) NICE
5. *Integrated Management of Pregnancy and Childbirth, Pregnancy, Managing Complications in Pregnancy and Childbirth: A guide for midwives and doctors* (2017) WHO
6. *Williams obstetrics* 24th edition (2014)
7. *WHO recommendations intrapartum care for a positive birth experience* (2018)

# ឧបសម្ព័ន្ធ ២

## តារាងពេលវេលាសង្កេត

ក្នុងរយៈយឺត

| 4. **ស្ថានភាពទារកក្នុងផ្ទៃ** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
|---|---|---|
| ស្តាប់ចង្វាក់បេះដូងទារក | រៀងរាល់ 30 នាទី[1(p60)] | រៀងរាល់ 15 នាទី[1(p88)] |
| ទឹកភ្លោះ (ប្រសិនបើបែកភ្លាម) | ពិនិត្យភ្លាម | |
| ទឹកភ្លោះ (ប្រសិនបើបែក) | រៀងរាល់ 4 ម៉ោង (ពេលលូកពិនិត្យទ្វារមាស) [1(p60)] | |
| 5. **ប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
| ការបើកនៃមាត់ស្បូនតាមរយៈការលូកពិនិត្យទ្វារមាស | រៀងរាល់ 4 ម៉ោង[1(p59)] | |
| ការចុះនៃក្បាលកូន | រៀងរាល់ 4 ម៉ោង (មុនពេលលូកពិនិត្យទ្វារមាស) | |
| ការកន្ត្រាក់របស់ស្បូន (ភាពញឹកញាប់ រយៈពេល កំលាំង) | រៀងរាល់ 1 ម៉ោង[1(p59)] | |
| 6. **តាមដានស្ថានភាពរបស់ស្ត្រី** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
| សញ្ញាជីវិត (សម្ពាធឈាម, ជីពចរ, កំដៅរាងកាយ) | រៀងរាល់ 2 ម៉ោង[1(p59)] | រៀងរាល់ 1 ម៉ោង [4(p22), 1(p.22-24),2(D23)] |
| ការធ្លាក់ឈាម | រៀងរាល់ 4 ម៉ោង (ពេលលូកពិនិត្យទ្វារមាស) [6(p341)] | |

*** បញ្ជូនស្ត្រីជាបន្ទាន់ បើស្ត្រីមានសញ្ញាមិនធម្មតាណាមួយទៅមូលដ្ឋានសុខាភិបាលដែលមានការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងទារកទើបកើត (CEmONC/CPA2 or CPA3) មុនពេលបញ្ជូនសូមផ្តល់ការសង្គ្រោះបឋម និងសូមបំពេញ អាយុគភ៌ និងការចាប់ផ្តើមឈឺពោះសម្រាល ( មុនសម្រាល ពេលសម្រាល ក្រោយសម្រាល)**

ក្នុងរយៈសកម្ម

| 4. ស្ថានភាពទារកក្នុងផ្ទៃ | សញ្ញាធម្មតា | សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ * |
|---|---|---|
| ស្តាប់ចង្វាក់បេះដូងទារក | រៀងរាល់ 30 នាទី[1(p60)] | រៀងរាល់ 15 នាទី[1(p88)] |
| ទឹកភ្លោះ (ប្រសិនបើបែកភ្លាម) | ពិនិត្យភ្លាម | |
| ទឹកភ្លោះ (ប្រសិនបើបែក) | រៀងរាល់ 4 ម៉ោង (ពេលលូកពិនិត្យទ្វារមាស) [1(p60)] | |
| 5. ប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល | សញ្ញាធម្មតា | សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ * |
| ការបើកនៃមាត់ស្បូនតាមរយៈការលូកពិនិត្យទ្វារមាស | រៀងរាល់ 4 ម៉ោង[1(p60)] + ច្រើនជាងនេះអាស្រ័យលើស្ថានភាពម្តាយ | |
| ការចុះនៃក្បាលកូន | រៀងរាល់ 4 ម៉ោង (មុនពេលលូកពិនិត្យទ្វារមាស) [1(p60)] | |
| ការកន្ត្រាក់របស់ស្បូន (ភាពញឹកញាប់ រយៈពេល កំលាំង) | រៀងរាល់ 30 នាទី[1(p60)] | |
| ភាពជ្រួសគ្នានៃលលាដ៏ក្បាលទារក | រៀងរាល់ 4 ម៉ោង (ពេលលូកពិនិត្យទ្វារមាស) [1(p60)] | |
| 6. តាមដានស្ថានភាពរបស់ស្ត្រី | សញ្ញាធម្មតា | សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ * |
| សញ្ញាជីវិត (សម្ពាធឈាម, ជីពចរ, កំដៅរាងកាយ) | រៀងរាល់ 2 ម៉ោង[1(p61, 62)] | រៀងរាល់ 1 ម៉ោង [4(p22), 1(p.22-24),2(D23)] |
| ការធ្លាក់ឈាម | រៀងរាល់ 4 ម៉ោង (ពេលលូកពិនិត្យទ្វារមាស) [6(p341)] | |

***បញ្ជូនស្ត្រីជាបន្ទាន់ បើស្ត្រីមានសញ្ញាមិនធម្មតាណាមួយទៅមូលដ្ឋានសុខាភិបាល ដែលមានការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងទារកទើបកើត (CEmONC/CPA2 or CPA3) មុនពេលបញ្ជូនសូមផ្តល់ការសង្គ្រោះបឋម និងសូមបំពេញ អាយុគភ៌ និងការចាប់ផ្តើមឈឺពោះសម្រាល (មុនសម្រាល ពេលសម្រាល ក្រោយសម្រាល)**

ក្នុងដំណាក់កាលទី2នៃការឈឺពោះសម្រាល

| **4. ស្ថានភាពទារកក្នុងផ្ទៃ** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
|---|---|---|
| ស្តាប់ចង្វាក់បេះដូងទារក | រៀងរាល់ 5 នាទី[1(p67)] | នៅចន្លោះស្បូនកន្ត្រាក់ម្តងៗ[1(p88), 2(D14)] |
| **ប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
| ការចុះនៃក្បាលកូន | សង្កេតរៀងរាល់ពេលប្រឹង | |
| ការកន្ត្រាក់របស់ស្បូន (ភាពញឹកញាប់ រយៈពេល កំលាំង) | រៀងរាល់ 10នាទី[1(p67)] | |
| **តាមដានស្ថានភាពរបស់ស្ត្រី** | **សញ្ញាធម្មតា** | **សញ្ញាប្រឈមមុខនឹងគ្រោះថ្នាក់ *** |
| សញ្ញាជីវិត( សម្ពាធឈាម, ជីពចរ, កំដៅរាងកាយ ) | រៀងរាល់ 5នាទី[7] | |
| ការធ្លាក់ឈាម | រៀងរាល់ 5នាទី | |

*** បញ្ជូនស្ត្រីជាបន្ទាន់ បើស្ត្រីមានសញ្ញាមិនធម្មតាណាមួយទៅមូលដ្ឋានសុខាភិបាល ដែលមានការសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងទារកទើបកើត (CEmONC/CPA2 or CPA3) មុនពេលបញ្ជូនសូមផ្តល់ការសង្គ្រោះបឋម និងសូមបំពេញ អាយុគភ៌ និងការចាប់ផ្តើមឈឺពោះសម្រាល ( មុនសម្រាល ពេលសម្រាល ក្រោយសម្រាល )**


Reference;

1. *Safe Motherhood Clinical Management National Protocol for health center* (2016) Ministry of Health, Kingdom of Cambodia
2. *Integrated Management of Pregnancy and Childbirth, Pregnancy, Childbirth, Postpartum and Newborn care: A guide for essential practice* (2015) WHO
3. *Midwifery Curriculum for Health Center* (2016) NMCHC
4. *Intrapartum core for health women and babies, Clinical guidelines190* (2014) NICE
5. *Integrated Management of Pregnancy and Childbirth, Pregnancy, Manageing Complications in Pregnancy and Childbirth: A guide for midwives and doctors* (2017) WHO
6. *Williams obstetrics* 24th edition (2014)
7. *Partograph Guideline for labor monitoring*

# ឧបសម្ព័ន្ធ ៣

បញ្ជីឈ្មោះសម្ភារៈប្រើប្រាស់

ទាំងនេះគឺជាបញ្ជីឈ្មោះសម្ភារៈប្រើប្រាស់ដើម្បីប្រមូលព័ត៌មានជាមួយនឹងតារាងវាយតម្លៃដំបូង និង ផ្តល់នូវការព្យាបាលចាំបាច់មុនពេលបញ្ជូន ។

| ជំពូក | សម្ភារៈ |
|---|---|
| **១.ករណីបញ្ជូនបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ** | |
| ១-១. ស្មារតី | ម៉ាញ៉េស្យូមស៊ុលហ្វាត ៥ក្រាម/១០មីលីលីត្រ |
| | សេរ៉ូមប្រៃ (សម្រាប់ពង្រាវ) |
| | សេរ៉ូមប្រៃ ១លីត្រ(សម្រាប់ព្យួរសេរ៉ូម) |
| | ម្ជុលចាក់សរសៃវ៉ែនលេខ២៥G |
| | ទុយោបន្តោងសេរ៉ូម (២០ដំណក់/១មីលីលីត្រ) |
| | សេរាំង ៣០មីលីលីត្រ |
| | សេរាំង ១០មីលីលីត្រ |
| ១-២. ផ្លូវដង្ហើមនិងការដកដង្ហើម | បំពង់អុកស៊ីសែន |
| | ម៉ាស់អុកស៊ីសែន ឬ cannula |
| ១-៣. សញ្ញាស្តុក | ប្រដាប់វាស់សម្ពាធឈាម |
| | ម្ជុលកាតេទ័រលេង១៦G ឬ១៨G |
| | សេរ៉ូមឡាក់តាតរីងគរ ឬសេរ៉ូមប្រៃ១លីត្រ |
| | ទុយោបន្តោងសេរ៉ូម (២០ដំណក់/១មីលីលីត្រ) |
| ១-៥. គ្រុនក្តៅ | ទែម៉ូម៉ែត្រ |
| **២.ស្តាប់ការត្អូញត្អែររបស់ស្ត្រី** | |
| ២-២ ជ្រាបទឹកតាមទ្វារមាស | ប្រដាប់បើកមាត់ស្បូន (Speculum ឬ S/M) |
| | (ថ្នាំអំពីស៊ីលីន១ក្រាម (as sodium salt) ក្នុងកូនដប) |
| | (ថ្នាំហ្សង់តាមីស៊ីន ៨០មីលីក្រាម (as sulfate)/ មីលីលីត្រ) |
| **៣.ព័ត៌មានទូទៅនិងប្រវត្តិសម្ភពរបស់ស្ត្រី** | |
| ៣-១.អាយុនៃគភ៌ពេលចូលសម្រាកពេទ្យ | កងប្រតិទិនរបស់ស្ត្រីមានផ្ទៃពោះ |
| ៣-២. កម្ពស់ស្បូន ពេលចូលសម្រាកពេទ្យ | ខ្សែម៉ែត្រ |
| ៣-៦. កំពស់ស្ត្រី | ម៉ែត្រ |
| ៣-៧. ភាពស្លេកស្លាំង | ប្រដាប់តេស្តភាពស្លេកស្លាំង (អេម៉ូខ្សូ) |
| ៣-៨.ស្ថានភាព<br>- ផ្ទុកមេរោគ/ជំងឺអេដស៍<br>- ជំងឺស្វាយ | តេស្តរកមេរោគអេដស៍រហ័ស |
| | តេស្តរកមេរោគស្វាយរហ័ស |
| | តេស្តរកមេរោគអេដស៍និងស្វាយរហ័ស |
| **៤. សង្កេតស្ថានភាពទារកក្នុងផ្ទៃ** | |
| ៤-១-១.ចង្វាក់បេះដូងទារក | ឌុបភ្លរ |
| **៥.ការប៉ាន់ប្រមាណការវិវត្តការឈឺពោះសម្រាល** | |
| ៥-២.កំណត់ដំណាក់កាលការឈឺពោះសម្រាល | ស្រោមដៃ |

| | |
|---|---|
| ៥-៣-១ កំលាំង (ការកន្ត្រាក់របស់ស្បូន) | នាឡិកា |
| **៦.ការសង្កេតមើលស្ថានភាពម្តាយ** | |
| ៦-១. សម្ពាធឈាម | ប្រដាប់វាស់សម្ពាធឈាម |
| ៦-៤. កម្តៅរាងកាយ | ទែរម៉ូម៉ែត្រ |
| ៦-៥. ការពិនិត្យទឹកនោម | ប្រដាប់តេស្តទឹកនោមសម្រាប់មើលប្រូតេអ៊ីនក្នុងទឹកនោម |
| ៦-៦. ធ្លាក់ឈាមតាមទ្វារមាស | រង្វាស់ |

# ឯកសារយោង


១. *Safe Motherhood Clinical Management National Protocol for health center* (2016) Ministry of Health, Kingdom of Cambodia

២. *Integrated Management of Pregnancy and Childbirth, Pregnancy, Childbirth, Postpartum and Newborn care: A guide for essential practice* (2015) WHO

៣. *Midwifery Curriculum for Health Center* (2016) NMCHC

៤. *Intrapartum core for health women and babies, Clinical guidelines190* (2014) NICE

៥. *Integrated Management of Pregnancy and Childbirth, Pregnancy, Managing Complications in Pregnancy and Childbirth: A guide for midwives and doctors* (2017) WHO

៦. *Williams obstetrics* 24th edition (2014)

៧. *Methods for Estimating the Due Date*, Committee Opinion No. 611. American College of Obstetricians and Gynecologists. Obstet Gynecol 2017; Number 700:

៨. ICD-10: international statistical classification of diseases and related health problems: tenth revision. — 2*nd* ed. Ver.3, WHO

៩. Marshall, J. and Raynor, M. (2014). *Myles Textbook for midwives*. 16*th* ed. Elsevier.

១០. World Health Organization, 2004, *Adolescent Pregnancy Issues in Adolescent Health and Development,* Department of Child and Adolescent Health and Development World Health Organization, Geneva

១១. *National Guideline for the prevention of Mother-to-Child Transmission of HIV and Syphilis*, 2016, 4th edition Ministry of Cambodia

១២. Royal College of Obstetricians & Gynaecologists, eLearning and Simulation for Instrumental Delivery (EaSi), resourse, Accessed on 15th June, Available at: https://elearning.rcog.org.uk/tutorials/technical-skills/elearning-and-simulation-instrumental-delivery-easi/easi-resource

១៣. World Health Organization, 2018, *WHO recommendations Intrapartum care*

*for a positive childbirth experience. Geneva: WHO*

១៨. NMCHC and JICA Project for Improving Maternal and New born Care through Midwifery Capacity Development, 2011, *Guide to Individualized Midwifery Care for Normal Pregnancy and Birth*

១៩. De Santis, M., De Luca, C., Mappa, I., Spagnuolo, T., Licameli, A., Straface, G., and Scambia, G., 2012, Syphilis Infection during Pregnancy: Fetal Risks and Clinical Management. *Infectious Diseases in Obstetrics and Gynecology*, 2012, pp.1-5

## សមាជិករៀបរៀងនិងប្រែសម្រួលសៀវភៅណែនាំនេះ:

**<Core members from NMCHC>**

| | |
|---|---|
| Prof. Tung Rathavy | Director |
| Assi Prof. Pech Sothy | Deputy director, In-charge of Traning Unit |
| Asso Prof. Som vanrithy | Chief of Technical Bureau |
| Dr. Saing Sona | Vice chief of Training Unit |
| Dr. Nuon Veasna | Chief of Labour and Delivery ward |
| Dr. Ros Saphath | Vice chief of Labour and Delivery ward |
| Dr. Krouch Rayounette | Vice chief of Outpatient department |
| Ms. Chhay Sveng Chea Ath | Director of Nursing,<br>President, Cambodian Midwifery Association |
| Ms. Oung Lida | Chief of Nursing, Labour and Delivery ward, |
| Ms. Keo Vantha | Chief of Nursing, Maternity and Postnatal Care |
| Ms. Pan Kimleang | Chief of Nursing, Outpatient department |
| Ms. Chhin Soknay | Midwife, Training Unit |
| Ms. Heng Ngim | Midwife, Training Unit<br>Vice president, Cambodian Midwifery Association |

**<Special technical supervisors>**

| | |
|---|---|
| Prof. Koum Kanal | President,<br>Cambodian Society of Gynecology & Obstetrics |
| Prof. Keth Ly Sotha | Vice-president,<br>Cambodian Society of Gynecology & Obstetrics |
| Assi Prof. Uong Sokhan | Cambodian Society of Gynecology & Obstetrics |

**<JICA IINeoC experts >**

| | |
|---|---|
| Ms. Kanda (Ishioka) Miwa | Short-term expert (Midwifery care) |
| Ms. Masuda Chisato | Short-term expert (Midwifery care) |

| | |
|---|---|
| Ms. Masaki Yoko | Long-term expert (community maternal and newborn health) |
| Ms. Tsukada Minori | Long-term expert (Midwifery care) |
| Dr. Matsui Mitsuaki | Short-term expert (Obstetric care) |
| Dr. Iwamoto Azusa | Chief advisor |

**<JICA IINeoC project staff >**

| | |
|---|---|
| Ms. Neang Munin | Technical staff |
| Mr. Hong Sunhao | Technical staff |